ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-Aug-2016, 09:46
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៤១៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន  ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក រ៉ូជ័ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ខេល លីសាក់ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច (2-TCW-916) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក កាំង ហ្កេកអ៊ាវ ហៅឌុច** (2-TCW-916)


សួរបន្តដោយលោក ឌែល លីសាក់ ផ្ដើមពី ............................................................ ទំព័រ ២

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................................................ ទំព័រ ៤៧

សួរដោយចៅក្រម ហ្សង់ ម៉ាកឡាវែន៍ ផ្ដើមពី ......................................................... ទំព័រ ៦០

# កិច្ចដំណើរការនីតិវិធី

[០៩:០០:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។ ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាព អវត្តមាន ភាគី និងបុគ្គល ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ ហើយសាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបន្តនៅថ្ងៃនេះ គឺលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច លោកមានវត្តមានរួចហើយ នៅក្នុងបន្ទប់សវនាការនេះ។

សូមអរគុណលោកប្រធាន។

[០៩:០១:៣១]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែល កុលវុឌ្ឍី។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាពឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំ

ការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ បានកត់សម្គាល់អំពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចង្កេះខ្លាំង ពេលអង្គុយ និងវិលមុខ អស់កម្លាំងពេលធ្វើចលនា និងបានផ្តល់អនុសាសន៍ សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម តាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០២:៣៥]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បន្តទៅនេះ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

បាទ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ម្សិលមិញ ពេលដែលយើងបញ្ចប់ទៅ គឺយើងបានសួរពាក់ព័ន្ធទៅនឹង ខៀវ សំផន។ ហើយលោកមានការពិភាក្សាជាមួយ ប៉ង់ ដែលបានប្រាប់លោកថា ខៀវ សំផន បានចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំមួយ ពាក់ព័ន្ធទៅនឹងការចាប់ខ្លួន ជូ ជេត ហៅ ស៊ី ជាប្រធានភូមិភាគបស្ចិម។

[០៩:០៣:៥៨]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យ៉ាងម៉េចទៅ? សូមអញ្ជើញលោកស្រី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជាដំបូង ខ្ញុំសូមអភ័យទោស ពីព្រោះកាលពីម្សិលមិញ ពេលដែលខ្ញុំងើបឡើង ខ្ញុំនិយាយអំពីឯកសារមួយនៅឆ្នាំ៩៩ <ហើយខ្ញុំមានការភ័ន្តច្រឡំ>។ ឯកសាររបស់សហព្រះរាជអាជ្ញា ដែល E3/347 សូមអភ័យទោស ខ្ញុំសូមមើលបន្តិចសិន។ គឺឯកសារ E3/347 ហ្នឹង មិនមែនជាបទសម្ភាសន៍ជាមួយ នេត ថាយ័រ ទេ ជាការសម្ភាសជាមួយឧត្តមស្នងការសិទ្ធិមនុស្ស -- អំ! ជនភៀសខ្លួន។ ហើយ ERN <00160922>, ជាភាសាបារាំង <00184998> ដែល<សាក្សី>បានយោងទៅលើ<ការសន្ទនា>ជាមួយ ប៉ង់ ជាការសំខាន់ដែលខ្ញុំត្រូវលើកឡើងថា ក្រោយពីការសម្ភាសដែលមានពាក់ព័ន្ធទៅនឹងចម្លើយសារភាពនោះ ខ្ញុំសូមជំទាស់ទៅនឹងការបន្តសួរសំណួរបែបនេះទៀត ពីព្រោះថាបើសិនបើយើងផ្អែកលើចម្លើយសារភាពរបស់ ប៉ង់ យកមកសួរនោះគឺវាមិនត្រឹមត្រូវទេ។

[០៩:០៥:៥០]

**លោក ឌេល លីសាក់៖**

នេះមិនមែនអ្វីដែលគាត់បានឆ្លើយ។ គាត់ឆ្លើយថា <នៅក្រោយពេលគាត់ផ្ដល់ចម្លើយសារភាពរួចហើយ។ គាត់បានធ្វើសេចក្ដីថ្លែងការណ៍ខុសគ្នាលើបញ្ហានេះផងដែរ។> នៅក្នុងសក្ខីកម្ម<ដំបូងរបស់គាត់ ពាក់ព័ន្ធទៅនឹងពេលវេលាជាក់ដែលរឿងនេះកើតឡើង។ នេះពិតជាបញ្ហាមួយ ដែលមេធាវីការពារក្ដីត្រូវសួរសាក្សី។ ខ្ញុំកំពុងសួរលើបញ្ហាផ្សេងពីនោះ>។ ហើយមេធាវីការពារក្ដីអាចចោទសួរបញ្ហានេះបាន នៅពេលដល់វេណរបស់ខ្លួន ហើយស្វែងរកឲ្យឃើញថា តើមានកាលៈទេសៈដែលមានថាការពិភាក្សាជាមួយនឹង ប៉ង់ មែនដែរឬក៏អត់នោះ។

**កញ្ញា អង់តា ហ្គីសសេ៖**

ប្រហែលជាខ្ញុំត្រូវដកស្រង់នៅក្នុងចម្លើយនេះឲ្យបានច្បាស់ ដើម្បីកុំឲ្យមានការភ័ន្តច្រឡំ។ "<បើយើងជឿ>ចម្លើយសារភាពរបស់ ឈឹម សំអោក ហៅ ប៉ង់ ក្រោយពីគាត់បាន<បញ្ចប់>ការសរសេរ<ចម្លើយសារភាព>ទៅ ខ្ញុំបាននិយាយជាមួយគាត់"។ ដូចគ្នាដែរ កាលពីម្សិលមិញ ខ្ញុំបាននិយាយថា នៅពេលដែលអ្នកណាម្នាក់ត្រូវបានសួរចម្លើយនៅស-២១ ជាអ្នកឃុំ -- ជាអ្នកជាប់ឃុំនៅស-២១។ ដូច្នេះពាក់ព័ន្ធទៅនឹងចម្លើយសារភាពរបស់គាត់មិនត្រូវយកមកប្រើប្រាស់នៅក្នុងក្របខ័ណ្ឌនៃនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះនោះទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

ខ្ញុំដូចជាភ្ញាក់ផ្អើលចំពោះការជំទាស់របស់មេធាវី កូប៉េ -- របស់ មេធាវី អង់តា ហ្គីសសេ។ <យើងដឹងថាសាក្សីមានចំណងរឹងមាំ>ជាមួយនឹង<ប៉ង់> ដូច្នេះពេលនោះគាត់មានទំនាក់ទំនងជាមួយនឹងគ្នាហើយ។ <យើងដឹងថា ប៉ង់ ក៏ត្រូវបានឃុំខ្លួននៅស-២១ដែរ។> យើងមានចម្លើយសារភាពរបស់ ប៉ង់ នៅក្នុងសំណុំរឿង លើកលែងតែលោកស្រីបង្ហាញឲ្យឃើញច្បាស់ ថាព័ត៌មានទាំងអស់<ដែលយកមកសួរ>នុំងចេញមកពីចម្លើយសារភាព។ ដូច្នេះគ្រាន់តែកំណត់ត្រាសាមញ្ញមួយ លោកស្រីយកមកនិយាយថា ព័ត៌មានដែលផ្តល់ដោយ ប៉ង់ ហ្នឹងគឺបានមកពីការធ្វើទារុណកម្មនោះ ដូចជាមិនត្រឹមត្រូវទេ។

[០៩:០៨:០២]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកចៅក្រម ឡាវែន៍ ខ្ញុំអត់យល់ការកត់សម្គាល់របស់លោកចៅក្រមទេ។ <ដំបូងបង្អស់កំណត់សម្គាល់សាមញ្ញនេះគឺថា ទាំងអស់នេះគឺជាចម្លើយរបស់សាក្សី ដោយសារថា ឃ្លាដំបូងនោះ> និយាយថា "បើ<យើង>ជឿទៅលើចម្លើយសារភាព ឈឹម សំអោក ហៅ ប៉ង់"។ អ៊ីចឹងសាក្សីរូបនេះផ្ទាល់គាត់និយាយថា <ការសន្ទនាគ្នានេះធ្វើឡើងនៅពេលដែល> ប៉ង់ <>នៅស-២១ ហើយ<បានឆ្លើយសារភាព>។ ដូច្នេះមិនមែនជាសម្តីខ្ញុំទេ គឺសាក្សីគាត់និយាយផ្ទាល់ដោយខ្លួនឯង។ ហើយបើសិនជាខ្ញុំយោងទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះកាលពីម្សិលមិញហ្នឹង មិនមែនខ្ញុំជាអ្នកត្រូវបង្ហាញភស្តុតាងឲ្យឃើញថា ចម្លើយ ប៉ង់ ហ្នឹងទទួលបានដោយធ្វើទារុណកម្ម ឬក៏មិនធ្វើនោះ មិនមែនខ្ញុំជាអ្នកបង្ហាញទេ គឺភាគីដែលយកមកសួរហ្នឹងត្រូវតែបង្ហាញឲ្យឃើញថា ព័ត៌មានដែលខ្លួនយកមកសួរសាក្សីហ្នឹង គឺមិនត្រូវបានទទួលដោយសារ<ការ>ធ្វើទារុណកម្ម<ទេ>។ <ដូច្នេះឥឡូវនេះ មានការកែប្រែបន្ទុកក្នុងការដាក់ភស្តុតាង ដែលខ្ញុំមិនយល់សោះ។>

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

យើងឯកភាពហើយថា ចម្លើយហ្នឹង ព័ត៌មានហ្នឹង មិនបានទទួលមកពីចម្លើយសារភាពរបស់ ប៉ង់ ទេ គឺជាព័ត៌មានជាទូទៅ។ ហើយយើងៗមានចម្លើយសារភាពរបស់ ប៉ង់ នៅក្នុងសំណុំរឿង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដូច្នេះបើអ៊ីចឹងយើងពិនិត្យមើលចម្លើយសារភាពហ្នឹងទៅថា តើមានព័ត៌មានហ្នឹងឬក៏អត់? វាចេញមកពីចម្លើយសារភាពឬក៏អត់? <>ខ្ញុំ<គិតថា លោកស្រីកំពុងតែ>យោងទៅលើសំណួរកាលពីម្សិលមិញរបស់សហព្រះរាជអាជ្ញា។ ខ្ញុំ<មិនយល់>ថា ការជំទាស់ហ្នឹងគឺ<ផ្អែកទៅលើសំណួរដែលសួរនៅព្រឹកនេះ>ទេ។ អ៊ីចឹងអាចព្រះរាជអាជ្ញាសួរតទៀតទៅ ហើយប្រសិនបើដល់វេន លោកស្រីៗ អាចសួរបញ្ជាក់បានត្រង់ចំណុចហ្នឹង។

[០៩:០៩:៥០]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំបញ្ជាក់ថា ខ្ញុំងើបឡើងម្ដងទៀតហ្នឹង ព្រោះថាសហព្រះរាជអាជ្ញាបាននិយាយដោយចាប់ផ្ដើមថា "លោកបាន<>សន្ទនាជាមួយ ប៉ង់"។ អ៊ីចឹងកាលពីម្សិលមិញហ្នឹងគឺថាចប់ផ្អាកត្រឹមហ្នឹង។ អ៊ីចឹងគឺបានជាខ្ញុំងើបឡើងម្ដងទៀតហ្នឹង ខ្ញុំត្រឡប់មកនិយាយកន្លែងហ្នឹងដដែល គឺដោយយោងទៅលើឯកសារ E3/347 ហ្នឹង គឺយើងខ្ញុំចង់ងើបឡើងហ្នឹង គឺថាដើម្បី<ឲ្យអង្គជំនុំជម្រះចេញសេចក្ដីសម្រេចរបស់ខ្លួន តែ>យ៉ាងហោចណាស់<ក៏ការបញ្ចេញមតិរបស់ខ្ញុំ>មាន<ក្នុង>កំណត់ត្រានៅក្នុងប្រតិចារឹកសវនាការ<ដែរឥឡូវ>។

[០៩:១០:២០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអនុញ្ញាតឲ្យខ្ញុំសួរសំណួរទៅកាន់សាក្សីសិនទៅ ហើយមេធាវីការពារក្ដីចាំតាម ពិនិត្យតាមក្រោយ។ លោកសាក្សី លោកនិយាយថា ប៉ង់ បាននិយាយជាមួយ<លោកអំពី> ខៀវ សំផន ថាតើនេះជាផ្នែកមួយនៃចម្លើយសារភាព ឬក៏ជាការសន្ទនាមួយដាច់ដោយឡែករវាងលោក ហើយនិង ប៉ង់?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ថា ពេលនោះបង សុន សេន អញ្ជើញទៅសមរភូមិមុខបាត់ទៅហើយ។ បងនួន ចាត់តាំងឲ្យ ប៉ង់ ចុះឡើងមកគ្រប់គ្រងស-២១។ ដូច្នេះ ខ្ញុំសួរ ប៉ង់ ក្នុងឋានៈគាត់ជាអ្នកគ្រប់គ្រងស-២១ ជាមេខ្ញុំ។ ឯកសារចម្លើយរបស់ ប៉ង់ ខ្ញុំចាំ អត់មានអីសំខាន់ទេ គាត់រវល់តែបដិសេធ។ ដូច្នេះ ពាក្យដែលខ្ញុំបានទាំងប៉ុន្មានយកមករាយការណ៍ជូនសវនាការនេះ គឺជាពាក្យរបស់ ប៉ង់ ក្នុងឋានៈគាត់ជាមេ របស់ស-២១ ជំនួសមុខឲ្យ ពូនួន។

[០៩:១១:៥៣]

**ស៖** អ្វីដែលខ្ញុំចង់សួរលោកឲ្យពិតប្រាកដនោះគឺ ចម្លើយដែលលោក ខៀវ សំផន បានឆ្លើយពេលដែលសម្ភាសដោយ ស្ទីវ ហេដឌ័រ គឺឯកសារ E3/203, ERN ជាភាសាខ្មែរ 00385413 ដល់ 14, អង់គ្លេស 00424016, បារាំង 00434236 ដល់ 37។ ឯកសារនេះគឺឯកសារ E3/203។ ខ្ញុំសូមអានផ្នែកមួយនៃកិច្ចសម្ភាសន៍នេះ សូមដកស្រង់៖ "សួរ៖ អ្វីដែលខ្ញុំចង់សួរលោកនៅពេលនោះ គឺសួរអំពីអ្នកណាម្នាក់ដែលត្រូវបានចោទប្រកាន់ថាជាភ្នាក់ងារ សេ.អ៊ី.អា ឬក៏ ភ្នាក់ងារយួន។ ខ្ញុំចង់សួរថា តើមានអ្នកណាម្នាក់ត្រូវបានចោទប្រកាន់ថាជាភ្នាក់ងារយួន ដើម្បីសម្លាប់ចោល <ដើម្បី>សម្លាប់អ្នក<ស្នេហាជាតិពិតប្រាកដ>ចោល។<> តើមានទេក្នុង<>ចំណោមកម្មាភិបាលថ្នាក់លើ? ខៀវ សំផន ឆ្លើយ៖ បាទ មានគឺមានកម្មាភិបាលនៅភូមិភាគបស្ចិម ត្រូវបានចោទប្រកាន់ថាជាភ្នាក់ងារយួន ពួកគេត្រូវទទួលខុសត្រូវលើបញ្ហានេះ <គេបានចោទប្រកាន់គាត់។> ក៏ប៉ុន្តែពួកគេមិនអាចធ្វើអ្វីបានជោគជ័យទេ <ដោយសារ>យើងធ្វើការស៊ើបសួរបានទាន់ពេលវេលា។" បញ្ចប់ការដកស្រង់។

ហើយនៅក្នុងអត្ថបទមួយដែល ស្ទីវ ហេដឌ័រ គាត់បានសរសេរគឺ <E3/3169>, ខ្មែរ <00711413>, អង់គ្លេស 00002771, បារាំង 00722090។ ស្ទីវ ហេដឌ័រ បានសរសេរដូចតទៅ សូមដកស្រង់៖ "<នេះជាភស្តុតាងមិនច្បាស់ ចំពោះ>ការស៊ើបអង្កេត<ដែលគាត់បានដឹកនាំ>នៅក្នុងខែសីហា ១៩៧៧ នៅភូមិភាគបស្ចិម ហើយ ប៉ុល ពត បានដោះស្រាយបញ្ហាសម្លាប់ សម្រេចសម្លាប់ ជូ ជេត លេខាភូមិភាគ ប៉ុន្តែមិនសម្លាប់អនុលេខាភូមិភាគឈ្មោះ ហេង ផល ទេ។" បញ្ចប់ការដកស្រង់។ លោកបាននិយាយថា លោកបាននិយាយជាមួយ ប៉ង់ <អំពី ខៀវ សំផន ដែលថាគាត់>បានចូលរួមនៅក្នុងអង្គប្រជុំមួយ។ តើលោកមានបានឮថា ខៀវ សំផន នេះបានចូលរួមក្នុងការស៊ើបសួរ ដើម្បីឈានទៅដល់ការចាប់ខ្លួនកម្មាភិបាល ឬក៏លេខាភូមិភាគបស្ចិមទេ?

[០៩:១៤:៤៥]

**ឆ៖** ដំបូងខ្ញុំសូមអនុញ្ញាតបញ្ជាក់ឈ្មោះបន្តិច អនុលេខាភូមិភាគបស្ចិមមិនមែនឈ្មោះ ហេង ផល ទេ ហេង ប៉ាល់ – ហេង ប៉ាល់។ គាត់ហ្នឹងឈ្មោះដើម ហួត ហេង។ បងហែម ចូលចិត្ត បងប៉ាល់នេះថា ហេង ប៉ាល់។ ឯចំណែក ខ្ញុំសូមបញ្ជាក់ឡើងវិញរឿងដដែលពីរឿង មិត្តប៉ង់។ មិត្តប៉ង់ អង្គាល់ដែលខ្ញុំសួរគាត់ពីរឿង បងហែម ពីរឿង បងស៊ុ នេះ គឺសួរក្នុងឋានៈគាត់ជាថ្នាក់លើរបស់ខ្ញុំ ដែលចុះទៅទាក់ទងនឹងខ្ញុំដែលជាប្រធាន ស-២១ ខ្ញុំសួរថា៖ "អង្គាល់ដែលអចិន្ត្រៃយ៍ប្រជុំសម្រេចចិត្តចាប់ខ្លួន បងស៊ុ តើ បងវន ចូលរួមទេ? បងវន មានមតិយ៉ាងម៉េច?" នេះ ខ្ញុំសួរអ៊ីចឹង។ សូមបញ្ជាក់ថែមបន្តិចដោយ

01311897



ឡែក មិត្តប៉ង់នេះ មិនមានសិទ្ធិអីទៅរួមប្រជុំជាមួយនឹងគេ ៨៧០ នោះទេ តែគាត់ជាមនុស្សដែលនៅក្នុងនោះ សម្រាប់អញ្ជើញអ្នកនេះឲ្យទៅប្រជុំ អញ្ជើញអ្នកនោះឲ្យទៅប្រជុំ តាមបញ្ជារបស់ បងប៉ុល។ បានជាបងប៉ង់ –មិត្តប៉ង់– ឆ្លើយប្រាប់ខ្ញុំថា៖ "ថ្ងៃណោះ បងវននៅដែរ តែបងប៉ុលអត់ចាត់តាំងគាត់ឲ្យទៅអញ្ជើញទេ បែរជាចាត់តាំងឲ្យទៅអញ្ជើញ បងហែម ឲ្យចូលរួមប្រជុំ"។ ដូច្នេះ ខ្ញុំបញ្ជាក់នេះ ដើម្បីបញ្ជាក់ថា ប៉ង់ អត់មានចូលទៅរួមប្រជុំនឹងគេទេ ក៏ប៉ុន្តែជាអ្នករត់ការតាមបញ្ជារបស់ បងប៉ុល អញ្ជើញអ្នកណាប្រជុំក្នុងពេលហ្នឹង អាហ្នឹងប៉ុណ្ណឹង។ ឯចំណែកចម្លើយរបស់ ប៉ង់ គឺឆ្លើយជាមួយនឹងពាក្យខ្ញុំដែលខ្ញុំសង្ស័យ។ ខ្ញុំសង្ស័យថា ការណ៍ដែលចាប់ បងស៊ី នេះដោយសារសម្ភប់របស់ បងម៉ុក ទៅលើបងស៊ី បានជាខ្ញុំសួរយ៉ាងនេះ។ ហើយដល់ចម្លើយ មិត្តប៉ង់ មកវិញថាអត់ទេ បងវន អត់បានចូលរួមទេ ព្រោះខ្ញុំជឿទុកចិត្តបងវន ជាងបងម៉ុក ក្នុងការវិនិច្ឆ័យទៅលើ បងស៊ី។ ដូច្នេះ រឿងវាច្បាស់អ៊ីចឹង ដំណើរការ។ ដូច្នេះ ខ្ញុំអាល័យតែនិយាយហួរហែពីរឿងនេះ ខ្ញុំភ្លេចសំណួរព្រះរាជអាជ្ញាមួយកំណាត់បាត់ទៅហើយ។ សូមមេត្តាសួរបញ្ជាក់ម្តងទៀតចុះ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចង់សួរបញ្ជាក់អ្វីដែលលោកបានឆ្លើយមកថា បងហែម គឺបានហៅឈ្មោះ ប៉ាល់ នេះ ចំឈ្មោះតែម្តង។ តើលោកដឹងថាម៉េចបានៗដឹងថា ខៀវ សំផន នេះគឺគាត់បានហៅ ឬក៏ថានិយាយចំឈ្មោះ ប៉ាល់ នេះតែម្តង?

**ឆ៖** រឿងនេះ ខ្ញុំដឹងក្រោយទេ ក្រោយមកទេ។ ហេង ប៉ាល់ ហ្នឹងគឺខ្ញុំដឹងក្រោយមកទេ។

[០៩:១៨:៣២]

**ស៖** ខ្ញុំសូមសួរលោកពីចំណុចមួយផ្សេងទៀត គឺជាសក្ខីកម្មរបស់ ខៀវ សំផន នៅពេលដែលគាត់ឆ្លើយជូនសហចៅក្រមស៊ើបអង្កេត។ គាត់បានបដិសេធថាមិនបានដឹងអំពីការចាប់ខ្លួនណាមួយទេនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គាត់ទើបតែបានដឹងក្រោយឆ្នាំ១៩៧៩ ទេ ថាមានការចាប់ខ្លួនមនុស្ស។ ខ្ញុំសូមអានសម្រង់នៃកិច្ចសម្ភាសន៍របស់គាត់នៅព្រឹកថ្ងៃទី១៤ ធ្នូ <២០០៧> គឺ ឯកសារ E3/37, ខ្មែរ 00156675, អង់គ្លេស 00156753, បារាំង 00156680។ នៅកិច្ចសម្ភាសន៍របស់គាត់នេះ ខៀវ សំផន បាននិយាយអំពីទំនាក់ទំនងរបស់គាត់ជាមួយ សឿ វ៉ាស៊ី ហៅ ឌឿន ហើយថា តើអ្នកទាំងពីរនេះធ្វើការនៅក្នុងគណៈកម្មាធិការពាក់ព័ន្ធទៅនឹងមន្ទីរ៨៧០ ឬក៏ថា<ជាគណៈ>នយោបាយ<>។ <នេះជាអ្វីដែលគាត់បាននិយាយ> នៅពេលដែលសួរពាក់ព័ន្ធទៅនឹងការចាប់ខ្លួន សឿ វ៉ាស៊ី សូមដកស្រង់៖ "គាត់ត្រូវបានចាប់នៅក្នុងឆ្នាំ១៩៧៧ ប៉ុន្តែខ្ញុំដឹងអំពីការពិតនេះ ក្រោយខ្មែរក្រហមដួលរលំទៅទេ

គឺក្រោយឆ្នាំ១៩៧៩។ ខ្ញុំមិនមានការភ្ញាក់ផ្អើលចំពោះអវត្តមានរបស់គាត់ទេ ដោយសារតែយើងម្នាក់ៗត្រូវផ្តោតលើការងាររបស់ខ្លួនផ្ទាល់។ គាត់ធ្វើដំណើរច្រើនកន្លែងណាស់ មិនមានអ្នកណាដឹងថាគាត់ទៅណាទេ លើកលែងតែសមាជិកគណៈអចិន្ត្រៃយ៍ទើបដឹង។" បញ្ចប់ការដកស្រង់។

ខ្ញុំសួរលោក ថាតើលោកយល់យ៉ាងដូចម្តេចលោកសាក្សី ជាពិសេស តើគេដឹងឮគ្រប់គ្នាទេ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមេដឹកនាំលេចធ្លោមួយចំនួន ដូចជា កុយ ធួន, ចក្រី, ឌឿន និងអ្នកដទៃទៀត ត្រូវបានគេបោសសម្អាត។ តើគេដឹងរឿងនេះទូលំទូលាយទេ?

[០៩:២១:០០]

**ប្រធានអង្គជំនុំ៖**

សាក្សី កុំអាលទាន់ឆ្លើយតប! អញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះការតាំងសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិ ទាក់ទងនឹងការស្នើសុំឲ្យសាក្សីផ្តល់យោបល់។ សួរថា តើយល់យ៉ាងដូចម្តេចចំពោះអង្គហេតុដែលសហព្រះរាជអាជ្ញារងបានបង្ហាញជូនសាក្សីអម្បាញ់មិញនេះ។ ដូច្នេះការណ៍ដែលឲ្យសាក្សីវាយតម្លៃទៅលើការសន្និដ្ឋានទៅលើអង្គហេតុណាមួយនេះ វាមិនបានផ្តល់នូវការស្វែងរកការពិតនៃរឿងក្តីទេ។ ដូច្នេះខ្ញុំសូមជំទាស់។ បាទ សូមអរគុណ។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមឆ្លើយតបសង្ខេបទេ។ សំណួររបស់ខ្ញុំសួរ គឺជាសំណួរជាក់លាក់ ថាតើគេដឹងឮគ្រប់ៗគ្នានេះ ដែលមនុស្សដូចជា ឌឿន, កុយ ធួន និងអ្នកដទៃទៀតត្រូវបានគេចាប់ខ្លួននេះ។ សំណួរនេះ ជាសំណួរមួយជាក់លាក់ណាស់ សម្រាប់ការដឹងរបស់គាត់ ឬក៏មិនដឹងនោះ។

**ប្រធានអង្គជំនុំ៖**

បាទ សំណួរនេះអាចជាសួរបាន សាក្សីអាចឆ្លើយបាន ប៉ុន្តែគ្រាន់តែភាគី កាលកន្លងមក យើងបានសម្របសម្រួលនូវការប្រើប្រាស់ពាក្យ។ ពាក្យមួយគឺយើងប្រើ គឺប្រតិកម្ម។ យើងប្រើពាក្យ"ប្រតិកម្ម" ជាជាងយើងប្រើថា ឲ្យសាក្សីយល់ឃើញថាម៉េច។ ពាក្យថា "យល់ឃើញថាម៉េច" អត្ថន័យរបស់វាបង្កប់ទៅដោយការយល់ដឹងអំពីអត្តនោម័តិរបស់ខ្លួនលើអង្គហេតុដែលពាក់ព័ន្ធនឹងសំណួរ។ ហើយបើយើងឲ្យគាត់ប្រតិកម្មទៅលើអ្វីដែលវាជាការសង្កេត ការបង្ហាញអង្គហេតុនោះ វាជាការសមស្រប។

អ៊ីចឹង គឺការប្រើពាក្យពេចន៍ គប្បីមានការប្រុងប្រយ័ត្នដែរ វាជៀសវាងឲ្យដំណើរការប្រព្រឹត្តទៅវាមានការរអាក់រអួល មានការតវ៉ាដូច្នេះ។

សាក្សី ឆ្លើយតបនឹងសំណួរនេះ ប្រសិនបើលោកចាំនូវសំណួរ ដែលសហព្រះរាជអាជ្ញារងអន្តរជាតិបានសួរលោកចុងក្រោយអម្បាញ់មិញនេះ។

[០៩:២៣:២១]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** សូមគោរពលោកប្រធាន។ សូមបញ្ជាក់ថា មនុស្សល្បីខ្លះដែលចាប់មកស-២១ វាមានពីរបែប។ មួយបែប ចាប់មក ហើយទុក។ សូម្បីតែនៅក្នុងស-២១ ក៏មិនងាយអ្នកណាដឹង ក៏ប៉ុន្តែត្រូវតែគេដឹង។ ឯចំណែកមនុស្សដូច កុយ ធួន ក្រោយពីចាប់មកនោះ កុយ ធួន ឆ្លើយហើយ ថ្ងៃមួយនោះ បងប៉ុលប្រើឲ្យ បងខៀវ –សុន សេន– នេះ ទៅបើកការផ្សព្វផ្សាយចម្លើយសារភាពរបស់ ប៉ាង មើល៍ការសារភាពរបស់ ប៉ាង, របស់ កុយ ធួន, របស់ យ៉ា។ បើកនៅស្ពាតហ្លួង នៅបុរី នៃ!កន្លែងលេង*បាសស្កេត* តារាង*បាសស្កេត*។ ខ្ញុំអត់សុំច្បាប់ មិនបានចូលរួមទេ មែន។ ប៉ុន្តែការប្រជុំហ្នឹង គឺគោលបំណងផ្សព្វផ្សាយទូលាយបញ្ហាហ្នឹង។ ហើយជាក់ស្តែង ក៏ក្រោយមកទៀត បងប៉ុល ក្នុងពិធីបុណ្យ១៧ មេសា ១៩៧៧ គាត់និយាយពីរឿងការចាប់ចង បងយ៉ា ហើយនិង បងឃួន។ គាត់និយាយថា "អាយ៉ា វាជាបុគ្គលទី១០ នៅក្នុងបក្ស។ ដូច្នេះក្រោមទង់បក្ស អាយ៉ា វានៅក្រោម អាឃួន។ ក៏ប៉ុន្តែអត់នៅក្នុងក្រោមទង់ សេ.អ៊ី.អា អាឃួន វាក្រោម អាយ៉ា"។ នេះសរុបតាមចម្លើយដែលចេញពី ស-២១។ ខាងផ្នែកសេ.អ៊ី.អានេះ បងយ៉ា កិន បងឃួន ថាធ្វើអ៊ីចេះៗ ណែនាំ បងឃួន ស្តីឲ្យ បងឃួន។ ឯចំណែកខាងបក្ស បងឃួន គាត់លេខ៩ បុគ្គលទី៩។ ដូច្នេះរឿងនេះ វាផ្សព្វផ្សាយទូលាយអ៊ីចឹង អ្នកណាមិនដឹង? នៅក្នុងជួរយុទ្ធជន នៅក្នុងជួរកម្មាភិបាល ដឹង។ មនុស្សសំខាន់ គេសម្ងាត់បានតែមួយរយៈទេ  នេះនៅក្នុងស-២១។ ឯចំណែកនៅខាងក្រៅ មិនមែននេះទេ សូម្បីតែបក្សដក បង កុយ ធួន ចេញដោយសារគាត់ទៅធ្វើឃាតកម្មលើប្តីគេ ពេលដែលគាត់ទៅខូចជាមួយប្រពន្ធគេនោះ មិត្តឡុង នោះ បក្សដក បងឃួន ចេញមិនឲ្យកាន់កិច្ចការពាណិជ្ជកម្មទៀត វាល្បីទៅដល់ស-២១។ គេដកគាត់ដូច នៅខែ៤ ១៩៧៦។ ខ្ញុំចាំកាលបរិច្ឆេទអត់ច្បាស់ទេ។ វាល្បី អាស-២១ ហ្នឹងវាមានសូវដឹងរឿងអីនុ៎ង។ ក៏ប៉ុន្តែវាល្បីដល់អ៊ីចឹង។ វាទៅក្រៅផ្លូវការអ៊ីចឹង។ រួចដល់ក្រោយមក ឌឿន –សឿ វ៉ាស៊ី ហៅ ឌឿន– នេះសុំចេញពីមន្ទីរមជ្ឈិមទៅធ្វើជាកុងសីក្រសួងពាណិជ្ជកម្មម្តងបន្តពី បងឃួន។ នេះរឿង ទាំងអស់នេះទៅអ៊ីចឹង។ រួចដល់

និយាយថា មិនដឹងមិនឮអីសោះ អ៊ូ! ភរជាគ្នាតែម្តង។ ដល់ ៧៩ បានដឹង ជាភាសាមួយដែលមិនក្លាហាន ប្រឈមមុខយើងជាអ្នកបដិវត្តន៍ យើងធ្វើការដើម្បីបម្រើប្រជាជន បើយើងខុសត្រូវតែសុំទោសប្រជាជនវិញដោយសុភាពរាបសា។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។

[០៩:២៧:២៨]

**ស៖** ពាក់ព័ន្ធទៅនឹងចម្លើយសារភាពដែលអាននៅក្នុងអង្គមីទ្ទិងនោះ ខ្ញុំសូមសួរលោក ចេញពីសៀវភៅ ដេវីដ ឆេនឌ័ល័រ គឺមានចំណងជើងថា “សំឡេងពីស-២១” គឺឯកសារ E3/1684 – E3/1684 ខ្មែរ 00192046, អង់គ្លេស 00192873 គឺនៅត្រង់លេខយោងជើងទំព័រ៤៧ នៅលេខយោងជើងទំព័រនេះ គឺមិនមានការបកប្រែជាភាសាបារាំងទេ។ នេះគឺជាអ្វីដែល ដេវីដ ឆេនឌ័ល័រ សរសេរ។ សូមដកស្រង់៖ “ណៃ សារ៉ាន់ ហៅ យ៉ា <--> អតីតកងការពារ<របស់ ណៃ សារ៉ាន់> ត្រូវបានសម្លាសនៅក្នុងឆ្នាំ១៩៩៦ <ដោយសារ សារ៉ា ខំ ក្នុងលក្ខខណ្ឌមិនបញ្ចេញឈ្មោះ គាត់បានរំឭកឡើងវិញ> អំពីស្ថានភាព គាត់នៅចាំថា ខៀវ សំផន បានអានចម្លើយសារភាពរបស់ <សារ៉ាន់ ខ្លាំងៗ> គឺអស់រយៈពេល៣ម៉ោង ឯណោះនៅក្នុងអង្គប្រជុំមួយ<របស់បក្ស>”។ តើលោកធ្លាប់ឮទេថា ខៀវ សំផន បានអានចម្លើយសារភាពពី ស-២១ នៅក្នុងវគ្គអប់រំនយោបាយ លោកធ្លាប់ឮទេ?

[០៩:២៨:៥២]

**ឆ៖** អរគុណ។ ខ្ញុំសូមសម្តែងការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះសេចក្តីសរសេរនេះ។ បើអត្ថបទនេះ ជាអត្ថបទរបស់ ដេវីដ ឆេនឌ័ល័រ ក៏គាត់ប្រើវោហាសាស្ត្រនយោបាយយ៉ាងលំបាកយល់។ ណៃ -- ណើ សារ៉ាន់ នេះមិនមែនជាកងការពារទេ ជាលេខាភូមិភាគឦសាន ហើយ បងហែម មិនដែលចេញទៅបរិហារបញ្ហាអស់ហ្នឹងចំហទេ។ គេជាមនុស្សសម្ងាត់។ បងហែម នៅសម្ងាត់តាំងពីជាតិណាម្ល៉េះ តាំងពីគាត់ចូលទៅក្នុងព្រៃ តាំងពីនៅភ្នំពេញ តាំងពីចូលទៅក្នុងព្រៃ។

**ស៖** សម្រង់នេះ ប្រហែលជាអាចខុសបន្តិច ប៉ុន្តែដាក់ថា “ជាអតីតកងការពាររបស់យ៉ា”។ អតីតគឺកងការពាររបស់ យ៉ា ហ្នឹងបានប្រាប់ថា គាត់នៅក្នុងអង្គប្រជុំរបស់បក្សមួយដែល ខៀវ សំផន បានអានចម្លើយសារភាពរបស់ យ៉ា។ សំណួររបស់ខ្ញុំគ្រាន់តែសួរថា តើលោកធ្លាប់ឮថា ខៀវ សំផន បានអានចម្លើយសារភាពពីស-២១ នៅក្នុងអង្គប្រជុំ<បក្សណាមួយទេ? មិនមែនប្រជុំ>ជាសាធារណៈណាមួយនោះ<ទេ ប៉ុន្តែជាការប្រជុំបក្ស> លោកធ្លាប់ឮទេ?

**ឆ៖** ខ្ញុំមិនដែលឮទេ – ខ្ញុំមិនដែលឮទេ ហើយខ្ញុំក៏មិនចង់និយាយអំពីរបៀបរបបសរសេររបស់

ដុកទ័រ ដេវីដ ឆេនដ័ល័រ ដែរ – សាស្ត្រាចារ្យអ្នកជំនាញការ ដេវីដ ឆេនដ័ល័រ ដែរ។

**ស៖** ហើយនៅក្នុងប្រធានបទដដែលនេះ <ការប្រកាស>នៅក្នុងជួរបក្ស គឺនិយាយអំពីការចាប់ខ្លួនកម្មាភិបាលមួយចំនួន។ ខ្ញុំសូមអានសម្រង់មួយចុះ<ខែឧសភា ដល់>មិថុនា <> ឆ្នាំ<៧៨ ដែលជាទង់បដិវត្ត> គឺឯកសារE3/727, ខ្មែរ <00064566>, អង់គ្លេស 00185333, បារាំង 00524460។ ចម្លើយនេះគឺថាបានយកមកសរសេរនៅក្នុងឯកសារទង់បដិវត្ត សូមដកស្រង់៖ “អាក្បត់ ចក្រី, ឈូក, អាធុច, <អាឌឿន, អាភឹម,> អាស៊ី, អាកែវ មាស និង អាជ័យ ទាំងអស់នេះ គឺជា សេ.អ៊ី.អា ហើយពួកគេខ្លះគឺនៅខាងអាមេរិកាំង ឯពួកគេខ្លះទៀតនៅខាងយួន”។ សូមបញ្ចប់ការដកស្រង់។

លោកសាក្សី លោកនៅចាំថាមានការពិភាក្សាគ្នាអំពីការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ដែលលើកមកសរសេរនៅក្នុងឯកសារទង់បដិវត្ត ហើយមានឈ្មោះដែលខ្ញុំអានអម្បាញ់មិញនេះ លើកលែងតែ សោ ភឹម មាន ចក្រី, ឈូក, កុយ ធួន ហៅធុច, ឌឿន, ស៊ី, កែវ មាស។ តើកម្មាភិបាលទាំងអស់ ជាន់ខ្ពស់ទាំងអស់នេះត្រូវបានចាប់ខ្លួនបញ្ជូនទៅស-២១ ហើយសម្លាប់ចោលនៅស-២១ ហ្នឹងឬក៏យ៉ាងណា?

**ឆ៖** អរគុណ។ ទី១ ខ្ញុំសូមនិយាយអំពី រាប់ឈ្មោះដូចតទៅ៖ ចក្រី ពិតជាបញ្ជូនទៅដល់ស-២១មែន។ បងឈូក ពិតជាបញ្ជូនទៅដល់ស-២១មែន។ បងធុច គឺបង កុយ ធួន នេះពិតជាបញ្ជូនទៅដល់ស-២១មែន។ មិត្តឌឿន ពិតជាបញ្ជូនទៅដល់ស-២១មែន។ មួយទៀត ខ្ញុំមើលឈ្មោះមិនដាច់។ បងស៊ីពិតជាបញ្ជូនទៅដល់ស-២១មែន។ បងកែវ មាស ពិតជាបញ្ជូនទៅដល់ស-២១មែន។ បងជ័យ ពិតជាបញ្ជូនទៅដល់ស-២១មែន។ មួយទៀត ដូច ភឹម –បងភឹម– អត់ទេ អត់ទៅដល់ស-២១ ទេ។

[០៩:៣៤:១១]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំលើកមកសួរលោកអំពីអ្វីដែលលោកបានលើកឡើងពីម្សិលមិញ គឺអង្គប្រជុំមួយដែលលោកបានចូលរួម ដែលដឹកនាំដោយ ខៀវ សំផន នៅដើមខែមករា ឆ្នាំ១៩៧៩ លោកបានជម្រាបជូនអង្គជំនុំជម្រះខ្លះៗដែរពីម្សិលមិញ។ តើនៅក្នុងកិច្ចប្រជុំមួយដែលដឹកនាំដោយ ខៀវ សំផន នេះមានមនុស្សប៉ុន្មាននាក់ដែរមានវត្តមាននៅពេលនោះ?

**ឆ៖** អរគុណ។ មនុស្សប៉ុន្មាននាក់ខ្ញុំអត់ចាំទេ ក៏ប៉ុន្តែខ្ញុំស្គាល់មែនទែនគឺមិត្ត វឿង ប្រធានក្រសួងឃ្លាំងរដ្ឋ ដែលទាញកៅអីឲ្យខ្ញុំអង្គុយ។ ឯចំណែកមនុស្សផ្សេងទៀត ខ្ញុំមិនស្គាល់មុខ ក៏ប៉ុន្តែខ្ញុំសូមជូនជាការសង្កេត អង្គប្រជុំនោះ គឺថ្ងៃ០៦ មករា ១៩៧៩ មុនយួនមកដល់ភ្នំពេញ២៤ម៉ោង យើងគិតថាម្ភៃ -- ៣០ម៉ោងទៅចុះ មិនដល់ទេ ២៧ម៉ោង។ ពេលនុ៎ង គេទូរស័ព្ទហៅខ្ញុំ មិត្តលីន ទូរស័ព្ទហៅខ្ញុំឲ្យ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៅធ្វើការជាមួយនឹងបង។ ខ្ញុំស្មានតែទៅធ្វើការជាមួយ ពូនួន ព្រោះខ្ញុំមិនដែលបានទៅធ្វើការជាមួយ បងហែម ទេ។ ដល់ទៅ ឃើញ បងហែម នៅខាងក្រៅជាមួយនឹងជុំគ្នាគេប៉ុន្មាននាក់រួចទៅហើយ។ មិត្តលីន រុញស្មាខ្ញុំទៅ។ ខ្ញុំរារែក។ ដល់ មិត្តលីន រុញស្មាខ្ញុំទៅ ខ្ញុំថា អ្ហ៎! មិត្តលីន គេមិនធ្វើផ្តេសផ្តាស ដោយគ្មានបញ្ជារបស់ បងប៉ុល ទេ។ ខ្ញុំក៏សុខចិត្តទៅ។ ដល់ទៅ មិត្តរឿង គេរុញកៅអីឲ្យខ្ញុំអង្គុយ។ ដូច្នេះឈ្មោះប៉ុន្មាននាក់នោះ ខ្ញុំអត់ដែលឃើញ អត់ស្គាល់ទេ ទាំងអស់មិនដល់ជា ប្រហែលជាប្រាំមួយ ប្រាំពីរនាក់។

ខ្ញុំសូមបញ្ជាក់ថា ជូនជាការបញ្ជាក់ ជូនការរំឭកឡើងវិញ ជូនជាការសង្កេត។ នៅពេលនោះ បង ចេង អន ក៏គេចាប់។ បងហុក ខាងថាមពលក៏គេចាប់ ហើយមិនដឹងអ្នកណាទៀតទេ ក៏គេចាប់។ លើកលែងតែ បងរត់ -- បងរិទ្ធ គាត់ខាងឃ្លាំងរដ្ឋទេ ដែលគេអត់ -- អ៎! សូមទោស ពាណិជ្ជកម្មរដ្ឋទេ ដែលគេអត់ចាប់ ក៏ប៉ុន្តែថ្ងៃនោះ បងរិទ្ធ អត់មានវត្តមានទេ។ នេះ ខ្ញុំសូមបញ្ជាក់ប៉ុននុំង។

**ស៖** ដូច្នេះ ដើម្បីឲ្យច្បាស់ គឺថាប្រហែលជាមានមនុស្សប្រាំមួយ ប្រាំពីរនាក់នៅក្នុងការប្រជុំអ៊ីចឹង។ អ៊ីចឹងបានន័យថា ការប្រជុំហ្នឹងមិនមានមនុស្សច្រើននាក់ទេ អ៊ីចឹងមែនទេ? តើខ្ញុំនិយាយត្រឹមត្រូវទេ ថាក្នុងការប្រជុំហ្នឹងមានមនុស្សតិចតួចទេ មិនជាច្រើនណាស់ណាទេ?

**ឆ៖** អរគុណ។ ការប្រជុំនេះ ប្រជុំការងារ ផ្សព្វផ្សាយដំណឹង ឲ្យប្រធានអង្គភាពនានានៅក្រោមចំណុះរបស់ប្រធានគណៈកម្មាធិការបក្ស -- អ៎! សូមទោស ប្រធានមន្ទីរ គណៈមន្ទីរជុំវិញមជ្ឈិម។ ដូច្នេះ មិនច្រើនទេ យ៉ាងច្រើនប្រាំពីរ – យ៉ាងច្រើនប្រាំពីរ។

[០៩:៣៨:០៤]

**ស៖** ដូច្នេះ នៅពេលដែលលោកបង្ហាញខ្លួននៅក្នុងការប្រជុំមួយនេះ គឺថាលោកចូលទៅក្នុងបន្ទប់ប្រជុំដែលមានមនុស្សតិចតួចហ្នឹង តើ ខៀវ សំផន មានបានសួរលោក ថាលោកជាអ្នកណាទេ? ហេតុអ្វីបានជាលោកមកប្រជុំទេ? ឬមួយក៏ ខៀវ សំផន គាត់ដឹងច្បាស់ហើយថាលោកជាអ្នកណា? ហេតុអ្វីបានជាលោកមកប្រជុំអ៊ីចឹង?

**ឆ៖** ខ្ញុំមិនឆ្លើយនឹងសំណួរនេះ ដោយចំទេ។ ខ្ញុំនិយាយអំពីការចងចាំរបស់ខ្ញុំ។ ពេលដែលខ្ញុំទៅដល់មាត់ទ្វារ ពុទ្ធិកៈវិទ្យាល័យព្រះសុរាម្រិត មិត្តលីន រុញស្មាខ្ញុំទៅ។ នេះ ខ្ញុំនិយាយឡើងវិញ។ ដល់ទៅខ្ញុំចូលទៅ មិត្តរឿង រុញកៅអី។ បងហែម អត់ទាំងសួរខ្ញុំមួយម៉ាត់ ហើយក៏អត់ទាំងហៅឲ្យខ្ញុំអង្គុយទេ គាត់ធ្វើមុខស្ងៀម។ ដល់ខ្ញុំអង្គុយស្រួលបួលហើយ គាត់ចាប់ផ្តើមឧទ្ទេសនាមបន្ត ពីរឿងសភាពការឃួន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

វាចូលមកជ្រៅហើយ។ ក៏ប៉ុន្តែក៏ភ្ញាក់ផ្អើល។ មិត្តរឿង ហើយនិងមិត្ត -- សូមទោស មិត្តរឿន ហើយនិងមិត្តសាន រ៉ៃទប់ អត់អីទេ។ យើងនៅខំធ្វើការងារតាមធម្មតាទៅ។ នេះខ្លឹមសារដែលត្រូវប្រជុំរាយ-ការណ៍មានតែប៉ុណ្ណឹង។ ខ្ញុំក៏ចេញម៉ូតូមកវិញមក។ ប្រជុំនេះ នៅចំហទូលាយ ធម្មតាការប្រជុំជាមួយបងនួន ក៏ដោយ នៅពុទ្ធិកៈវិទ្យាល័យព្រះសុរាម្រិត គឺនៅជាន់ក្រោម ជាន់ផ្ទាល់ដី អត់មានជញ្ជាំង អត់មានអីទេ។ កងការពារមិនដឹងគេលួចមើល ត្រួតពិនិត្យសុវត្ថិភាពរបស់ដឹកនាំប៉ុន្មាននាក់ពីចម្ងាយទេ។

**ស៖** ដូច្នេះ ដើម្បីបញ្ជាក់ឲ្យបានច្បាស់។ អ៊ីចឹងមានន័យថា នៅពេលដែលលោកមកដល់ការប្រជុំហ្នឹងគឺ ខៀវ សំផន គាត់អត់ភ្ញាក់ផ្អើលអ្វីនោះទេ ហើយគាត់មិនបានសួរលោក ថាលោកជានរណាហេតុអ្វីលោកមកទីនេះទេ អ៊ីចឹង មែនទេ? គឺមានន័យថា គាត់មិននិយាយអ្វីទាំងទាក់ទងនឹងលោក អ៊ីចឹងមែនទេ?

[០៩:៤០:១៩]

**ឆ៖** អរគុណ។ គាត់ធ្វើមុខស្មើធម្មតា។ តែមាត់យ៉ាងម៉េចរកខ្ញុំ ក៏អត់មាត់មួយម៉ាត់ដែរ។ ឃើញខ្ញុំអង្គុយស្រួលបួលហើយ បានគាត់ចាប់ផ្តើលខទ្មេសនាមសភាពការណ៍។ ដូច្នេះ យើងសន្និដ្ឋានយ៉ាងម៉េច ផ្ទាល់ខ្លួនខ្ញុំៗសន្និដ្ឋានថា រឿងនេះគាត់ដឹងខ្ញុំ គាត់ស្គាល់ខ្ញុំហូរហែមកហើយ គ្រាន់តែមិនបានជួបមុខគ្នាប៉ុននុំង។

**ស៖** នៅក្នុងការប្រជុំនេះ តើ ខៀវ សំផន មានបានណែនាំ ឬក៏បញ្ជាអ្វីទៅដល់អ្នកដែលចូលរួមទេ?

**ឆ៖** អរគុណ។ ការណែនាំនេះតែមួយម៉ាត់ទេ។ “អត់អីទេ សភាពការណ៍ កុំភ្ញាក់ផ្អើល ធ្វើការងារតាមធម្មតា” នេះប៉ុននុំង។

**ស៖** នៅក្នុងការប្រជុំ តើគាត់បាននិយាយអ្វីស្ពានភាពកងទ័ព ឬក៏និយាយអំពីអ្វីដែលមេបញ្ជាការកងទ័ពត្រូវធ្វើ ត្រូវអនុវត្តអ្វីដែរឬទេ?

**ឆ៖** គាត់អត់និយាយអីហូរហែវែងពេកទេ។ គាត់និយាយចុះណែនាំសភាពការណ៍តែប៉ុណ្ណឹងច្បាស់ ខ្លី ហើយពេញលេញ “សភាពការណ៍មិនអីទេ មិត្តរឿន និងសាន រ៉ៃទប់ហើយ ដូច្នេះកុំភ្ញាក់ផ្អើលដំណើរការការងារតាមធម្មតា”។ ដូច្នេះវាខ្លី វាច្បាស់ វាចំ វាណែន។

**ស៖** ខ្ញុំដឹងថា មនុស្សពីរនាក់ហ្នឹងជាអ្នកណា ប៉ុន្តែលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ ដើម្បីជាប្រតិចារឹកថា តើសមមិត្តរឿន ហើយ សមមិត្តសាន ហ្នឹង ជានរណាដែរ?

**ឆ៖** អរគុណ។ មិត្តរឿន នេះជាលេខាកងពលមួយ បើតាមខ្ញុំចាំ វាយូរណាស់ហើយ លេខាកងពល៨០១។ ឯចំណែក មិត្តសាន ជាលេខាកងពលមួយផ្សេងទៀត បើតាមខ្ញុំចាំដែរ ព្រោះវាយូរហើយ លេខាកងពល៩២០ ជាកងខ្លាំង។

[០៩:៤៣:១៦]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំបន្តទៅប្រធានបទថ្មីមួយទៀត។ ខ្ញុំនឹងនិយាយអំពីការចាប់ខ្លួនបុគ្គលិកស-២១។ នៅក្នុងកំណត់ត្រាស-២១ បានបង្ហាញពីការចាប់ខ្លួនកម្មាភិបាលស-២១ ឆ្នាំ៧៧ ឆ្នាំ៧៨។ ដូច្នេះខ្ញុំចង់ដឹងថា តើលោកជាអ្នកធ្វើសេចក្ដីសម្រេចចាប់ខ្លួនកម្មាភិបាលទាំងនោះ ឬមួយក៏ថ្នាក់លើរបស់លោកទេ ជាអ្នកសម្រេច?

**ឆ៖** អរគុណ។ រឿងនេះច្បាស់លាស់ណាស់ អ្នកដែលត្រូវចាប់ខ្លួន ភាគច្រើនគឺអតីតមកពីពួកក្រុងភ្នំពេញ គឺអតីតអ្នកតស៊ូនៅក្រុង។ រួចបន្ទាប់មកដែល ដោយសារខាងកងពល៧០៣ ដែលចូលរួមសមាសភាពនុ៎ង ច្រើន គឺពួកហ្នឹងដែលត្រូវចាប់ខ្លួនច្រើន។ ដូច្នេះពួកក្រុងត្រូវចាប់ខ្លួនបណ្ដើរៗចាប់តាំងពី ណាត គាត់នៅធ្វើប្រធាន។ ដល់គាត់ចេញទៅ ដូចជាអស់ នេះបើតាមខ្ញុំចាំ។ កាលនោះ ណាត គាត់រាយការណ៍សុំយោបល់ខាងលើ។ ក្នុងឋានៈគាត់ជាប្រធានស-២១នោះ គាត់រាយការណ៍សុំសេចក្ដីសម្រេចចិត្តពីខាងលើ។ ហើយបន្ទាប់មក ដែលនៅពួកខាង ៧០៣ នេះ បាតុភាពហ្នឹង មិត្តហ៊ី ក៏មករាយការណ៍មកខ្ញុំ ដល់ទៅ ខ្ញុំរាយការណ៍ទៅខាងលើ។ ខាងលើសម្រេចទើបខ្ញុំហ៊ានចាប់ – ខាងលើសម្រេចទើបខ្ញុំហ៊ានចាប់។ ដូចឈ្មោះ ប៉េង ដែលបណ្ដោយប្រហែស ធ្វើឱ្យអាកងលួនទៅយកកាំភ្លើងពួកកងពិសេសបាន ហើយបាញ់កងពិសេសវិញ។ ខាងលើអត់ថាម៉េច ខ្ញុំក៏អត់ហ៊ានដក ហើយមិត្តប៉េង គាត់នៅតែធ្វើការជាប្រធានកងពិសេសតទៅទៀត។ ដូច្នេះ វាអាស្រ័យខាងលើជាអ្នកសម្រេច យើងរាយ-ការណ៍។ ផ្ទុះកាំភ្លើងភ្លាម មិត្តហ៊ី រាយការណ៍មកខ្ញុំ ខ្ញុំចុចទូរស័ព្ទទៅរាយការណ៍ជូនបង សុន សេន។ ដល់យើងបង្ក្រាបអាកងបានហើយ ចប់។ បន្ទាប់មកទៀត មានក្មេងម្នាក់ គាត់ជាវរសេនាធំនៅខាងកងពល៣១០ ពេលដែលចូលទៅដល់អគារមួយនៅខាងមុខស-២១ ហ្នឹង។ អ្នកដែលទៅធ្វើអីជិតហ្នឹង កាន់កាំភ្លើង អឹមសី មួយដើមស្ពាយ។ អារុន វាចាប់បានកាំភ្លើងវាបាញ់កងការពារ។ ផ្ទុះអារុនភ្លាម មិត្តហ៊ីមកដល់កន្លែងខ្ញុំភ្លាម ខ្ញុំរាយការណ៍ទៅខាងលើភ្លាម។ ដល់ក្រោយមក គេបង្ក្រាបបាញ់ អារុន នោះស្លាប់ទៅគាត់ក៏ដឹង គាត់ហើយនិងខ្ញុំឈប់ទូរស័ព្ទ។ ឯចំណែកអ្នកដែលកាន់កាំភ្លើងប្រហែសហ្នឹងក៏គាត់អត់មានដាក់ទោស។ នេះជាឧទាហរណ៍ពីរដែលខាងលើសម្រេច។ ឧទាហរណ៍ពីរនេះជាក់ស្ដែង ដែលខ្ញុំនៅ

ចាំច្បាស់។

[០៩:៤៧:១៤]

**ស៖** លោកបាននិយាយច្រើនក្នុងពេលកន្លងមកអំពីការចាប់ខ្លួន ហ៊ុយ ស្រែ គឺជាប្រធានព្រៃស។ អ្វីដែលខ្ញុំចង់សួរលោកបន្ថែមទៀតគឺថា <នៅពេល>គេចាប់ខ្លួន ហ៊ុយ ស្រែ <>តើប្រពន្ធរបស់ ហ៊ុយ ស្រែ ហ្នឹងត្រូវបានគេចាប់ខ្លួនដែរឬទេ? ហើយមានអ្វីកើតឡើងចំពោះប្រពន្ធគាត់នោះ?

**ឆ៖** អរគុណ។ រឿងមិត្ត ហ៊ុយ ស្រែ នេះវាមានរឿងជាហូរហែមក ដែល មិត្តហ៊ី រាយការណ៍មកឲ្យខ្ញុំ ហើយខ្ញុំរាយការណ៍ទៅខាងលើបណ្ដើរៗ។ ដែល មិត្តហ៊ី គាត់ចាប់អារម្មណ៍សង្ស័យខ្លាំង គឺរឿងអ្នកកាន់តែអ្វ រស់ស-២១ ឯស្រែនោះ វារត់។ ដូច្នេះ កំហុសហ្នឹងវាបន្ថែមលើអាកំហុសចាស់ ធ្វើឲ្យ មិត្តហ៊ី គាត់សង្ស័យកាន់តែខ្លាំង ខ្ញុំរាយការណ៍ទៅខាងលើ។ ដល់ទៅខាងលើឲ្យចាប់ ខាងលើដែលសម្រេចកាលនោះ ពូនួន មិនមែនបង សុន សេន ទេ ពូនួន។ ខ្ញុំក៏ចាប់ជាមួយ មិត្តហ៊ី រៀបចំការចាប់តាមសេចក្ដីសម្រេចរបស់ខាងលើ។

**ស៖** តើថ្នាក់លើដែលលោករាយការណ៍ទៅហ្នឹងគឺជានរណាដែរ គឺជាថ្នាក់លើដែលធ្វើការសម្រេចទៅលើបញ្ហា ហ៊ុយ ស្រែ នោះ?

**ឆ៖** ពូនួនៗ គឺលោក នួន ជា។

**ស៖** ចុះប្រពន្ធ ហ៊ុយស្រែ មិនដឹងថាគាត់មានកូនក៏អត់ទេ ប៉ុន្តែចុះចំពោះប្រពន្ធ ឬក៏កូនរបស់ ហ៊ុយស្រែ ហ្នឹងយ៉ាងម៉េចដែរ នរណាជាអ្នកសម្រេចចាប់?

**ឆ៖** តែកាលណាប្ដីទៅហើយ ស្វ័យប្រវត្តិប្រពន្ធគេចាប់ហើយ។ ដូច្នេះ មិត្តយឿន ក៏គេចាប់ មិនមែនគេទេ ស-២១ចាប់។ កូនហ្នឹងនៅតូច ប្រហែលជាអាយុមិនទាន់ដល់មួយឆ្នាំផង ក៏ស-២១ ចាប់ ព្រោះនេះជាគោលការណ៍កំណត់របស់ខាងលើ។

[០៩:៥០:០៣]

**ស៖** តើប្រពន្ធរបស់ ហ៊ុយស្រែ ឈ្មោះ យឿន ហើយនិងកូនគាត់ហ្នឹងនៅរស់រានមានជីវិតទេ?

**ឆ៖** អរគុណ។ ជាគោលការណ៍ឲ្យតែគេចាប់ហើយ គេអត់ដែលទុកទេ តែគេចាប់គេកម្ទេច។ អ្នកដែលចាប់ហើយមិនកម្ទេចមានតែមួយទេ គឺបង ឌី ផុន ហៅ ធុក។

**ស៖** ដោយសារលោកនិយាយអំពីបញ្ហានេះ ខ្ញុំចង់សួរលោកអំពី ឌី ផុន។ លោកបានបញ្ជាក់ថា ក្រោយពេលដែលគេចាប់ខ្លួនគាត់ហ្នឹង គឺលោកបានទទួលទូរស័ព្ទ ឬក៏ថា នួន ជា ទាក់ទងមកលោក

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ហើយបង្គាប់ឲ្យលោកទុកជីវិតគាត់ដើម្បីឲ្យគាត់ធ្វើជាពេទ្យធ្មេញ។ ដូច្នេះ ខ្ញុំចង់ដឹងថា នួន ជា ធ្វើយ៉ាងម៉េច បានដឹងថា ឌី ផុន ហ្នឹង <ត្រូវ>គេចាប់ខ្លួន<បញ្ជូនមកស-២១>?

**ឆ៖** សូមបញ្ជាក់ថា បង ឌី ផុននេះ បងប៉ុលនេះ បងហែមនេះ គេស្គាល់គ្នាតាំងពីដើមមក។ នោះហើយ ហើយខ្ញុំនិយាយម្សិលមិញដូចជាជ្រុលបន្តិចផង ឋានៈ ឌី ផុន ហើយនិងបងប៉ុលនេះ មិត្តភក្តិគាត់ចូលបក្សពីស្រុកបារាំងជាមួយគ្នា។ ដូច្នេះ គាត់មកនេះ បង ឌី ផុន នៅខាងក្រៅទេ មិនដែលចូលទៅដល់ក្នុងមន្ទីរមជ្ឈិមជាមួយនឹងគេទេ ប៉ុននេះគេស្គាល់គ្នាហើយ។ អង្កាល់មុនឆ្នាំ៧០ រដ្ឋប្រហារក៏បង ឌី ផុន ធ្វើសកម្មភាពច្រើនដែរ។

**ស៖** លោកចាំទេថា ឌី ផុន គាត់មានប្រពន្ធឬក៏អត់? ហើយថាតើប្រពន្ធរបស់ ឌី ផុន ហ្នឹងគាត់មកស-២១ ក្នុងពេលជាមួយគ្នានឹងប្តីរបស់គាត់ដែរ ឬមួយក៏យ៉ាងណា?

**ឆ៖** អរគុណ។ បង ឌី ផុន -- អូនែ! ប្រពន្ធបង ឌី ផុន នេះជាអ្នកគ្រូរបស់ខ្ញុំ កាលខ្ញុំទៅរៀនថ្នាក់គណិតវិទ្យាពិសោធ។ អ្នកគ្រូ តាន់ ប៉ូលីន នេះបង្រៀនវិទ្យាសាស្ត្រធម្មជាតិ។ ពួជគេហ្នឹងជាជនចម្រើន ហើយយើងហៅប្រើពាក្យ “ជនចម្រើន”ហ្នឹង បានន័យថាអ្នកដែលស្រឡាញ់លទ្ធិកុម្មុយនីស្ត ធ្វើសកម្មភាពបម្រើកុម្មុយនីស្ត។ អ្នកគ្រូ តាន់ ប៉ូលីន នេះមានបងមួយសកម្មណាស់ វិស្វករអគ្គីសនីឈ្មោះតាន់ នុប -- តាន់ ណុក។ ដូច្នេះ ពេលដែលបង ឌី ផុន រត់ទៅព្រៃក្នុងឆ្នាំ ៧០ អ្នកគ្រូ តាន់ ប៉ូលីន នៅភ្នំពេញទេ មិនព្រមមកព្រៃជាមួយនឹងបង ឌី ផុន ទេ។ ក្រោយមកបង ឌី ផុន ក៏យកប្រពន្ធមួយទៀតទៅយកស្រីមេម៉ាយម្នាក់។ ដូច្នេះ អ្នកគ្រូ តាន់ ប៉ូលីន ទៅស្រុកបារាំង។ ហ្នឹងហើយដែលខ្ញុំនិយាយថា ខ្ញុំរង់ចាំមើល អ្នកគ្រូ តាន់ ប៉ូលីន ហើយនិង*ម៉ាដាម* ចៅ សេង មកខ្ញុំនឹងឱនកាយថ្វាយបង្គំសុំទោសស្រីៗពីរនាក់ហ្នឹង ដែលខ្ញុំការពារអាយុជីវិតអ្នកដែលជាទីស្នេហាមិនបាន។

[០៩:៥៤:១៨]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញនូវបញ្ជីស-២១ គឺឯកសារ E3/2175 សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ផងដែរ។ បញ្ជីដែលខ្ញុំប្រគល់ជូនលោក សាក្សីនេះ គឺជាបញ្ជីអ្នកទោសមកពីក្រសួងសង្គមកិច្ច។ សូមលោកមើលលេខ៦នៅក្នុងបញ្ជី។ លោកនឹងឃើញឈ្មោះ ឌី ផុន ហៅ ផុក ខ្ញុំមិនដឹង ខ្ញុំអានឈ្មោះហ្នឹង ត្រូវ ឬខុសទេ គឺ<គណៈបច្ចេកទេស>មកពីសង្គមកិច្ច។ ចូលនៅថ្ងៃ១០ ខែធ្នូ ឆ្នាំ៧៨។ ថាតើ ឌី ផុន ហ្នឹង គឺជា ឌី ផុន ទន្តបណ្ឌិតដែលយើងកំពុងតែពិភាក្សាគ្នាហ្នឹងមែនទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ គឺពិតហើយ គឺពិតជាបង ឌី ផុន ដែលយើងទើបនឹងពិភាក្សាគ្នាហើយនេះ។

**ស៖** ប្រសិនបើលោកមើលចុះក្រោមបន្តិច គឺលេខ២៥ នៅក្នុងបញ្ជី គឺជានារីម្នាក់ឈ្មោះ អ៊ឹង ហ្វូន ហៅ វ៉ាន ហើយអាយុ៣៦ឆ្នាំដែលគេហៅ ដែលគេបញ្ជាក់ថា ប្រពន្ធ អាផុក គឺចូលក្នុងថ្ងៃជាមួយគ្នានឹង ឌី ផុន។ តើគាត់ហ្នឹង ជាប្រពន្ធទី២របស់លោក ឌី ផុន មែនទេ ទៅតាមដែលលោកចាំ?

**ឆ៖** អរគុណ។ មិត្តវ៉ាន់ នេះ ពិតជាប្រពន្ធចុងរបស់បង ឌី ផុន ហើយ ប្រពន្ធទី២របស់បង ឌី ផុន ហើយ។

**ស៖** នៅពេលដែល នួន ជា ទាក់ទងមកលោក ហើយប្រាប់លោកឲ្យទុកជីវិតទន្តបណ្ឌិត ឌី ផុន ហ្នឹង តើគាត់មានបញ្ជាលោកឲ្យទុកជីវិតប្រពន្ធរបស់គាត់ដែរឬទេ ឬមួយក៏ប្រពន្ធរបស់គាត់ត្រូវបានគេសម្លាប់ដែរ?

[០៩:៥៧:១០]

**ឆ៖** អរគុណ។ ពេលនោះ បងនួន ហៅខ្ញុំទៅធ្វើការ ហើយគាត់ទាមទារឲ្យខ្ញុំទុកបង ឌី ផុន ឲ្យនៅរស់។ ហើយឃើញខ្ញុំត្រេះត្រុះបន្តិច គាត់ថា "មិត្ត ធ្មេញមិត្តអន់ណាស់ណា លែងទៅ ទុកឲ្យគេធ្វើធ្មេញឲ្យ"។ ខ្ញុំឯណាទៅហ៊ានប្រកែកនឹងបទបញ្ជារបស់ ប៉ុល ពត ប៉ុន្តែគ្រាន់តែសុំពេល១ដកដង្ហើមប៉ុណ្ណឹង។ ដល់មកដល់ ខ្ញុំបញ្ជាឲ្យលែងបង ឌី ផុន ភ្លាម។ ឯចំណែកមិត្ត វ៉ាន់ ខ្ញុំអត់ឮ បងនួន គាត់ណែនាំយ៉ាងម៉េច ហើយខ្ញុំក៏មិនដឹងជា មិត្តវ៉ាន់ ទៅដល់ណ្ហុងផង ទើបនឹងឃើញនេះឯង។ ដូច្នេះ មិត្តវ៉ាន់ ទៅបាត់ហើយ។ គេកម្ទេចចោលបាត់ទៅហើយ។ ហើយកូន មិត្តវ៉ាន់ តាំងពីប្ដីមុនម្ល៉េះ ជាមួយ បងហង្ស ក៏មិនដឹងជាទៅណា។

**លោក ខេល លីសាក់៖**

សូមអរគុណ។ ឥឡូវនេះ យើងត្រឡប់ទៅនិយាយអំពីការចាប់ខ្លួនកម្មាភិបាលស-២១។ ខ្ញុំបានសួរលោករួចមកហើយ អំពី ហ៊ុយស្រែ ហើយយើងបាននិយាយអំពីប្រពន្ធកូនរបស់គាត់។ ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ផ្តល់ឯកសារ E3/3694។ គឺជាកំណត់ត្រាមួយដែលសរសេរដោយៗសាក្សី គឺនៅលើចម្លើយសារភាពមួយចំនួន។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ផ្តល់ឯកសារនេះដល់សាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[០៩:៥៩:១៤]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ឯកសារដែលខ្ញុំប្រគល់ជូនលោក គឺ E3/3694 គឺជាទំព័រដើមនៃចម្លើយសារភាពរបស់មនុស្សឈ្មោះ វង់ សំអាត ហៅ វង់ អឿន ដែលថាជាយុទ្ធជនសួរចម្លើយនៅស-២១។ ហើយមានកំណត់ត្រាសរសេរដៃមួយ ដែលនៅក្នុងទំព័រដែលសរសេរក្រហម សូមអនុញ្ញាតបង្ហាញនៅក្នុងអេក្រង់។ ប្រសិនបើលោកមើលមិនច្បាស់ទេ ខ្ញុំនឹងផ្តល់ឯកសារដែលពង្រីកឲ្យធំ ប្រហែលជា ប្រសិនបើលោកមើលឯកសារនេះមិនច្បាស់ ខ្ញុំនឹងផ្តល់នូវឯកសារដែលយើងពង្រីកឲ្យធំ។ នេះគឺអ្វីដែលគាត់បានបញ្ជាក់នៅក្នុងបញ្ជីនេះ សូមលោកមើល គឺបានបញ្ជាក់ថា “ជូនបងជាទីគោរព, អាចង្រៃមួយនេះវាធ្វើសកម្ម-ភាពនៅក្នុងស-២១ ខុសពីអាពីរនាក់មុន វាធ្វើតែជាមួយក្រុមរបស់វា ដែលជាអ្នកសួរចម្លើយ និងជាសន្តិសុខនៅក្នុងមន្ទីរ ស-២១, ដោយ ឌុច, ចុះថ្ងៃទី២០--”។ ដូច្នេះ ចង់ដឹងថាតើគឺ ថាតើ អ្នកណាដែលលោកផ្ញើទៅ ហៅថា “បងជាទីគោរព”? គឺលិខិតចុះថ្ងៃ២៦ មីនា ៧៨នោះ។

**ឆ៖** អរគុណ។ ខែមីនា ក្រោយ -- ខែមីនា ៧៨ ក្រោយថ្ងៃ១៥ សីហា ៧៧។ ដូច្នេះ ខ្ញុំបែកពីបង សុន សេន ចាប់តាំងពីថ្ងៃ១៥ សីហា ៧៧។ បងជាទីគោរពនេះ គឺពិតជាសំដៅ បងនួន។

[១០:០១:៤៤]

**ស៖** តើលោកមានបានទទួលការបញ្ជាណាមួយពី បងនួន ទាក់ទងទៅនឹងលិខិតរបស់លោកនិយាយអំពីសន្តិសុខនៅ ស-២១ ដែលត្រូវបានគេឆ្លើយដាក់នេះទេ?

**ឆ៖** អរគុណ។ ធម្មតាទេ ការចាប់ខ្លួនបុគ្គលិកនៅក្នុងស-២១ គឺយើងខ្ញុំរាយការណ៍ទៅលើ ខាង

លើជាអ្នកសម្រេចឲ្យចាប់ ហើយនិងកម្ទេច។ តែកាលណាចាប់ហើយ គឺកម្ទេចហើយ។

**ស៖** នៅក្នុងឆ្នាំ៧៨ នៅពេលដែលលោករាយការណ៍ទៅ នួន ជា តើការចាប់ខ្លួនកម្មាភិបាល ស-២១ ត្រូវបានបញ្ជា ឬក៏ត្រូវបានអនុម័តយល់ព្រមពី នួន ជា ដែរឬទេ?

**ឆ៖** អរគុណ។ នៅក្នុងស-២១ក៏ដោយ យើងខ្ញុំមិនដែលហ៊ានអត្តនោម័តិ ចាប់ដោយខ្លួនឯង មិនបានការយល់ស្របអំពី ពូនួន ទេ។ នេះជាគោលការណ៍ដែលយើងខ្ញុំធ្វើការ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារ E3/10376 គឺជាបញ្ជីអ្នកទោសមកពីមន្ទីរ ស-21 គឺក្នុងខែកុម្ភៈ -- កុម្ភៈ-មីនា ឆ្នាំ៧៨។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**លោក ឌេល លីសាក់៖**

**ស៖** សូមលោកពិនិត្យមើលបន្តិចទៅលើឯកសារនេះ គឺជាបញ្ជីអ្នកទោសស-២១ គឺមានមនុស្ស ២២នាក់ ដែលមានឈ្មោះ នៅក្នុងនេះ រួមទាំងអ្នកដែលសារភាព ដែលយើងមើលមុននេះបន្តិច គឺឈ្មោះ វង់ សំអាត។ ដូច្នេះ ខ្ញុំចង់សួរលោក<ជា>ទូទៅអំពីមនុស្សនៅក្នុងបញ្ជីនេះ។ ថាតើ នួន ជា ជាអ្នកបញ្ជាឲ្យចាប់ខ្លួនមនុស្សទាំងអស់នេះ ឬមួយក៏យ៉ាងណា? ហើយលោកចាំទេថា ហេតុអ្វីបានជា មនុស្សដែលមានឈ្មោះនៅក្នុងបញ្ជីហ្នឹងត្រូវបានគេចាប់ខ្លួន?

[១០:០៤:៥៨]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ រឿងនេះវាកន្លងច្រើនឆ្នាំហើយ។ ហើយទី២ ខាងការចាប់ខ្លួន ខាងការអី ពួកខាងនេះ ខាងពួកខាងកងពល៧០៣ ស-២១មែន តែប្រភពមកពី៧០៣ មិត្តហ៊ី គេគិតគូរទាំងអស់ គេរាយការណ៍មកខ្ញុំ ហើយខ្ញុំរាយការណ៍ទៅ។ ដូច្នេះសភាពការណ៍ពេលនោះមិនដឹងជាយ៉ាងម៉េចទេ ឃើញដូចចាប់ជាប់ៗគ្នាតែម្តង។ ឯចំណែកជាគោលការណ៍រួម យើងខ្ញុំមិនដែលរំលងទេ ទាំងខ្ញុំ ទាំងមិត្តហ៊ី មិនដែលហ៊ានរំលងថ្នាក់ដឹកនាំក្នុងរឿងសម្រេចចាប់ទេ។ នេះជាគោលការណ៍របស់បក្ស។ ណាតគាត់មានហ៊ានរំលង ខ្ញុំអត់ដែលហ៊ានទេ។ អ្នកដែលហ៊ានរំលង ពួកមន្ទីរ ប្រធានមន្ទីរនគរបាល សុទ្ធតែអត់រួចខ្លួនទេ ក្រោយមកត្រូវកម្ទេច ជិត២០០ប្រធានមន្ទីរនគរបាលនៅស្រុកខ្មែរ ត្រូវស្លាប់ ឬមួយ

ដោយសារចាប់អត្តនោម័តិ ឬមួយដោយសារសីលធម៌ ឬមួយដោយសារជយភណ្ឌ។ នេះតាមការពិចារណារបស់ខ្ញុំ តាមការពិចារណាទេ ប៉ុន្តែនគរបាល -- ប្រធានមន្ទីរនគរបាលជិត២០០នាក់។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់បញ្ជីមួយទៀតដល់សាក្សី គឺឯកសារE3/9905។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១០:០៦:៥៤]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** គឺជាក្រុមមួយទៀតដែលខ្ញុំចង់សួរលោកផងដែរ គឺអ្នកដែលធ្វើការនៅស-២១ ប៉ុន្តែជាពេទ្យ។ នៅក្នុងបញ្ជីដែលខ្ញុំប្រគល់ជូនលោកគឺឯកសារE3/9905។ ខ្ញុំសូមអនុញ្ញាតបង្ហាញលើអេក្រង់ គឺមានលេខ <01011302> គឺលេខ១២ ដល់លេខ១៤។ នៅក្នុងបញ្ជីនេះដែលខ្ញុំបានគូសពណ៌ពីលើ គឺជាពេទ្យនៅស-២១ លេខ១២ គឺ ផេង ទ្រី ដែលគេបញ្ជាក់ថាជាប្រធាន<>ពេទ្យស-២១ ចាប់ថ្ងៃ១០ ខែ៥ <ឆ្នាំ>៧៨។ លេខ១៣ លេខ ឈឹម សំអឿ ហៅ សិត ចាប់ខ្លួនថ្ងៃ០៦ មេសា ៧៨។ លេខ១៤ គឺ ឆេង ប៉ោ ចាប់ខ្លួនថ្ងៃ០៨ ឧសភា ៧៨។ យើងក៏បានស្តាប់ឮសក្ខីកម្មរបស់ពេទ្យមួយចំនួនដែលថាភាគច្រើននៃពេទ្យជាន់ខ្ពស់នៅស-២១ ត្រូវបានគេចាប់ខ្លួនក្នុងពេលណាមួយក្នុងឆ្នាំ៧៨។ ដូច្នេះ ខ្ញុំចង់សួរលោកថាហេតុអ្វីបានជាពេទ្យនៅស-២១ ត្រូវបានគេចាប់ខ្លួន? ថាតើវាជាបញ្ជារបស់ នួន ជា ដែរឬទេ? តើលោកចាំអំពីការចាប់ខ្លួនពេទ្យហ្នឹងយ៉ាងម៉េចដែរ លោកអាចជម្រាបបានទេអំពីការចាប់ខ្លួនពេទ្យនៅស-២១ នេះ?

[១០:០៨:៣១]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ពេទ្យទាំងបីនេះ អ្នកដែលជិតស្និទ្ធនឹងខ្ញុំជាងគេ ហើយរត់ចុះរត់ឡើងមកមន្ទីរពេទ្យ៩៨ នេះញឹកញាប់ជាងគេគឺ មិត្តទ្រី។ មិត្តទ្រី នេះខ្ញុំអត់ចាំទេ មិនដឹងជាខុសអីទេកាលនោះ ហើយជាគោលការណ៍នៅតែដដែលទេ គិតមើល គឺមិត្តហ៊ី រាយការណ៍មក ខ្ញុំអ្នកស្នើទៅខាងលើ ព្រោះគាត់ជាអង្គភាពដែលគ្រប់គ្រង គាត់ជាប្រធានដែលគ្រប់គ្រងភាគីហ្នឹង ផ្នែកហ្នឹងដែលចូលមករួមនៅក្នុងស-២១

នេះមិត្តទ្រី។ ឯចំណែក មិត្តអឿ មិនដឹងជាគាត់ធ្វើខុសយ៉ាងម៉េចទេ ប៉ុន្តែថ្ងៃមួយនោះគាត់បំផ្លាញការងារនៅក្នុងស-២១ហ្នឹង មិត្តហ៊ី ហាមមិនស្តាប់ទៀត។ ខ្ញុំបាននិយាយហើយថាខ្ញុំបានចំណាយពេលច្រើនខែដែរ ទៅប្រមូលឯកសារពីផ្ទះមេធំៗរបស់ពួក លន់ នល់ មានឯកសារពីផ្ទះលន់ នល់, ឯកសារពីគណបក្សសាធារណរដ្ឋខ្មែរ គណបក្សស្អីទេរបស់ សិរិមតៈ នោះ ពី គុយ.ហ្សេ.អា.ហា សង្កាត់ -- ចាត់ការទូទៅនៃកងយុទ្ធពលខេមរភូមិន្ទនោះ យកមករក្សាទុក។ ប្រមូលឯកសារពីអគ្គសេនាធិការខ្លាំង យកមករក្សាទុកយ៉ាងមានរបៀបរៀបរយ។ ប៉ុនថ្ងៃមួយនោះ សំអឿ ស្នើសុំធ្វើ -- នែ! រៀបចំកន្លែង ខាងលិចៗ ស-២១នោះ ធ្វើមន្ទីរពេទ្យ។ មិត្តហ៊ី ឲ្យ។ ហើយដល់ទៅគាត់ទៅរើឯកសារបណ្ណាល័យរបស់ខ្ញុំហ្នឹង។ មិត្តហ៊ី ហាមមិនស្តាប់។ រើៗ បារបោះទៅឯកសារដែលខ្ញុំប្រមូលបានទាំងប៉ុន្មាន ដែលខ្ញុំខំរក្សាទុកយ៉ាងស្អាតនោះ។ ដល់ឥឡូវ មិត្តហ៊ី ភ័យ រត់មកហៅខ្ញុំ។ គាត់មិនរាយការណ៍ស្អីទេ គាត់ហៅខ្ញុំទៅមើលមន្ទីរពេទ្យម្តងបង។ ខ្ញុំក៏ទៅ ទៅខ្ញុំឃើញអាឯកសារខ្ញុំរប៉ាត់រប៉ាយ? ខ្ញុំថានរណា? មិត្តសំអឿ មក។ "ថា នេះ! ខ្ញុំទុកក្រដាកសៗនេះ អាក្រដាសថ្មី ឲ្យបងធ្វើ។ អានេះ ខ្ញុំប្រមូលយកបោសចោល" "បានថាយីស! អ្ហែងអីក៏សម្រេចធំជាងអញ! អាឯកសារហ្នឹងថ្លៃស្មើជីវិតអញណ៎ា! ដែលបក្សឲ្យអញទៅប្រមូល"។ នេះកំហុសចុងក្រោយ ដែលទ្រាំមិនបាន ខ្ញុំក៏រាយការណ៍សុំសេចក្តីសម្រេចពី បងនួន។ ឯចំណែក មិត្តប៉ោ ៗ នេះជាខាងកោះធំ។ ក្មេងនេះក៏មកពី៧០៣ដែរ។ ថ្ងៃមួយនោះ មិត្តហ៊ី គាត់មកពីធ្វើសកម្មភាពប្រតិបត្តិការខាងក្រៅ ដូចជាមេហៅទៅ។ រាក ដល់រាក មិត្តប៉ោ ឲ្យ *អាកសេណាល់* -- អ៎!សុំទោស *បេម៉ាកស្សុល* ៗ មិត្តហ៊ី ធ្វើទុកប្រកាច់យកដាប់អាម៉េចទេ។ ខ្ញុំរាយការណ៍ទៅបង សុន សេន ភ្លាម។ បង សុន សេន ថាអ៎ *បេម៉ាកស្សុល* នេះ *អាកសេណាល់* មានជាតិអាកសេណាល់ច្រើន។ "មិត្តពិនិត្យមើលបញ្ហាមនុស្សហ្នឹងឲ្យមែនទែនណ៎ា ប្រយ័ត្នងាប់កម្មាភិបាលរបស់មិត្តអស់"។ ដូច្នេះមិនដឹងជាពេលនុ៎ង ឬក៏ពេលក្រោយមកទេ កាលដែលចាប់ មិត្តប៉ោ នេះ។ ខ្ញុំសង្ស័យពេលក្រោយមកទេ ពេលនុ៎ងគ្រាន់តែពិនិត្យព្រោះព្រឹត្តិការណ៍នុ៎ង ដូចមុនកាលបរិច្ឆេទនេះឆ្ងាយណាស់។ កាលបរិច្ឆេទនេះដូចតាំងពី៧៧ មិត្តប៉ោ ៧៨ អ្នកដែលចុះឡើងផ្ទះខ្ញុំគឺ មិត្តទ្រី ទៅវិញទេ។ ដូច្នេះរឿងរ៉ាវអស់នេះ គឺវាអ៊ីចឹង។ យើងខ្ញុំចាប់នេះ គឺអ៊ីចឹង។

[១០:១៣:១៥]

រួចខ្ញុំសុំបញ្ជាក់ម្តងទៀត នៅស-២១នេះ ដែលចាប់ច្រើនគឺ ខ្ញុំនិយាយថាពួកដែលមកពីក្រុងអស់រលីង តាំងពី ណាត ចេញទៅ។ ឯចាប់ច្រើន គឺពួក៧០៣ ដើម្បីរក្សាអត្ថិភាពរបស់ខ្លួន មិត្តហ៊ី ត្រូវគិត

គួរអំពីបាតុភាពសេរីរបស់កងពល៧០៣ តាមដានជាប់ ការខុសឆ្គងយ៉ាងម៉េចៗ។ ឯចំណែកពួកមកពីអមលាំង ១៧នាក់នោះ មិត្តហ៊ អត់ប៉ះទេ។ ជាមនុស្សដែលមក ខ្ញុំនាំមកពីអមលាំង មិត្តហ៊ អត់ប៉ះទេ។ ដូចខុស -- ដូច្នេះខុសអីត្រូវអី គេរាយការណ៍។ ត្រង់គេនេះ -- តាមពិតគេអត់សង្កេតឃើញពួកអស់នោះខុសអីផង។ នេះជារបៀបរបបធ្វើការងារនៅស-២១។ ៧០៣ មិត្តហ៊ គេគិតគួរសម្បើមណាស់ ដើម្បីរក្សា ទុកកិត្តិយសរបស់គេ អត្ថិភាពរបស់គេនៅក្នុងបក្ស។ ឯចំណែកនៅខាងពួកដែលមកពីអមលាំង គេទុកឲ្យខ្ញុំសម្រេច ដោះស្រាយ។ ដូច្នេះ ខ្ញុំអត់មានអីប៉ះពាល់ដល់កូនចៅខ្លួនឯង ដូចខ្ញុំជ្រើសរើសយ៉ាងផ្ចិតផ្ចង់រួចមកហើយទេ អត់។ ដូច្នេះការ -- នេះខ្ញុំចូលជ្រៅទៅក្នុងការសម្រិតសម្រាំងនៅស-២១ បែបនេះ។ សូមបញ្ចាក់ប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់និងសាមសិបប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់ និងសាមសិបប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣៥ នាទី)*

[១០:៣៥:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះថា តើខ្ញុំអាចចាប់ផ្តើមសួរហូតទៅដល់ម៉ោងដប់មួយ សាមសិបនាទី ហើយចំណាយពេលរសៀលនេះខ្លះៗមិនជាច្រើនប៉ុន្មានទេ។ ហើយបន្ទាប់ពីម៉ោងដប់មួយ សាមសិបនាទីព្រឹកនេះទៅ ខ្ញុំនឹងជម្រាបជូនលោកប្រធានថា តើខ្ញុំត្រូវការពេលប៉ុន្មាននៅពេលរសៀលនេះទៀត?

ឥឡូវនេះ ខ្ញុំសុំចូលទៅដល់ការបោសសម្អាតនៅភូមភាគបូព៌ាលោកសាក្សី។ ខ្ញុំសូមចាប់ផ្តើមសួរឯកសារ E3/1688 – E3/1688។ សូមការអនុញ្ញាតបង្ហាញជូនឯកសារនេះទៅឲ្យសាក្សីពិនិត្យមើលនេះមានចំណាររបស់សាក្សីនៅលើទំព័រខាងមុខ<នៃចម្លើយសារភាពរបស់ ចាប ម៉ុត> គឺឯកសារ E3/1688។ បាទ សូមការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ហើយយើងខ្ញុំក៏សូមបញ្ចាំងឯកសារនៅលើអេក្រង់កុំព្យូទ័រផងដែរ គឺបុគ្គលម្នាក់ដែលជាលេខាស្រុកមកពី<តំបន់២២> ភូមិភាគបូព៌ា គឺនៅលើចម្លើយសារភាពនេះលោកបានចារដែលសរសេរដូចតទៅ៖ បញ្ជូនទៅ ប៉ុន។ ហើយនៅក្នុងកថាខណ្ឌ២ "ដកឈ្មោះ បងឈាន តំបន់<២២> បង<ម៉ុន និងបងសូ។ តាមគោលការណ៍> បងលេខ២ បាន ផ្តល់យោបល់នៅថ្ងៃទី<២៥ ខែកុម្ភៈ ឆ្នាំ> ១៩៧៨ ថា <ឈ្មោះ បងសូ> តំបន់២៣, <បង>ម៉ុន តំបន់២៣, សុត តំបន់២១, ឈាន តំបន់២២)។ គាត និង សុខ (កងពល១៧០) <និង តាល់ កងពល២៩០> សុំឲ្យដកឈ្មោះទាំងអស់នោះចេញពីចម្លើយសារភាពនេះ"។ សំណួររបស់ខ្ញុំ គឺហេតុអ្វីបានជាបងទី២នេះ ឲ្យលោកដកឈ្មោះបុគ្គលទាំងនេះចេញពីចម្លើយសារភាពនេះ?

[១០:៣៨:៤០]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ នេះជាយុទ្ធវិធី ឬក៏ហៅថាកិច្ចដំណើរការរាយការណ៍ឯកសារជូនខាងលើ។ កាលណាយើងខ្ញុំរាយការណ៍ទៅ ខាងលើឲ្យដកឈ្មោះណាជាបណ្តោះអាសន្នសិន យើងត្រូវវាយពុម្ពសាថ្មីម្តងទៀត ដក។ ដើម្បីខាងលើប្រើឯកសារនេះបញ្ជូនទៅភូមិភាគបូព៌ា កុំឲ្យវាប៉ះដល់អារម្មណ៍មេដឹកនាំ

នៅបូព៌ា គឺ បងភីម។ នេះជាគោលការណ៍ដែលយើងខ្ញុំអនុវត្តមកអ៊ីចឹង។ ដូច្នេះ មានន័យថាឯកសារនេះ យើងខ្ញុំជូនទៅដល់ដៃ ពូនួន ម្តងហើយ។ ហើយគាត់ណែនាំមកអ៊ីចឹង ទើបខ្ញុំឱ្យ មិត្តប៊ុន វាយសាថ្មីដក ឈ្មោះប៉ុន្មាននាក់ហ្នឹងចេញ។ ដែលការដកឈ្មោះហ្នឹងមិនមែនគ្រាន់តែដកឈ្មោះទទេទេ ដកសកម្មភាព អីដែលគេមើលទៅសង្ស័យថាវាប៉ះឈ្មោះហ្នឹង។

**ស៖** ខ្ញុំសូមដកស្រង់សម្តីរបស់លោកនៅថ្ងៃទី២៧ មីនា ឆ្នាំ២០១២ គឺ ឯកសារ E1/54.1 នៅ ម៉ោង ១០:២៦ ទៅដល់ម៉ោង ១០:២៩ ព្រឹក គឺគេសួរលោកដូចតទៅ៖ “ថាតើហេតុម៉េចបានជា នួន ជា ឱ្យលោកដកឈ្មោះទាំងនេះចេញ? លោកឆ្លើយថា៖ យើងបានដកឈ្មោះនេះចេញ ដោយសារយើងមិន ចង់ឱ្យដឹងថា ឈ្មោះរបស់ពួកគេហ្នឹងមានការជាប់ពាក់ព័ន្ធទេ ដោយសារតែឯកសានេះត្រូវបញ្ជូនទៅភូមិ ភាគបូព៌ា។” បញ្ចប់ការដកស្រង់។ លោកសាក្សី តើមានអ្វីកើតឡើងទៅដល់អ្នកដែល នួន ជា បានឱ្យ លោកដកឈ្មោះចេញពីចម្លើយសារភាពហ្នឹង តើក្រោយមកមានអ្វីកើតឡើងទៅដល់អ្នកទាំងហ្នឹងដែរទេ?

**ឆ៖** អរគុណ។ ដែលឱ្យដកនេះដកជាបណ្តោះអាសន្នទេ សម្រាប់ឱ្យបងទី២ គាត់បញ្ជូនឯក-សារនេះទៅខាង បងភីម ឱ្យបងភីមចាត់ចែង។ ដល់ក្រោយមក បងឈាន លេខា២២នេះ ចាប់ ដំណាលគ្នានឹងការដែលបក្សសម្រេចចាប់ បងភីម។ បងមុននេះ ក៏បក្សសម្រេចចាប់ នៅពេលដែលចាប់ បងភីម សម្រេចចាប់ បងភីម។ ឯចំណែក បងសូ បងសុត មិត្តតាត មិត្តសុខ ចាប់មុន។ ឯចំណែកមិត្ត តាល់ ក៏ចាប់មុនដែរ។ អានេះក្នុងកងពលមជ្ឈិម នៅក្នុងកងពលមជ្ឈិម។ ដូច្នេះអ្នកទាំងអស់នេះ គឺសុទ្ធ សម្រេចចាប់។ អ្នកណាដែលនៅក្នុងកងពលមជ្ឈិម ដូចយ៉ាង មិត្តតាត មិត្តសុខ មិត្តតាល់ ចាប់មុន។ ឯ ចំណែកអ្នកណាដែលនៅក្នុងតំបន់ខាងភូមិភាគបូព៌ា គេចាប់សរុបថ្ងៃដែលចាប់ បងភីម។ នេះខ្ញុំសូម បញ្ជាក់ប៉ុណ្ណោះ។

[១០:៤២:២៩]

**ស៖** សូមអរគុណលោកសាក្សី។ យើងបានឃើញ រកឃើញឈ្មោះទាំងនេះនៅក្នុងបញ្ជីរបស់ សហាចៅក្រមស៊ើបអង្កេត។ <៤នាក់ក្នុងចំណោមនោះ ត្រូវបានគេចាប់ខ្លួនសឹងតែត្រូវនឹងពេលវេលា ដែលលោកនិយាយនោះហើយ។> ឥឡូវខ្ញុំសូមសួរបុគ្គលិកពីរនាក់ដែលត្រូវបានចាប់ខ្លួនមុន គឺ<>ភ្លាមៗ ក្រោយពេលដែលលោកសរសេរកំណត់ត្រានេះ។ លេខាកងពល១៧០ សុខ គឺ កែ សុខ ហៅ សុខ គឺនៅ លេខរៀង ២៩៦៩ បញ្ជីរបស់សហាចៅក្រមស៊ើបអង្កេត គាត់ចូលមកនៅថ្ងៃទី០៤ មីនា ១៩៧៨ គឺមួយ សប្តាហ៍ក្រោយ ដកឈ្មោះនេះ <ហើយ>ត្រូវ<បាន>សម្លាប់នៅថ្ងៃទី១១ ខែ<ឧសភា ឆ្នាំ៧៨>។ កូន

និងប្រពន្ធក៏ត្រូវបញ្ជូនមក<ស-២១ដែរនៅពេលក្រោយមក គឺនៅ>ថ្ងៃទី<១៧> មិថុនា ៧៨ ហើយប្រពន្ធនិងកូនត្រូវបានសម្លាប់នៅថ្ងៃ<បន្ទាប់>នោះ<គឺថ្ងៃ១៨ មិថុនា>។ ឈ្មោះរបស់ប្រពន្ធកូនក៏មាននៅបញ្ជីរបស់សហាថៅក្រមស៊ើបអង្កេត គឺប្រពន្ធរបស់គាត់នៅលេខ<១០៧៥៨> កូនរបស់លេខាកងពល១៧០ គឺនៅលេខរៀង ១០៧៥៣ <និង៧៥៤>។ <មនុស្សម្នាក់ទៀត ដែលត្រូវបានចាប់ខ្លួនជិតនឹងពេលដែលលោកធ្វើចំណារនេះ គឺលេខាតំបន់២៣ ឈ្មោះ សូ ឈ្មោះពេញថា> អ៊ុក សាវ៉ាន់ ហៅ អ៊ុក ញ៉ាត់ ហៅ សូ គឺនៅលេខរៀង៥៩៩៩ <នៅបញ្ជីរបស់សហាថៅក្រមស៊ើបអង្កេត> ចាប់ខ្លួននៅ<ថ្ងៃទី១៧> ខែមីនា ៧៨ ប្រពន្ធរបស់គាត់ចូលមកស-២១ នៅថ្ងៃទី០៤ មេសា ហើយសម្លាប់នៅថ្ងៃទី០៥ មេសា <> គឺលេខរៀង <៩០៦៥> កូនប្រុសចូលនៅថ្ងៃទី<០៤> មេសា ៧៨ <លេខរៀង៩០៧៤> ហើយកូនស្រី ចូលមកថ្ងៃទី០៤ មេសា ៧៨ ហើយសម្លាប់ចោលនៅថ្ងៃទី២៤ <លេខរៀង ៩០៦៧ នៅបញ្ជីរបស់សហាថៅក្រមស៊ើបអង្កេត>។ សំណួររបស់ខ្ញុំលោកសាក្សី គឺកម្មាភិបាលពីរនាក់ <និងគ្រួសាររបស់ពួកគេ ក្នុងនោះ>គឺលេខាកងពល១៧០<ឈ្មោះ សុខ និង>លេខាតំបន់<២៣>ឈ្មោះ សូ។ តើ នួន ជា ធ្លាប់ដែលប្រាប់លោកថា ហេតុអ្វីបានជាកម្មាភិបាលទាំងពីរនេះ ព្រមទាំងប្រពន្ធកូន ត្រូវបានចាប់ខ្លួនបញ្ជូនមកស-២១? <តើអ្នកទាំងអស់នេះត្រូវបានគេចាប់ខ្លួនដោយសារមូលហេតុអ្វី?>

[១០:៤៥:៣៤]

**ឆះ** អរគុណ។ ធ្វើការជាមួយ បងនួន ឆាប់ណាស់។ គាត់ហៅខ្ញុំទៅធ្វើការមិនដែលលើសពី ១០*មីនុត* – ១០នាទីទេ។ ដូច្នេះឯកសារទាំងអស់នេះ គឺគាត់បញ្ជា បានឯកសារទៅ គាត់បញ្ជាទៅខាងបងភឹម ឲ្យចាត់ចែងដោះស្រាយ។ ឯចំណែករឿង មិត្តសុខ ខ្ញុំឮតាម បងខៀវ ខ្លះៗ –បងសុន សេន– គាត់ទាក់ទងមកខ្ញុំតាមអាកាស គាត់ថា “ហ៊ឺ! សុខ រវល់តែដកកងទ័ពយកទៅរៀនសូត្រ អាយួនចូលមក គាត់ដកកងទ័ពយកទៅរៀនសូត្រ ពិបាកណាស់”។ សូមបញ្ជាក់ថា ខ្ញុំ ហើយនិង មិត្តសុខ ធ្លាប់ធ្វើការក្រោមការដឹកនាំរបស់គាត់ ដូច្នេះនៅពេលដែលចាប់ ចក្រី មក អង្គការដាក់ សុខ ឲ្យធ្វើលេខាកងពល។ ដូច្នេះគាត់ដឹងថាខ្ញុំ ហើយនិង មិត្តសុខ ស្វែងយល់គ្នា យល់ចិត្តគ្នាទៅវិញទៅមក ហើយគាត់ប្រាប់អីចឹង។ ដូច្នេះបានន័យថា មិត្តសុខ ចេញបាតុភាព ចេញក្រឡាសាឲ្យគាត់ដឹងហើយ។ នេះ ខ្ញុំដឹងតែរឿង មិត្តសុខ ទេ ឯចំណែក បងសូ ខ្ញុំមិនដែលស្គាល់ មិនដែលឃើញមុខ។ ដូច្នេះ បងនួន មិនដែលងាយនិយាយរឿងអីទេ។ អត់ដែលនិយាយៗរឿងអីទេ ហ្នឹងខ្ញុំសូមចប់ប៉ុណ្ណឹង។

**សះ** តើលោកធ្លាប់ដែលឮ នួន ជា និយាយអំពីកម្មាភិបាលភូមិភាគបូព៌ាដែរទេ? ហើយក្រោយ

មក ក្រោយការកត់ត្រារបស់លោកមក តើលោកធ្លាប់ដែលទទួលការណែនាំ<ពី នួន ជា> ឲ្យចាត់ការយ៉ាងម៉េចដែរទេ ពាក់ព័ន្ធទៅនឹងអ្នកទោសដែលគេបញ្ជូនមកពីភូមិភាគបូព៌ា?

**ឆ៖** អរគុណ។ អ្នកទោសដែលបញ្ជូនមកពីភូមិភាគបូព៌ា ដល់ស-២១ ខាងស-២១ ចាត់ចែងសួរ។ អត់មានណែនាំអីជាពិសេសទៀតទេ។ គាត់រង់ចាំតែទទួលចម្លើយ ហើយបញ្ជូនទៅឲ្យគេខាងក្រោម។

[១០:៤៣:៣៧]

**ស៖** ក្រោយមក នៅពេលមួយក្នុងឆ្នាំ១៩៧៨ តើលោកមានបានទទួលការណែនាំពី នួន ជា ពាក់ព័ន្ធទៅនឹងការសម្លាប់អ្នកទោសមកពីភូមិភាគបូព៌ាដែរទេ?

**ឆ៖** ខ្ញុំសូមរំឭកតាមការចងចាំខ្លះ។ ព្រឹត្តិការណ៍នេះវាយូរហើយ កាលនោះ វាជាក់ស្តែង វាច្បាស់។ ដូចខ្ញុំបាននិយាយអ៊ីចឹង នៅស-២១ កាលណាជិតចាប់ភូមិភាគណាមួយជាគំហុកមកច្រើនៗ ដឹកនាំតែងតែឲ្យខ្ញុំកម្ទេចអ្នកដែលនៅសល់នុ៎ង ឲ្យបានច្រើនជាអតិបរមា ដើម្បីយកកន្លែងឃុំឃាំងអ្នកមកថ្មី។ ហើយនិងចាត់ចែងសួរអ្នកមកថ្មី។ ដូច្នេះព្រឹត្តិការណ៍ចាប់ពួកបូព៌ានេះ វាមានហូរហែពីមុនមកដែរ។ ដូច្នេះខ្ញុំជឿថា ពិតជាអាចមានបញ្ហាហ្នឹងមួយ។ មុនការចាប់ បងភឹម ចាប់អីនៅខែ៦ ១៩៧៨។ ដល់ខែ៦ ១៩៧៨ មកម្តងទៀត ច្រើន។ ហើយខ្ញុំបាននិយាយដែរ ប៉ុន្តែនៅពេលនេះ ខ្ញុំសូមនិយាយម្តងទៀត។ អ្នកដែលទទួលភារៈបញ្ជូនមនុស្សមក ស-២១ គឺ មិត្តរឿង ជំនួយការសេនាធិការ អ្នកបញ្ជូនមកឲ្យខ្ញុំ។ ការបញ្ជូនមកទាំងច្រើនៗនៅពេលដែលសម្រេចចាប់ បងភឹម នេះ ពេលនុ៎ងហើយ ដែលមកមួយព្រឹក ម្តែសាមសិបនាក់។ ដោយឡែក មានរឿងមួយដែលខ្ញុំចង់បញ្ជាក់ ជាគោលការណ៍ បងប៉ុល មិនដែលនិយាយចូលខ្ញុំទេ ពីរឿងស-២១ ពីរឿងប៉ូលិស ពីរឿងចាប់ អត់ដែលនិយាយសោះ។ ថ្ងៃមួយនោះ ព្ទូរស័ព្ទគេរោទិ៍ ខ្ញុំទៅលើកឡើង ដល់លើកឡើង មិត្តរឿង គាត់ថា "បងឌុច! មានឈ្មោះអក្សរ (ម៉) មកទេ? ខ្ញុំថា យ៉ុស! មិត្តរឿង ឯងក៏ត្រូវការដឹងរឿងអីខ្លាំងស-២១"។ ខ្ញុំអត់និយាយ -- ថាខ្ញុំអត់និយាយទេ ប្រាប់មិត្តរឿង អ៊ីចឹង តែប្រតិកម្មខ្ញុំឆ្លល់ ថាមិត្តរឿង ម៉េចក៏ហ៊ានលូកលាន់មកកិច្ចការ ស-២១? អង្កាល់ហ្នឹងថា "ទេ ខ្ញុំអត់និយាយទេ"។ ស្រាប់តែមួយសន្ទុះ មិត្តរឿង មកទៀត "បងឌុចអ្នំា ចាំជួបបង" ខ្ញុំក៏ចាំជួបហ្នឹង មិនដឹងបងណា ដល់ទៅ ស្រាប់តែមកច្បាស់ចែស "មិត្តឌុច" មាត់បង ប៉ុល "អក្សរ (ម៉) មានមកទេ?" ម៉ គឺសំដៅ ម៉ុន។ ខ្ញុំថា "មានបង បាទៗ មានបង ឆ្លើយប្រញាប់អ៊ីចឹងទៅ។ គាត់ថាអើបានហើយ"សួរតែមួយម៉ាត់ហ្នឹង។ ដូច្នេះមនុស្សអក្សរ (ម៉) នេះ – ម៉ុន នេះ ឈ្មោះដើមរបស់គាត់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស៊ីថុន។

ដំបូង បងភឹម ចាត់តាំងឲ្យធ្វើជារងសេនាធិការយុទ្ធភូមិភាគបូព៌ា ដោយក្រោយដែលបក្សចាប់លី ផែល ហៅ ផែន មក បងម៉ុន ឡើងទៅជាសេនាធិការ នាយសេនាធិការភូមិភាគបូព៌ា។ នេះរឿងបងម៉ុន។ ឯចំណែក បងម៉ុន នេះជាមនុស្សដែល បងប៉ុល ចាប់អារម្មណ៍សរសេរនៅក្នុងប្រវត្តិតស៊ូនយោបាយ១៨ឆ្នាំ ថា “ជនក្បត់បក្សមាន ស៊ីវ ហេង, ប៉ែន យុទ្ធ និង ស៊ីថុន”។ ស៊ីថុន នេះគឺ ម៉ុន។ អ៊ីចឹងហើយបាន បងប៉ុល ចាប់អារម្មណ៍ណាស់ តើពេលនុ៎ងមានមក ឬអត់? ដូច្នេះវាបញ្ជូនមកអ៊ីចឹង ចាប់មកទាំងឈុត ទាំងដុលអ៊ីចឹង។ សូមអរគុណ។

[១០:៥៣:១៨]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំសូមផ្តោតទៅលើបញ្ហាជាក់លាក់ ដែលខ្ញុំពេញចិត្តនឹងចម្លើយរបស់លោក។ តើសមមិត្តរឿន ដែលហៅលោក ហើយសួរលោកនេះ<គឺជាជំនួយការសេនា-ធិការ> តើជាឈ្មោះ រឿន ដែលជាលេខាកងពល៨០១ ហ្នឹង ឬក៏ជាមនុស្សផ្សេង?

**ឆ៖** អរគុណ។ មិត្តរឿង ជំនួយការសេនាធិការ ដល់ក្រោយមកគេយកមកចាត់តាំងជាជំនួយការសេនាធិការ។ ដល់មិនដឹងជាមានរឿងអីចាប់ជំនួយការសេនាធិការហ្នឹងប្រគល់មកឲ្យ ស-២១ ទៀត ឯចំណែក មិត្តរឿន ហ្នឹងអត់ចាប់ទេ។ ដល់ក្រោយមកបាន បងម៉ុក គាត់ចាប់មិត្តរឿន, មិត្តសាន, មិត្តឃន ជាមួយនឹង បងប៉ុល។ មិត្តរឿន ៨០១ នោះចាប់ពីក្រោយនេះទេ។

**ស៖** ពេលនិយាយអំពី រឿន និង សាន គឺពេលក្រោយមកទេ គឺដឹងថាក្រោយមកទេ គឺនៅ<ក្រោយ>ឆ្នាំ១៩៧៩ ទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ សូមបញ្ជាក់ម្តងទៀត។ រឿង ផ្សេង, រឿន ផ្សេង – រឿន ៨០១។ រឿង ជំនួយការសេនាធិការ ក្រោយមកត្រូវចាប់ខ្លួន។

**ស៖** សូមអរគុណដែលបានបញ្ជាក់ចំណុចនេះ។

**លោក ផេល លីសាក់៖**

លោកប្រធានសុំការអនុញ្ញាតបង្ហាញឯកសារ E3/8463 – E3/8463 ដែលជាបញ្ជីមួយជាក់លាក់ចេញពីឯកសារនេះ គឺបញ្ជីអ្នកទោសដែលបានសម្លាប់នៅថ្ងៃទី២៧ ឧសភា ឆ្នាំ៧៨។ បាទ សុំការអនុញ្ញាត។

[១០:៥៥:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ឯកសារដែលខ្ញុំផ្តល់ជូនទៅលោកនេះ លោកសាក្សី ខ្មែរគឺ<ចាប់ពីទំព័រ> 00016039 ដល់74 ហើយអង់គ្លេសបកប្រែត្រង់ទំព័រនេះ នេះគឺជាបញ្ជីអ្នកទោសដែលមានចំណងជើងថា បញ្ជីអ្នកទោសដែលបានកម្ទេចនៅថ្ងៃទី២៧ ឧសភា ៧៨ ហើយសូមលោកមើលផ្នែកខាងលើ ក្នុងនោះគឺថា មានអ្នកទោសសរុបទាំងអស់៥៨២នាក់ ឯណោះ។ ភាគច្រើនគឺមកពីភូមិភាគបូព៌ា ហើយបើលោកមើលទៅលើបញ្ជីអ្នកទោសដែលសម្លាប់នេះ ចំនួន៣១៦នាក់ពីខាងលើ លេខរៀងតាំងពីខាងលើមក គឺសុទ្ធតែជាអ្នកដែល មកពី<តំបន់២៣>ភូមិភាគបូព៌ា។ ហើយបើលោក មើលរហូតមកដល់ចុងបញ្ចប់នៃបញ្ជីនេះ នេះបើលោកមានពេល ពិនិត្យមើល ជាពិសេសអ្នកទោស លេខរៀង ៥២៦ ទៅដល់ ៥៥៦ នៅចុងបញ្ចប់នៃបញ្ជីនេះ គឺថាអ្នកទោសទាំងអស់នេះ បានបញ្ជាក់ថា ត្រូវបានមកដល់នៅថ្ងៃទី២៨ ឧសភា ៧៨។ ហើយដែលថា ការសម្លាប់ សម្លាប់រហូតដល់ថ្ងៃបន្ទាប់មកទៀតឯណោះ។ សំណួររបស់ខ្ញុំ គឺសំណួរដំបូង បញ្ជីអ្នកទោសដែលត្រូវបានសម្លាប់នេះ គឺភាគច្រើនអ្នកទោសមកពីភូមិភាគ បូព៌ា គឺចាប់ផ្តើមសម្លាប់នៅថ្ងៃទី២៧ ឧសភា ៧៨។ តើលោកនៅចាំបានទេ ពីរថ្ងៃដំបូង គឺថ្ងៃ២៥ ឧសភា ១៩៧៨ លោកចាំទេ ថ្ងៃបរិច្ឆេទហ្នឹង មានអ្វីកើតឡើង? ពីរថ្ងៃ គឺថ្ងៃទី២៥ ឧសភា ៧៨ មុននឹងអ្នកទោសទាំងអស់នេះ ត្រូវសម្លាប់នៅថ្ងៃទី២៧ ឧសភា ៧៨។ លោកចាំកាលបរិច្ឆេទ ហើយមានអ្វីកើតឡើងពេលនោះទេ?

[១០:៥៨:៣០]

**ឆ៖** អរគុណ។ ដូចខ្ញុំបានបញ្ជាក់ហើយ បងភឹម និងគណៈប្រធានភូមិភាគបូព៌ា ហើយនិងយុទ្ធជនមួយចំនួនដែលនៅក្បែរគាត់នោះ ត្រូវចាប់ខែ៦ ១៩៧៨។ ដូច្នេះ មុននោះ ខាងលើពិតជាណែនាំឱ្យខ្ញុំដកមនុស្សឱ្យអស់ជាអតិបរមា សម្រាប់ទទួលអ្នកមកថ្មី។ នេះវាស្ថិតនៅក្នុងការបញ្ជូនអ្នកទោសចេញយកទៅជើងឯក ជាចំនួនច្រើនៗតាមដែលអាចធ្វើទៅបាន ដើម្បីចាំទទួលអ្នកមកថ្មី។

**ស៖** តើអ្នកណាជាអ្នកណែនាំឱ្យដកអ្នកទោសចំនួន ៥៨២នាក់ ពីស-២១ យកទៅសម្លាប់នៅជើងឯកហ្នឹង?

**ឆ៖** អរគុណ។ បងនួន គាត់ណែនាំមកមិនច្បាស់ចំនួនអ៊ីចឹងពេកទេ។ គាត់ហៅខ្ញុំទៅណែនាំ

គាត់ថា “មិត្តឌុច ដកចេញណ៎ា ដកឲ្យច្រើនជាអតិបរិមា។” ហើយមកដល់ ខ្ញុំយករឿងនេះទៅប្រាប់មិត្តហ៊ា ឲ្យគេម្ចាស់ការរៀបចំដក ទៅដកឲ្យច្រើនជាអតិបរិមា ចម្លើយដែលមានទាំងប៉ុន្មានហ្នឹង យើងដឹងហើយថាពិតជាមានការបោសសម្អាតខាងភូមិភាគបូព៌ាឆាប់ៗនេះ។ ដល់ហើយមិត្តហ៊ា គេម្ចាស់ការទៅហើយ ប្រមូលយកអ្នកណាដែលត្រូវដក គេដក ព្រោះបញ្ជាពីខាងលើមកអ៊ីចឹង។ “មិត្តឌុច គឺត្រូវដកឲ្យបានច្រើនជាអតិបរិមា” នេះបញ្ជា។ ឯចំណែកយើងខ្ញុំនៅនោះ ជាអ្នកប្រតិបត្តិការនៅស-២១ យើងដឹងថាចម្លើយនៅបូព៌ាហ្នឹងកាន់តែវាទាបណាស់ហើយ ជិតដល់ថ្ងៃដែលខាងលើសម្រេចឲ្យចាប់ បងភឹមហើយនិងកូនចៅហើយ។

[១១:០១:១២]

**សៈ** នៅក្នុងសក្ខីកម្មលោកមុនៗនោះ <លោកបាននិយាយពី>ពេលដែលលោកទទួលការណែនាំពី នួន ជា ឲ្យសម្លាប់អ្នកទោស<មកពីភូមិភាគបូព៌ា>រាប់រយនាក់មុនពេលសួរចម្លើយយ៉ាងដូច្នេះ តើ<នោះគឺជា>ការសម្លាប់ដែលបានលើកឡើងនៅក្នុងបញ្ជីនៅចុងខែឧសភា ៧៨ <ហ្នឹង ឬក៏នោះជាអ្វីដែលបានកើតឡើងនៅពេលក្រោយ នៅក្នុងឆ្នាំនោះ> តើ<លោកនៅចាំទេ>?

**ឆៈ** អរគុណ។ នៅឆ្នាំនោះ រឿងខាងក្រោយមកទៀត គឺមានតែរឿងតាមចាប់ពួកបូព៌ាប្រមូលមកឲ្យអស់ ហ្នឹងមួយ។ ប៉ុន្តែបើនិយាយពីដកចេញទាំងឈុត ទាំងសិប ទាំងរយអ៊ីចឹង បើតាមខ្ញុំចាំមានតែមួយលើកទេ គឺប្រហែលជាថ្ងៃប៉ុន្មាន ថ្ងៃ០៣ មករា ១៩៧៩។ បងនួន ហៅខ្ញុំទៅប្រាប់ “ដកចេញទាំងអស់”, ខ្ញុំថា “ចុះពួកយួន?” ថា “អើ យើងរកបានក្រោយ”។ អាហ្នឹងខ្ញុំថា “អ៊ីចឹងខ្ញុំសូមទុកពួកយ-៨ បួននាក់”។ យ-៨ហ្នឹង គឺពួកដែលបាញ់ភ្ញៀវបរទេសនៅកន្លែងទទួលភ្ញៀវនោះ មានពួកបស្ចិមប្រទេសឈ្មោះ ឌុក ម៉ាន់ អីនោះ ខ្ញុំភ្លេចអស់ហើយ ហើយក៏ឈ្មោះអង់គ្លេសខ្ញុំពិបាកចាំ។ ដូច្នេះ ខ្ញុំសូមទុកពួកយ-៨ បួននាក់សម្រាប់សួរតទៅទៀត។ គាត់ថា “អើម្ចាស់ការណ៎ា”, ខ្ញុំថា “បាទ”។ អ៊ីចឹង ខ្ញុំមកផ្ដល់ប្រាប់មិត្តហ៊ា ថា “ដកទាំងអស់ អង្គការឲ្យដកទាំងអស់”។ ដល់គ្នាក៏ខំខ្នះខ្នែងដកទាំងអស់។ ដល់ហើយមកប្រាប់ខ្ញុំ “អស់ហើយបង”, ខ្ញុំថា “អើ! អ៊ីចឹងឲ្យពួកក្មេងៗគេសួរអាបួននាក់ហ្នឹងទៅ”។ ដូច្នេះការដកទាំងអស់ពិតប្រាកដ គឺនៅថ្ងៃ០៣ អាច ០៣ ឬក៏០៤ ឬក៏០២ មករា ១៩៦៦ -- អ៎នែ! ៧៨ -- អ៎! ៧៩។

[១១:០៣:៥១]

**សៈ** ខ្ញុំនឹងសួរលោកអំពីការបញ្ជា និងការសម្លាប់អ្នកទោសដែលនៅសល់នៅស-២១ ហ្នឹងនៅពេលបន្តិចទៀតនេះ។ ឥឡូវនេះខ្ញុំនិយាយអំពីការសម្លាប់អ្នកទោស<មកពី>បូព៌ា គឺថាមានការសម្លាប់

ច្រើនដើម្បី<>សម្អាត<ក្នុងគុកដូចដែលលោកនិយាយ។> ថាតើមានការសម្លាប់ទ្រង់ទ្រាយធំទៅលើអ្នកទោសនៅបូព៌ាដែរឬទេ <>ក្រោយ<ថ្ងៃទី> ២៧ <ឬ>២៨ ឧសភា ៧៨? ដែលថាគឺក្រោយពេលដែលការសម្លាប់អ្នកទោសជាង<៥៨០>នាក់នៅលើបញ្ជីហ្នឹង តើមានការសម្លាប់បន្តទៀតទេទៅលើអ្នកទោសនៅភូមិភាគបូព៌ានោះ?

**ឆ៖** អរគុណ។ រឿងនេះវាយូរបន្តិចទៅហើយ បើតាមខ្ញុំលើកឡើងវិញដូចមានម្តង។ ពួកបូព៌ាដឹកឡានចូលមកចាប់បញ្ចូលក្នុងទ្រុងហើយយកទៅបណ្តោយ អត់បាច់សួរ។ នេះជាការណែនាំពីខាងលើ។ នាំពួកបូព៌ាចូលមកចាប់ ហើយយកចេញទៅ ចាប់ព្រឹក ថ្ងៃ ល្ងាចឡើងយកចេញទៅ។ ហ្នឹងមានដូចជារាប់រយនាក់ណា ពីរបីរយ។ ខ្ញុំមិនចាំទេ មាន១បាតុភាពមួយទៀត។

**ស៖** តើអ្នកណាជាអ្នកបញ្ជាឲ្យលោកយកមនុស្សទាំងអស់នេះយកទៅសម្លាប់ភ្លាមៗ<ដោយមិនចាំបាច់សួរចម្លើយ>នោះ?

**ឆ៖** គឺ បងនួន ដដែល ពូនួន ដដែលហ្នឹង។

**ស៖** ឥឡូវនេះ ខ្ញុំនិយាយអំពីការប្រជុំដែលលោកចូលរួមនៅខែតុលា ៧៨។ តើលោកចាំទេថា លោកបានចូលរួមនៅក្នុងវគ្គរៀនសូត្រនយោបាយដែលដឹកនាំដោយ ប៉ុល ពត គឺក្នុងខែតុលា ៧៨? តើលោកអាចប្រាប់បានទេថា ប៉ុល ពត បានចេញបញ្ជា ឬក៏ផ្តល់នូវការណែនាំយ៉ាងម៉េចខ្លះ នៅក្នុងការប្រជុំនោះ?

[១១:០៦:៣៦]

**ឆ៖** អរគុណ។ ពេលនុំងខ្ញុំទៅរៀន។ គ្នាខ្ញុំទៅបីនាក់ ខ្ញុំ មិត្តហ៊ី ហើយនិង មិត្តហ៊ុយ ទៅរៀន។ ទីកន្លែងដែលរៀនគឺនៅពុទ្ធិកៈវិទ្យាល័យព្រះសុរាម្រិត នៅជាន់លើ។ អាជាន់ក្រោម ខ្ញុំតែងតែជួប ពូនួន ធ្វើការងារ ហើយចុងក្រោយនេះ ជួប បងហែម ធ្វើការងារនៅនុំង។ ក្នុងពេលរៀននុំង សំខាន់ខ្លឹមសារដែលឧទ្ទេសនាមមានពីរ គឺទី១ ឧទ្ទេសនាមឡើងវិញអំពីសីលធម៌១២ប្រការនេះ ហើយទី២និយាយអំពីសហករណ៍ជឿនលឿន។ គាត់និយាយថា នៅស្រុកចិន គេកសាងសហករណ៍គំរូ។ ឯចំណែកយើង យើងកសាងសហករណ៍ជឿនលឿន។ សហករណ៍នីមួយៗត្រូវមានផ្ទះ ត្រូវមានដំណាំជុំវិញផ្ទះ។

**ស៖** តើលោកបានទទួលបញ្ជា<ច្បាស់លាស់>ពី ប៉ុល ពត ជាពិសេសទាក់ទងទៅនឹង<អ្នកទោស> ការចាប់ខ្លួនអ្នកទោស សួរចម្លើយអ្នកទោសអ្វីដែរឬទេ<នៅក្នុងការប្រជុំនេះ>? តើលោកចាំថា ប៉ុល ពត មាននិយាយអ្វីជាក់លាក់ច្បាស់លាស់អំពីបញ្ហាអ្នកទោសនេះទេ?

[១១:០៨:៣៤]

**ឆ៖** អរគុណ។ គាត់និយាយបញ្ហានេះ វាហាក់ដូចជាសភាពការណ៍ហ្នឹងធូរស្រាល ណែនាំឈប់ ស-២១ ឈប់សួរ ឈប់សួរចម្លើយអ្នកទោស។ រួចគាត់ដោះសាទៀតថា កន្លងមកមជ្ឈិមមានដែលទៅណែនាំនគរបាលឯណា ឥឡូវឈប់សួរ។ អាដែងយើង ចំណែកដែលយើងហៅថា ខ្មែរសហ្នឹង គឺពួកវាអត់បាយស៊ី ហើយវាទៅដេកព្រៃទៅ។ យើងទៅយកមកឲ្យបាយវាស៊ីទៅរួចគ្នាហើយ។ អានេះគាត់ណែនាំនៅអ៊ីចឹង។ ឯចំណែកសារាចរដែលចេញពេលនុ៎ង អ្នកណាចូល សេ.អ៊ី.អា ពីឆ្នាំណា អាចបក្សលើកលែងបានស្អី១ អានេះសភាពការណ៍ហ្នឹង។ ដល់មក ប៉ុន្មានថ្ងៃក្រោយមក បងនួន ហៅខ្ញុំទៅធ្វើការ។ ខ្ញុំអត់ដឹងធ្វើម៉េច បើបក្សណែនាំមកមិនឲ្យសួរ។ អ្នកទោសនៅប៉ុន្មាន ខ្ញុំអត់ធ្វើអី។ ដូច្នេះ បងនួន ថា "អ្ហែ៎! មិត្តឌុច ឥឡូវគេចេះមាគ៌ាសម្បើមណាស់"។ ខ្ញុំក៏ចាប់ផ្ដើមសួរឡើងវិញ។ នេះរឿងរ៉ាវដែលប៉ុល ពត ណែនាំ។ ដោយឡែកចំពោះបញ្ហាមន្ទីរនគរបាល ជាពិសេសស-២១ និយាយឲ្យចំ ស-២១។

**ស៖** ខ្ញុំចង់ឲ្យលោកមើលនៅកំណត់ត្រាមួយ ដែលជាកំណត់ត្រានៅក្នុងសៀវភៅរបស់អ្នកសួរចម្លើយ គឺ១ជាសៀវភៅមួយ គឺសៀវភៅរបស់ ប៉ុន <ឬ> ទុយ <E3/834> ខ្មែរមានទំព័រលេខ 00077518 នៅ<ផ្នែកខាងក្រោមនៃ>ទំព័រ, អង់គ្លេសមានលេខ <00184522> គឺមិនមានឯកសារជាភាសាបារាំងទេ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតប្រគល់ឯកសារនេះជូនដល់សាក្សី ហើយក៏សូមបង្ហាញនៅលើអេក្រង់ផងដែរ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១១:១១:១៧]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ទំព័រនេះត្រូវបានប្រគល់ជូនលោក ហើយលោកឃើញខ្ញុំគូសពណ៌បៃតង ហើយខ្ញុំសូមអនុញ្ញាតផងដែរ បង្ហាញនៅលើអេក្រង់។ នេះគឺជាកំណត់សម្គាល់<របស់អ្នកសួរចម្លើយ> ចុះថ្ងៃ០៨ តុលា ៧៨។ ហើយកំណត់សម្គាល់ដែលខ្ញុំចង់ផ្ដោតទៅលើនេះ គឺបានសរសេរដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ក្នុងពេលខ្លី គឺយើងចង់សួរចម្លើយខ្មែរទាំងអស់ដែលមិនចាំបាច់វាយ ហើយទាញឲ្យបានចម្លើយ ៨០ភាគរយ មិន១១វៃ ហើយទទួលបានចម្លើយ ៧០ភាគរយ។ ចំពោះបរទេសវិញ "គឺយួន ពួកចក្រពត្តិអាមេរិក សេ.អ៊ី.អា យើងចាំបាច់ត្រូវប្រើវិធីអចិន្ត្រៃយ៍ វិធីតឹងតែង"។ ខ្ញុំសូមនិយាយឡើងវិញ

ចំពោះបរទេស គឺយួន ពួកចក្រពត្តិ សេ.អ៊ី.អា យើងត្រូវប្រើវិធីពិសេសដោយអចិន្ត្រៃយ៍ និងជារួម ហើយក្នុងរយៈពេល បណ្ដោះអាសន្នភារកិច្ចរបស់យើងគឺអនុវត្តនូវគោលការណ៍ចាស់ជារួម និង<ដាច់ខាត>។” សូមបញ្ចប់ការដកស្រង់។ ដូច្នេះ កំណត់សម្គាល់នេះគឺបានបញ្ជាក់ថា ក្នុងពេលខាងមុខហ្នឹងគឺពួកគេគ្រោងនឹងសួរអ្នកទោសខ្មែរ ដោយមិនបាច់វ៉ៃ ប៉ុន្តែចំពោះបរទេស គឺយួន សេ.អ៊ី.អា ចក្រពត្តិ គឺយើងអនុវត្តការងារសន្តិបាលដាច់ខាតនិងទាំងស្រុងនិងជាស្ថាពរ ប៉ុន្តែក្នុងពេលបណ្ដោះអាសន្នហ្នឹង គឺគេអនុវត្តគោលការណ៍ចាស់ដដែល។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើលោកធ្លាប់ប្រជុំជាមួយអ្នកសួរចម្លើយរបស់លោក ក្រោយពេលដែលលោកពិភាក្សាជាមួយ ប៉ុល ពត និង នួន ជា ដែរឬទេ? ហើយតើលោកដឹងទេថាការណែនាំ គឺការណែនាំដែលលោកបានផ្ដល់ហ្នឹង គឺជាការណែនាំដែលលោកបានទទួលពី ប៉ុល ពត និង នួន ជា ដែរឬទេ?

[១១:១៣:៥៩]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ដំបូងខ្ញុំសូមនិយាយជូនជាការចាប់អារម្មណ៍ដដែលដូចម្សិលមិញអ៊ីចឹង។ ឯក-សារនេះច្បាប់ដើមខ្ញុំធ្លាប់ឃើញតែពីរសន្លឹកគត់ ដែលខាងនេះខាងការិយាល័យសហព្រះរាជអាជ្ញាអង្គាល់ដែលខ្ញុំនៅក្នុងរយៈកាលស៊ើបអង្កេតនោះដែរ ហៅថាឯកសារ ទុយ ប៊ុន។ ហើយខ្ញុំមើលជាក់ស្ដែងទៅមិនមែនឯកសារ មិត្តទុយ។ ព្រោះ មិត្តអឿន គាត់សរសេរថា បងទុយ ធ្វើឲ្យប្រឡាក់ប្រឡូស មើលៗយូរទៅបានឃើញខ្លឹមសាររបស់ មិត្តអឿន។ ដូច្នេះ អាពីរសន្លឹកខាងដើមជាឯកសាររបស់ មិត្តអឿន។ អាកន្លែងតទៅទៀតនេះ ខ្ញុំឃើញមានស៊ីញ៉េ មិត្តទុយ។ ដូច្នេះ សូមបញ្ជាក់ជូនថា ឯកសារនេះខ្ញុំមិនដែលបានឃើញតាំងពីក្នុងរយៈកាលស៊ើបអង្កេតរហូតមកដល់ខ្ញុំធ្វើជាសាក្សីលើកទី១ ពីថ្ងៃ១៩ ខែ៣ រហូតដល់ថ្ងៃ ១០ ខែ៤ ២០១២ នោះទេ។ ឯកសារនេះ ខ្ញុំអត់ដែលឃើញទេ ប៉ុន្តែដោយឡែកខ្លឹមសារនេះ ខ្ញុំនិយាយពីខ្លឹមសារវិញ ឯកសារនេះជារបស់អ្នកណាខ្ញុំអត់និយាយទេ តែខ្លឹមសារ គឺពិតជាទាក់ទងនឹងខ្លឹមសារដែលប៉ុល ពត គាត់ណែនាំ ពេលដែលខ្ញុំទៅរៀន គឺពិតជាទាក់ទងអ៊ីចឹង ហើយខ្ញុំចេញមកថ្ងៃណោះ ខ្ញុំចេញមកពីរនាក់មិត្តហ៊ុយ អ៎! សុំទោស ពីរនាក់មិត្តហ៊ឺ ឲ្យមិត្តហ៊ុយ នៅដេកនឹងនេះចុះ ខ្ញុំមកផ្ទះ។ ដល់ហៅពួកអ្នកសួរចម្លើយមកឧទ្ទេសនាមឯកសារហ្នឹងទាំងយប់ហ្នឹង កន្លះម៉ោង មួយម៉ោង ពីពីរមួយម៉ោង ពីរម៉ោង ខ្ញុំចប់ ព្រឹកឡើងគេរៀនទៀត។ ដូច្នេះទាក់ទងពិត តាមការណែនាំរបស់ ប៉ុល ពត នៅក្នុងវគ្គនុំង។

**ស៖** នៅក្នុងកំណត់ត្រានេះ ក៏បាននិយាយថានៅពេលខាងមុខ គឺមិនត្រូវវ៉ៃអ្នកទោសខ្មែរ ប៉ុន្តែ ប្រើប្រាស់ការងារសន្តិបាលជាមួយជនជាតិវៀតណាម ពួកចក្រពត្តិអាមេរិក។ ថាតើប៉ុល ពត គាត់មាន ពន្យល់ហេតុផលអីបានទៅធ្វើអ៊ីចឹងទេ?

**ឆ៖** អានេះ វាជាគោលការណ៍ ជាវត្ថុបំណងរបស់ស-២១ ក្នុងការសួរចម្លើយអ្នកទោស យើង មានពិសោធហើយ ដូច្នេះរៀនទៅ ធ្វើម៉េចអ្នកទោសខ្មែរកុំវ៉ៃ យកឲ្យបានចម្លើយពី ៨០ ទៅ -- ពី ៧០ ទៅ៨០ ភាគរយ។ នេះជាគោលគំនិតខ្ញុំដែលខ្ញុំរាយការណ៍នៅក្នុងអង្គប្រជុំ ព្រោះផែនការខ្ញុំគិតអ៊ីចឹង ថា កុំវ៉ៃអ្នកទោសខ្មែរ ឯចំណែកយួន តាមធម្មតា។ សេ.អ៊ី.អា វ៉ៃតាមធម្មតា។ នេះខ្ញុំរាយការណ៍នៅក្នុងនុ៎ង ឯចំណែក បងប៉ុល គាត់ណែនាំមកវិញគាត់ថា "អត់ អត់សួរ"។

[១១:១៧:៤៥]

**ស៖** ប៉ុន្តែនៅក្នុងកំណត់ត្រាហ្នឹងសរសេរថា នៅពេលខាងមុខ ឆាប់ៗនេះ គឺនឹងផ្លាស់ប្តូរវិធី សាស្ត្រសួរចម្លើយ គឺមិនវ៉ៃ<អ្នកទោស>ខ្មែរទេ ប៉ុន្តែសម្រាប់រយៈពេលបណ្តោះអាសន្នហ្នឹង គឺវិធី សាស្ត្រចាស់ហ្នឹង គឺជាបន្តដដែល។ ដូច្នេះតើប៉ុល ពត បានប្រាប់ឲ្យលោកបន្តក្នុងពេលបណ្តោះអាសន្ន ហ្នឹង ឬមួយក៏នួន ជា គាត់បានប្រាប់លោកនៅពេលក្រោយមកទៀតថា ឲ្យបន្តអនុវត្តវិធីសាស្ត្រដដែល ហ្នឹងក្នុងពេលអន្តរកាលហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំបាននិយាយហើយថា នៅក្នុងវគ្គរៀនសូត្រនេះ គោលគំនិតដែលលុបបំបាត់ការធ្វើ ទារុណកម្ម ជាគោលគំនិតរបស់ស-២១ ខំពុះពារធ្វើម៉េចលះបង់ការធ្វើទារុណកម្មចំពោះជនជាតិខ្មែរ។ នេះខ្ញុំរាយការណ៍ទេ ចំណែកសេចក្តីសម្រេចរបស់បងប៉ុលថ្ងៃនោះ គឺអត់សួរ សឹងតែនិយាយថាអត់ចាប់ ប៉ុន្តែគាត់និយាយខ្លីថា "អត់សួរ"។ ហើយដល់ក្រោយមកបងនួនហៅខ្ញុំទៅធ្វើការ ខ្ញុំមិនដឹងធ្វើម៉េច បើខ្ញុំ ប្រាប់កូនចៅថាអត់សួរ។ ដល់ខ្ញុំហៅទៅធ្វើការ ខ្ញុំង៉េះង៉ោះៗឆ្លើយអីនឹងគាត់មិនរួច, គាត់ថា "យី! មិត្តឌុច គេរៀនចេះមាត៌ាសម្ងើមណាស់ណា"។ គាត់ស៊កឲ្យខ្ញុំប៉ុណ្ណឹង ហើយក៏ខ្ញុំចេញមក។ ប្រជុំកូនចៅ ថា៖ "អើឥឡូវសួរធម្មតាតទៅទៀត" នេះវាបត់បែនអ៊ីចឹង រឿងរ៉ាវ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងសួរលោកប្រធានបទថ្មីមួយទៀតទាក់ទងនឹង វន វ៉េត គឺជាអ្នកដែលលោក ធ្វើការជាមួយក្នុងពេលដែលលោកនៅ ម-១៣ <ហើយបានក្លាយជាសមាជិកគណៈអចិន្ត្រៃយ៍>។ តើ លោកអាចប្រាប់បានទេ តើ វន វ៉េត ត្រូវបានគេចាប់ខ្លួននៅពេលណា និងនៅទីណា?

**ឆ៖** អរគុណ។ បងវន ត្រូវគេចាប់ខ្លួនទៅជាមួយនឹង បងអន ហើយនិង កី បញ្ជូនទៅស-២១។

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

អ្នកដែលដឹកនាំចាប់ គឺ មិត្តលីន កម្លាំងដែលទៅចាប់នោះ គឺកងការពារមជ្ឈិម។ ហើយក្នុងពេលចាប់ ហ្នឹង បងម៉ុក ជាបញ្ជាការ គឺចាប់នៅក្នុងមន្ទីរមជ្ឈិម ក្រោយពីការប្រជុំហើយ។ ថ្ងៃនោះ បើតាមការ អធិប្បាយជាកំប្លុកកំប្លែង សើចរបស់ បងស៊ិន ប្រពន្ធ បងនួន នេះ គាត់ថា បងពក គាត់ភ័យពេក រត់ ចូលក្រោមគ្រែ។ ឯចំណែក បងពក ថ្ងៃក្រោយមក ខ្ញុំជួបគាត់ អង្គាល់ខ្ញុំនៅក-១៨ គាត់ថាថ្ងៃនោះ បងម៉ុក គាត់ចេញមក បញ្ជាឲ្យចាប់ ដូច មិត្តលីន បញ្ជាដែរ។ ពេលហ្នឹង បងម៉ុក ជាអ្នកបញ្ជា។ ហើយគេចាប់ មកហ្នឹង គេអត់ដាក់ខ្នោះទេ គេយកខ្សែអាស្ទីខ្សែរបស់អាល្លឺម៉ង់ ទាញខ្ទាច់អ៊ីចេះទៅ វាអត់ៗនេះ រលា ទៅវិញទេ បញ្ជូនមក។ ហ្នឹងរឿង វន វ៉េត គេបញ្ជូនទៅដល់ស-២១ព្រលប់ៗហើយ ល្ងាចហើយ ម៉ោង ប្រាំមួយ ប្រហែលម៉ោងប្រាំកន្លះ ទៅម៉ោងប្រាំមួយហើយ គេចាប់ឯមន្ទីរមជ្ឈិមឯណោះទេ។

[១១:២១:៥៧]

**ស៖** អ៊ីចឹង គឺថាការចាប់ខ្លួនហ្នឹង ធ្វើឡើងនៅចុង នៅពេលបញ្ចប់កិច្ចប្រជុំ អាចជាសមាជបក្ស ឬក៏កិច្ចប្រជុំគណៈមជ្ឈិម។ អ៊ីចឹងការចាប់ខ្លួនហ្នឹង គឺចាប់ខ្លួននៅពេលដែលមានសមាជិកគណៈមជ្ឈិម ដទៃទៀត ឃើញការចាប់ខ្លួនមនុស្សទាំងអស់នេះដែរ តើមែនទេ?

**ឆ៖** អ្នកណាឃើញខ្លះ ខ្ញុំអត់ដឹងទេ ក៏ប៉ុន្តែមានអ្នកពួនក៏មានដែរ ពួនមិនទៅអើតកន្លែងនុ៎ង គឺ បងប៉ុល ហើយនិង បងនួន ហ្នឹងប្រហែល។ សុំទោស គឺ បងប៉ុល និយាយឲ្យមួយម៉ាត់ទៅ ខ្ញុំមិននិយាយ ប្រហែល បងនួន ទេ តែប្រហែលចូលក្នុងស្មានហើយ ព្រោះគាត់ចូលចិត្តគេចឲ្យឆ្ងាយពីសមរភូមិអ៊ីចឹងៗ ។ ឯចំណែកអ្នកទៅបញ្ជា គឺ បងម៉ុក។ ឯចំណែក្មេងៗអ្នកចាប់ គឺពួក មិត្តលីន។ ហើយតាមសម្តី បង ពក ដែលជួបខ្ញុំប្រហែលជានៅក្នុងឆ្នាំ២000 អុះ! ១៩៩៩ -- ១៩៨៩។ គាត់ថា ដល់ពេលនេះទៅ បងប៉ុល ឃាត់គាត់ឲ្យនៅសិន កុំអាលទាន់មកផ្ទះ។ ដល់ចាប់ បងវន ហើយ បានៗ បងប៉ុល ថា “ម៉េច ឃើញ កុនគេល្អមើលទេ?” គាត់សួរអ៊ីចឹង។ នេះតាម បងពក និយាយជាមួយខ្ញុំ។ ដូច្នេះអ្នកណាឃើញខ្លះ អ្នក ណាអីខ្លះ ខ្ញុំមិនដឹងទេ ប្រហែលជាសមាជិកមជ្ឈិមថ្មីអត់បានឃើញទេ។ ពេលនោះ មហាសន្និបាតបក្ស មជ្ឈិមថ្មី មាន មិត្តសាន, មិត្តវឿន អីនុ៎ង។

**ស៖** ឥឡូវនេះ ខ្ញុំនឹងនិយាយអំពីការសួរចម្លើយ វន វ៉េត ម្តង។ តើអ្នកណាជាអ្នកសួរចម្លើយ គាត់ តើមានការធ្វើទារុណកម្មដែរឬទេ? ប្រសិនបើមាន តើគេធ្វើទារុណកម្មបែបណា ហើយតើថ្នាក់លើ ណែនាំមកលោកយ៉ាងម៉េចខ្លះ ទាក់ទងទៅនឹងការសួរចម្លើយ វន វ៉េត នេះ?

**ឆ៖** ខ្ញុំសូមជម្រាបថា ការសួរចម្លើយ បងវន នេះ ខ្ញុំឲ្យ មិត្តប៊ុន ធ្វើ។ ប៉ុន្តែមុននឹងប្រគល់ បង

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

វន ទៅឲ្យ មិត្តប៉ុន ក៏គេចាប់គាត់ពីល្ងាចថ្ងៃ០២ ខែ១១ ១៩៧៨។ ព្រឹកឡើង ខ្ញុំងើបពីព្រលឹមទៅ ទៅជួប បងវន។ ខ្ញុំសួរគាត់ពីរឿងខ្លះ ពីសភាពការណ៍ បងប៉ុល យ៉ាងម៉េច អីយ៉ាងម៉េច បានជាគាត់ត្រូវគេធ្វើទុក្ខបុកម្នេញអីចឹង។ បងវន គាត់ឆ្លើយថា "មនុស្ស បងប៉ុល នេះជាមនុស្សត្រដេវរិច អត់ជឿទុកចិត្តអ្នកណាទេ មានតែ បងរ៉ាន់ គ្នាគាត់ទើបគាត់ចេះអត់ឱន"។ ខ្ញុំ គាត់ឃើញថា ខ្ញុំមានកម្មករប្រមាណ ៥០.០០០ ឬ ៥០០.០០០ នៅក្នុងដៃ ម្ល៉ោះហើយគាត់ខំសម្លឹងមើលលើមើលក្រោម ខ្លាចខ្ញុំក្ដាប់កម្លាំងកម្មករទាំងអស់នោះ។

សូមបញ្ជាក់ថា ពាក្យ "ត្រដេវរិច" នេះជាពាក្យខ្មែរ គេប្រើសម្រាប់អ្នកដែលគិតតែពីខ្លួន ខ្លាចគេសម្លាប់ ខ្លាចគេលួចធ្វើឃាត។ ដែលអង់គ្លេសហៅថា "*ផេណូរៀ*" ឬក៏បារាំងហៅ "*ប៉ាន់ណូរីយ៉ា*"។ នេះខ្ញុំបានទៅជួប បងវន ប៉ុណ្ណឹង ដើម្បីសូមទោសគាត់។ ប៉ុន្តែមុននឹងចូលទៅហ្នឹង គាត់ហៅហើយ "អាឃាតករ" ហៅខ្ញុំ ខ្ញុំនៅតែដើរឱនលំទោនចូលទៅរកគាត់ ព្រោះគាត់ជាគ្រូចាស់ ជាអ្នកបង្រៀនការងារបដិវត្តន៍ចាស់ដល់ខ្ញុំ ជាអ្នកឲ្យខ្ញុំចូលបក្ស សម្រេចឲ្យខ្ញុំចូលបក្ស។ ដូច្នេះ ខ្ញុំនិយាយពីរឿងសួរចម្លើយ អ្នកដែលសួរចម្លើយគឺ មិត្តប៉ុន ប៉ុន្តែមុននឹងប្រគល់ឲ្យ មិត្តប៉ុន ខ្ញុំបានទៅជួប បងវន ប៉ុណ្ណឹងឯង។ ដល់ក្រោយឲ្យ មិត្តប៉ុនៗ គេមានធ្វើទារុណកម្មមួយបែប។ ខែ១១ នេះជាខែរងារ គេយកកង្ហារទៅបើកៗ ហើយគេបាចទឹក ឬក៏ស្រោចទឹក បងវន នោះឲ្យរងារ។ ដូច្នេះវ៉ៃអត់មានទេ បាចទឹកឲ្យរងារប៉ុននុ៎ងឯង។ នេះទារុណកម្មរបស់បង -- ទៅលើរូប បងវន។

[១១:២៧:៣១]

**ស៖** ខ្ញុំសួរឲ្យលោកបញ្ជាក់បន្តិចទៀតសិន។ ឥឡូវនេះ ខ្ញុំសូមអានន្ទូវកិច្ចសម្ភាសន៍ខែឧសភា ៩៩ របស់លោក <ដើម្បីកំណត់ត្រាប្រតិចារឹក> គឺថា ខ្ញុំ<មិនអាចចាំបានទេ ខ្ញុំបានចំហឈ្មោះនោះចោលកាលពីម្សិលមិញ>។ ឥឡូវនេះ ដើម្បីបញ្ជាក់ឲ្យច្បាស់ គឺឯកសារ <E3/347> <កិច្ចសម្ភាសន៍ធ្វើចាប់ពី>ថ្ងៃ<០៤> ដល់ថ្ងៃ០៦ <ឧសភា ១៩៩៩> គឺជាការសម្ភាសជាមួយ គ្រីស្តូហ្វ <ប៉េស៊្វ> មកពីឧត្តមក្រុមប្រឹក្សាទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ ខ្មែរមានលេខ 00160905, អង់គ្លេសមានលេខ <00185026>, បារាំងមានលេខ 00160948 ដល់ 49 គឺឯកសារ E3/347 គឺនៅខែឧសភា ឆ្នាំ១៩៩៩៖ "សមមិត្តប៉ុន និង វន វ៉េត នៅពេលដែលគាត់មិនពេញចិត្តជាមួយនឹងចម្លើយសារភាពរបស់ វន វ៉េត គាត់ឲ្យ វន វ៉េត និយាយអំពីយួន ហើយថា យួនបានវាយប្រហារ ប្រសិនបើយួនមានវាយប្រហារ តើយើងចាញ់ ឬក៏ ឈ្នះ។ នៅពេលដែលនិយាយនេះ នៅពេលដែលនិយាយ វន វ៉េ

ត និយាយថា យួននឹងឈ្នះ។ <គាត់>ចាក់ទឹកកកទៅលើ <វន វ៉េត>។ គាត់ជាមនុស្សចាស់ ហើយគាត់រងារ។ ការធ្វើទារុណកម្មដែលប្រើប្រាស់នៅលើ វន វ៉េត គឺទឹកត្រជាក់ គេដាក់ទឹកកកចូលទៅក្នុងទឹក ហើយបន្ទាប់មកគេស្រោចទៅលើគាត់។ វន វ៉េត ត្រូវបានគេចាក់ទឹកកកពីលើ ហើយបន្ទាប់មកទៀតគេបើកកង្ហារ"។ សូមបញ្ចប់ការដកស្រង់។

តើលោកអាចបញ្ជាក់បានទេ ថាៗ តើគេដាក់ វន វ៉េត ចូលទៅក្នុងទឹក ទឹកកក ឬក៏គ្រាន់តែគេជះទឹកត្រជាក់ទៅលើគាត់ ហើយបើកកង្ហារ ឬមួយក៏លោកមិនប្រាកដថាតើគេធ្វើយ៉ាងម៉េចជាមួយ វន វ៉េត នៅក្នុងទឹកកក ទឹកត្រជាក់នោះ?

**ឆ៖** រឿងហ្នឹងមានការជជែកគ្នាម្តង។ អ្នកដែលចោទប្រកាន់ខ្ញុំថា ខ្ញុំដាក់ បងវន ទៅក្នុងធុងទឹកកក។ អ្នកដែលចោទប្រកាន់ហ្នឹងគឺ អាឡិចហ្សាន់ដឺ ប៊ែត។ ខ្ញុំថា បើដាក់ បងវន ទៅក្នុងធកុងទឹកកក ហើយ គេចង់បើកកង្ហារធ្វើស្អី? ដូច្នេះ ខ្ញុំបង្គាប់ថា គេដាក់ទឹកកកទៅក្នុងធុង ហើយគេជះអាទឹកកកហ្នឹងទៅលើ អាកង្ហារគេបើកទៅ។

[១១:៣០:៤៨]

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតសុំប្រហែលជា ៣០ទៅ ៤០នាទី ក្រោយពីសម្រាកអាហារថ្ងៃត្រង់ដើម្បីបន្តការសួរចម្លើយ -- ការសួរដេញដោលរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតហើយជាសំណើរបស់ខ្ញុំជូនចំពោះលោកប្រធានក៏ដូចជាអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតផ្តល់រយៈពេល៣០នាទីបន្ថែម។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ហើយនិងសាក្សីទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការរៀងៗខ្លួន ហើយនិងបង្គាប់ឲ្យនាំខ្លួនលោក ខៀវ សំផន មកចូលរួមសវនាការ

នៅក្នុងបន្ទប់សវនាការនេះ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ ហើយលោកសាក្សី លោក កាំង ហ្កេកអ៊ាវ ឲ្យគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមជម្រាបសួរលោកសាក្សី លោកស្តាប់ខ្ញុំឮទេ? មុននេះ យើងបាននិយាយអំពីការសួរចម្លើយ វន វ៉េត។ ឥឡូវនេះខ្ញុំចង់សួរលោកបន្តិច តើ នួន ជា គាត់មានបានតាមដានការវិវត្តន៍ទៅនៃការសួរចម្លើយ វន វ៉េត ដែរឬទេ? ចំពោះអ្នកទោសដែលមានឋានៈខ្ពង់ខ្ពស់ដូច វន វ៉េត អ៊ីចឹង តើលោកចាំបាច់ត្រូវឲ្យមានការអនុម័តយល់ព្រម ឬក៏មានការបញ្ជាពីថ្នាក់លើដែរឬទេ នៅពេលដែលប្រើទារុណកម្មនោះ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ការសួរចម្លើយ បងវន, ពូនួន តាមដានធម្មតា មិនដូចជា បងខៀវ នៅពេលដែលខ្ញុំសួរចម្លើយ កុយ ធួន ទេ ខុសគ្នា។ គាត់តាមដានធម្មតា។ ឯចំណែកការធ្វើទារុណកម្ម គាត់មិនអើពើប៉ុន្មានទេក្នុងរឿងជាមួយ បងវន តាំងពីពេលដែលខ្ញុំទៅជួបគាត់ ដូចខ្ញុំនិយាយហើយ បងវន គាត់ប្រាប់ គាត់ថា "មិត្តអើយ! បងប៉ុល ពិបាកណាស់ណ៎ា មនុស្សត្រដេវរិច" ឃើញខ្ញុំមានកម្មករប្រមាណ ៥០.០០០ ម៉ឺន ឬ៥០០.០០០ ខ្ញុំមិនច្បាស់ទេ នៅនឹងដៃ គាត់មើលលើមើលក្រោមគិតគួរជានិច្ច បានពេលនោះ បងនួន ឆ្លើយ៖ "អ្ហូ! មិនមែនតែវាទេអ្ហ៎ា វាមានគេមានឯង អា៥០.០០០នាក់កម្មករនោះ ចំនួន

៥០.០០០ នាក់ហ្នឹង មិនមែនមានតែ បងវន ម្នាក់ឯងទេ វាមានគេ មានឯង”។ ដូច្នេះ បងប៉ុល គាត់មិនទទួលទេ គាត់ចង់និយាយអ៊ីចឹង។ ហើយក៏ខ្ញុំចាប់ផ្ដើមសួរចម្លើយទៅ។ ដល់ចុងបញ្ចប់ ខ្ញុំថាខ្ញុំមិនស្មានថា នែ!ស្ទើរិស្វករ កែវ ផាត នោះដែល បងវន ឆ្លើយដាក់នោះថាជាមេគាត់នោះ ក៏មិនស្មានថាដល់ប៉ុណ្ណឹង។ អាហ្នឹងខ្ញុំគ្រាន់តែជម្រាបប៉ុណ្ណឹងទេ ឲ្យថា បងនួន គាត់តាមដានជាប់ដូចជា បងខៀវ តាមដានក្នុងករណីបងឃួន អត់ទេ។

[១៣:៣៦:១៥]

**ស៖** ខ្ញុំនឹងសួរលោកឲ្យជាក់លាក់បន្តិច ឥឡូវនេះប្រសិនបើលោកចង់ពន្យល់បន្ថែម លោកអាចប្រាប់យើងខ្ញុំបាន។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក E3/106, ខ្មែរមានលេខ 00177627, អង់គ្លេសមានលេខ <177637>*(ស៊ីក)*, បារាំងមានលេខ 00177648 គឺឯកសារ E3/106។ ពាក់ព័ន្ធទៅនឹងការសួរចម្លើយ <វន វ៉េត> លោកបានឆ្លើយដូចតទៅនេះ៖ “យើងមិនត្រូវភ្លេចទេថា នួន ជា តាមដានការសួរចម្លើយនេះដោយម៉ត់ចត់ ហើយគាត់ត្រូវការចម្លើយសារភាពពេញលេញ។ ទោះបីថាខ្ញុំគោរព សុន សេន និង វន វ៉េត ប៉ុន្តែខ្ញុំនៅតែខ្លាច នួន ជា។”

ហើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ E3/5771, ខ្មែរមានលេខ <00185492>, អង់គ្លេសមានលេខ 00185500 ដល់ 501, បារាំងមានលេខ 00185509។ លោកបាននិយាយអំពីការរបាយការណ៍ស៊ើបសួរចម្លើយទៅ សុន សេន លោកនិយាយថា៖ “គ្រាន់តែយុទ្ធជនសាមញ្ញគឺ <ហ៊ី បានគ្រប់គ្រងអ្វីៗទាំងអស់ ហើយ>អាចប្រើប្រាស់ទារុណកម្ម។ ប៉ុន្តែចំពោះអ្នកទោសសំខាន់ដូចជា យ៉ា, សុន សេន បានបញ្ជាឲ្យខ្ញុំ ហើយគាត់គឺជាអ្នកសម្រេចទៅលើការធ្វើទារុណកម្ម ឬក៏អត់។” ថាតើអ្វីដែលខ្ញុំអានឲ្យលោកស្ដាប់ហ្នឹងធ្វើឲ្យលោកនឹកឃើញដែរឬទេ សម្រាប់មនុស្សដូចជា វន វ៉េត ជាដើមហ្នឹង គឺលោកចាំបាច់ត្រូវទទួលបានការយល់ព្រម នួន ជា ដើម្បីធ្វើទារុណកម្ម<សមាជិក>គណៈអចិន្ត្រៃយ៍<>ហ្នឹង តើលោកនឹកឃើញទេ?

[១៣:៣៨:៣២]

**ឆ៖** ខ្ញុំជូនជាការប្រៀបធៀបអំមិញនេះ តាមពិតគឺវាស្ថិតនៅក្នុងក្របខ័ណ្ឌដែលខ្ញុំឆ្លើយ នៅក្នុងឯកសារកន្លងមកហ្នឹងហើយ ប៉ុន្តែបើករណី បងខៀវ, ករណីបង សុន សេន ចំពោះការសួរចម្លើយ យ៉ា, ចំពោះការសួរចម្លើយ កុយ ធួន, ចំពោះការសួរចម្លើយ ទុំ, គាត់ចូលរួមហ្មង គាត់ណែនាំតាមទូរស័ព្ទឲ្យធ្វើអ៊ីចេះ ឲ្យធ្វើអ៊ីចុះ។ ដោយឡែក ការសួរចម្លើយ ទុំ បើតាមខ្ញុំចាំគាត់មកផ្ទះខ្ញុំ គាត់អញ្ជើញមកផ្ទះ

ហើយគាត់សរសេរសំបុត្រក្លែងមួយ គាត់សរសេរសំបុត្រមួយទៅឲ្យ បងទុំ សារភាពទៅ។ រួចដល់ទៅគាត់ "ទេអ្អេស ឲ្យខ្ញុំហៅម៉េច មិត្តទុំ ឬអាទុំ ទេមិនកើតទេ"។ ដូច្នេះ គាត់ធ្វើជាសរសេរសំបុត្រមកខ្ញុំថា "មិត្តឌុច ប្រាប់មើល បើទុំ គេសារភាពអាហ្នឹងយើងគិតគូរតាមហ្នឹង"។ ដូច្នេះ គាត់ចូលរួមក្នុងករណីនេះជាប់ ជាពិសេស កុយធួន, សុន សេន ក៏ដូចអន្ទះសាមែនទែន។ ដូច្នេះ រឿងសួរចម្លើយ កុយ ធួន អីហ្នឹងគាត់ដឹងថាខ្ញុំអត់ធ្វើទារុណកម្ម។ ហើយសួរចម្លើយនេះ ចុងក្រោយបំផុតមក ខ្ញុំសួរអត់ចេញ មិត្តប៉ុនក៏មិនចេញ -- អ៊ំ! មិត្ត ជាពិសេសមិត្តប៉ុន។ មិត្តប៉ុន ក៏សួរមិនចេញ ខ្ញុំរុញទៅឲ្យ ទុយ។ ពេលហ្នឹងមកគាត់ នែ! បង១ សុន សេន គាត់ឈប់ តាមដានជាប់ហើយ។ ឯចំណែក កុយ ធួន អ៊ំនែ! បងវន ខ្ញុំទៅរាយការណ៍ជូន១ ពូនួន។ ខ្ញុំទៅរាយការណ៍ជូន ពូនួន ហួរហែអ៊ីចឹងទៅ កាលណាបានបីបួនសន្លឹក ខ្ញុំទៅរាយការណ៍ម្តង គាត់ហៅទៅ ពីរបីថ្ងៃគាត់ហៅទៅ។ ដល់ចុងបញ្ចប់បានសំណុំរឿងមួយពេញលេញ ខ្ញុំជូនទៅគាត់។ ដូច្នេះ អារឿងការធ្វើទារុណកម្ម ចំពោះបងវន ខ្ញុំដូចជាមិនចាំ ថាគាត់ចូលល្អិតល្អក់ដែរមកក្នុងស-២១ ល្អិតទេ។ តាមពិត បងវន ពេលខ្លះ -- អ៊ំ! ពូនួន ពេលខ្លះគាត់លូកល្អិត ល្អិតហ្នឹង ល្អិតទាល់តែជ្រុល ខ្ញុំអស់សំណើចដែរ ដូចរឿងចាប់បុគ្គលម្នាក់ ឈ្មោះ ម៉ុល ការិន ហៅក្តាត។ ដល់ទៅគាត់ណែនាំខ្ញុំតាមរយៈ សុន សេន។ គាត់ថា៖ "ឲ្យប្រាប់អាក្តាតមើល៍ ថា ហ៊ូ នឹម ដែលគេចាប់ទៅហ្នឹង វាឆ្លើយសារភាពអស់ហើយ ឥឡូវគេយកទៅនេះវិញហើយ" ឲ្យខ្ញុំយកយុទ្ធវិធីហ្នឹងទៅប្រើ។ ខ្ញុំថា៖ "យុទ្ធវិធីនេះសាបហើយ" ខ្ញុំអត់ធ្វើ។ បន្តិចទៀត បងខៀវ ណែនាំមកទៀត ថា៖ "បងនួន ណាគាត់ប្រាប់ឲ្យធ្វើអ៊ីចឹង"។ ខ្ញុំ អ្ហឹះ! ទាល់ច្រកហើយ ឥឡូវត្រូវតែធ្វើ ព្រោះយុទ្ធវិធីហ្នឹងយើងយក១ចម្លើយអត់បានទេ ភរគេហ្នឹង។ ដូច្នេះ បងនួន ពេលខ្លះគាត់ចូលជ្រៅ ប្រឡូកជ្រៅល្អិតមែនទែន មិនទុកឲ្យស-២១ គេមានយុទ្ធវិធីរបស់គេ។ ដូច្នេះពេលខ្លះគាត់ចូលជ្រៅមកអត់ប្រយោជន៍អ៊ីចឹង ក៏ប៉ុន្តែពេលខ្លះគាត់បណ្តោយតាមធម្មតា ដូចករណី បងវន អ៊ីចឹង គាត់បណ្តោយតាមធម្មតា។ ដូច្នេះ ខ្ញុំមិនចាំថាការណ៍ដែលធ្វើទារុណកម្ម បងវន គឺគាត់សម្រេចទេ។ គឺស-២១ សម្រេច។

[១៣:៤២:២២]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំនឹងនិយាយបន្តពីការសួរចម្លើយ កុយ ធួន វិញ។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារជូនសាក្សី គឺជាចំណារមួយចំនួននៅក្នុងចម្លើយសារភាពរបស់ កុយ ធួន E3/1604 ព្រមទាំងរូបថត E3/2360។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារ E3/1604 និង <E3/2360>។ សូមលោកប្រធានអនុញ្ញាត។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** <ខ្ញុំសូមអនុញ្ញាតដាក់បង្ហាញលើអេក្រង់ផង។ បើមើលនៅទំព័រទី១ លោកសាក្សី ហើយដើម្បីជាប្រតិចារឹកផងដែរ នេះ>គឺ<ជា>ចំណារមួយ <ដែលនៅក្នុងភាសាខ្មែរទំព័រ 00006159 អង់គ្លេស 00769831 និងបារាំង 00766795 ហើយអក្សរសរសេរដៃ>នេះ គឺនៅបន្ទាប់។ ខ្ញុំសូមអនុញ្ញាតបង្ហាញទំព័របន្ទាប់ គឺ 6159។ ចំណារនេះ គឺនៅខាងឆ្វេងដៃ ខ្ញុំដាក់ពណ៌លឿងដើម្បីបង្ហាញ ហើយចំណារនេះបានសរសេរដូចតទៅនេះ៖ “បន្ទាប់ពីយើងបាន<ចោះរន្ធ>មួយចំហៀង ទើបយើងទទួលបានចម្លើយនេះ”។ <ចំណារនេះចុះថ្ងៃ០៩ ខែមេសា ឆ្នាំ១៩៧៧។> ដូច្នេះ ខ្ញុំចង់ដឹងថាតើអ្នកណាជាអ្នកសរសេរ ឬក៏អ្នកណាជាអ្នកចារទៅលើចំណារមួយនេះ?

[១៣:៤៤:៤២]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ចំណារនេះ ជាចំណារ បងខៀវ – បងសុន សេន។

**ស៖** តើគេធ្វើអីដែរ ដែលគេថា “វាឆ្លើយ ពេលយើងចោះម្ខាងហ្នឹង” តើវាមានន័យយ៉ាងម៉េចដែរ?

**ឆ៖** ចម្លើយលើកទីប៉ុន្មានរបស់ បងឃួន ទេ ខ្ញុំឮបង សុន សេន ទូរស័ព្ទមកប្រាប់ខ្ញុំថា “មិត្តឌុចអាឃួន វាវាលដាលវាយកម្លាំងយើងហើយណ៎ា ចម្លើយវាណ៎ា” ខ្ញុំអត់ៗហ៊ានមាត់តបទេ “រឿងហ្នឹងមិត្តឯងមើលមើល៍ ឲ្យវាៗនិយាយឲ្យស្រួលណ៎ា វាលដាលកម្លាំងយើង”។ ដូច្នេះ ខ្ញុំក៏ទៅប្រាប់ បងឃួនឲ្យសរសេរម្ដងទៀតឲ្យស្រួល។ ដូច្នេះហើយបានៗជាខ្ញុំគិតថា ចម្លើយនេះ ពេលនេះ ចំណារនេះ វាទាក់ទងនឹងការដែល បងឃួន -- អ៎ន៎ែ! បងៗ បងខៀវ ទូរស័ព្ទមកខ្ញុំ ប្រាប់អំពីបញ្ហានេះ។ “វាឆ្លើយពេលយើងចោះម្ខាង”។ ចោះហ្នឹង គឺទម្លាក់ចោល ជម្រុះចោល ចម្លើយដែលវាឆ្លើយដាក់កម្លាំងយើង។

**ស៖** សូមលោកមើលទំព័របន្ទាប់ គឺទៅលើឯកសារដែលខ្ញុំផ្ដល់ឲ្យលោកផងដែរ គឺជាចំណារវែងនៅខាងឆ្វេងដៃ។ ចំណារនេះ គឺចុះថ្ងៃ០៨ ខែមីនា ៧៧ គឺឯកសារនៅទំព័រខ្មែរ 00006757, អង់គ្លេសមានលេខ 00773088, បារាំងមានលេខ 00965892។ ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់។ ខ្ញុំចង់សួរលោកបន្តិចទៅលើកថាខណ្ឌទី១ នៃចំណារនេះ។ “ពេលបងប្អូនដាក់ខ្នោះដៃ អាធុច

ឆ្លៀតសរសេររឿងនេះទៀត។ វាសុំស្នើលែងខ្នោះដៃ <ដោយនិយាយថា>ដាក់តែ៣ថ្ងៃបានហើយ។ វា<នឹង>សរសេររឿងសមមិត្តញឹម, បងភឹម។ ខ្ញុំសម្រេចចិត្តថាមិនឲ្យវាសរសេរទៀតទេ ហើយដាក់ខ្នោះដៃរហូតដល់១០ ទៅ១៥ថ្ងៃវិញ ព្រោះកន្លងមក វាប្រឌិតរឿង<ដើម្បីវាយប្រហារកម្លាំង>បក្ស។ ក្រោយ១០ ទៅ១៥ថ្ងៃ <ខ្ញុំនឹងសម្រេចដោះខ្នោះចេញ ប៉ុន្តែ>ប្រសិនបើវាសរសេររឿងអត់ប្រយោជន៍ យើងនឹងនៅតែបន្តដាក់ខ្នោះដដែល។" សូមបញ្ចប់ការដកស្រង់។ ខ្ញុំចង់សួរថា តើអ្នកណាជាអ្នកសរសេរចំណារមួយនេះ លោកសាក្សី?

**ឆ៖** អរគុណ។ ចំណារមួយនេះ តាមការដឹងជាហូរហែមកពីរឿងបងៗ បង សុន សេន គាត់ថា " អាឃួន វាឆ្លើយដាក់កម្លាំងយើង មិត្តប្រយ័ត្ន"។ ដូច្នេះចំណារនេះ នៅលើឯកសារ កុយ ធួន នេះ មុនថ្ងៃបរិច្ឆេទដែលគាត់សរសេរថា "វាឆ្លើយពេលយើងចោះម្ខាង។"។ ដូច្នេះចំណារនេះ វាមុនចំណារដែលលោកព្រះរាជអាជ្ញាអានអំមិញ។ ដូច្នេះរឿងនេះ វាទាក់ទងនឹងរឿងដែលគាត់ស្តីឲ្យខ្ញុំតាមទូរស័ព្ទ។ រួចគាត់ឲ្យខ្ញុំសរសេរម្ខាងទៀត -- អ៎! គាត់បញ្ជាឲ្យខ្ញុំ ឲ្យ កុយ ធួន គាត់សរសេរម្តងទៀត។ នេះ វាទាក់ទងគ្នាអ៊ីចឹង។

**ស៖** សុំទោស ខ្ញុំកាត់លោកបន្តិច។ តើវាជាអក្សររបស់លោក ឬក៏អក្សររបស់ សុន សេន? គឺអក្សរចំណារដែលនិយាយអំពីការដក ពីការដាក់ខ្នោះដៃ កុយ ធួន នេះ?

**ឆ៖** អក្សរ សុន សេន។

**ស៖** ហើយការយោងទៅលើ កុយ ធួន ថាកន្លងមក គាត់ប្រឌិតរឿងជាច្រើន ដើម្បីវាយប្រហារបក្សហ្នឹង។ ថាតើគេយោងទៅលើអ្វី ទើបគេនិយាយដូច្នេះ?

[១៣:៥០:០២]

**ឆ៖** អរគុណ។ ខ្ញុំបានរាយការណ៍ជូនអង្គប្រជុំជាច្រើនលើកច្រើនគ្រាហើយ ចម្លើយសារភាពរបស់ កុយ ធួន ខ្ញុំអត់បានៗមើលទេ អត់បានអានទាំងអស់ ព្រោះខ្ញុំគិតថា ខ្ញុំដឹងរឿងវ៉ាវមិនច្បាស់ទេ មិនល្អិតដល់ កុយ ធួន ទេ។ ដូច្នេះ បើសិនជាយកមកអាន ក៏មិនដឹងជាចាប់ចំណុចខ្សោយគេយ៉ាងម៉េច។ ដូច្នេះគាត់ឆ្លើយដាក់នរណា ស្អីនរណា ខ្ញុំអត់យល់ ឮតែមេទូរស័ព្ទមកអ៊ីចឹង ខ្ញុំថា យ៉ឹស ឆ្លើយដាក់នរណាស្អីនរណា។ អាហ្នឹងវាជាបញ្ហាមួយដែលយើងត្រូវតែធ្វើការតទៅទៀត។ អ៊ីចឹង ខ្ញុំណែនាំ បងឃួន។ ខ្ញុំប្រាប់ថា "បងអ្នា! ខាងលើមិនសុខចិត្តទេណ៎ា បងឯងឆ្លើយដាក់កម្លាំងបដិវត្តន៍ ឥឡូវសរសេរម្តងទៀតទៅ"។ ដូច្នេះរហូតមកដល់ថ្ងៃនេះ ចម្លើយ កុយ ធួន អត់ ខ្ញុំអត់ដែលបានអានទេ អត់យកចិត្តទុកដាក់។

ហើយខ្ញុំចាំតែមួយម៉ាត់ កុយ ធួន គាត់និយាយអំពីការដែលបក្សឲ្យគាត់កម្ទេច យ៉ុង។ យ៉ុង ហ្នឹងអតីតលេខាភូមិភាគឧត្តរមុនគាត់។ ខ្ញុំចាំតែមួយរឿងហ្នឹងឯង ដែលគាត់និយាយ។ រួចខ្ញុំបានចេះតែឆ្ងល់ កុយ ធួន គាត់ដឹងដែរ របៀបរបបធ្វើការងារនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា “ថាឆ្លើយក៏ស្លាប់ មិនឆ្លើយក៏ស្លាប់” ម៉េចក៏គាត់ឆ្លើយស្រួលម្ល៉េះ រួចខ្ញុំអត់ហ៊ានធ្វើទារុណកម្មផង ដូចខ្ញុំនិយាយអ៊ីចឹង ខ្ញុំគ្រាន់តែចេះវាយតម្លៃខ្លួនឯងទាបជាងគាត់យ៉ាងម៉េច ខ្ពស់ជាងគាត់យ៉ាងម៉េច ហើយឲ្យគាត់សរសេរ។ ព្រោះសំណួមពររបស់គាត់សរសេរទៅ ប៉ុល ពត។ ខ្ញុំតាំងខ្លួនជានីរសារ។ រហូតមកទល់ថ្ងៃនេះ ខ្ញុំរកតែយល់ចិត្តសាស្ត្រ កុយ ធួន អត់ទាន់ច្បាស់ទេ។ ខ្ញុំពិគ្រោះនឹង ស៊ារូនី –ហ្វ្រង់ស្វ័រ ស៊ារូនី ហ្គីលបូ– គាត់ថា “អ្ហេ! អាហ្នឹងវាអ៊ីចឹង វា១ដំណើរការខាងចិត្តសាស្ត្រ វាទៅអ៊ីចឹង” គាត់សរសេរនេះហើយ តាមចិត្តគាត់។ ដូច្នេះ ខ្ញុំនៅតែអត់យល់ទេ អារឿងចម្លើយ កុយ ធួន នោះបាទ។

[១៣:៥២:៤៥]

**ស៖** សូមអរគុណលោក។ ខ្ញុំសូមឲ្យលោកឆ្លើយតែសំណួរដែលខ្ញុំសួរបានហើយ ព្រោះខ្ញុំមានពេលតិចណាស់ ខ្ញុំនៅសល់ពេលតិច។ ដូច្នេះ ខ្ញុំចង់ឲ្យលោកមើលរូបថតមួយទៀតដែលខ្ញុំបានប្រគល់ជូនលោក ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ ឯកសារមានលេខ E3/2360។ ដូច្នេះ ខ្ញុំចង់សួរថា តើរូបថតហ្នឹងជារូបថតរបស់អ្នកណា? ហើយតើរូបថតហ្នឹងគេថតនៅកន្លែងណាដែរ? ខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់។

**ឆ៖** អរគុណ។ រូបថតនេះ គឺថតនៅនឹងកន្លែងដែលឃុំឃាំងគាត់ វាឲ្យគាត់សម្រាន្តនៅលើគ្រែផ្តៅមួយ ប៉ុន្តែគេដោះខ្នោះជើង។ ផ្ទះហ្នឹងខ្ញុំនៅចាំនៅស្រមៃឃើញ គឺនៅខាងត្បូងស-២១ ផ្ទះហ្នឹងបួនជាន់។ គាត់ ដាក់គាត់នៅជាន់លើបំផុត។

**ស៖** ខ្ញុំចង់សួរលោកថា តើនេះគឺជាកន្លែងដែលគេសួរចម្លើយគាត់មែនទេ?

**ឆ៖** ថាសួរចម្លើយក៏បាន។ ក៏ប៉ុន្តែតាមពិត ខ្ញុំទៅៗឲ្យគាត់សរសេរដាក់កៅអី អាកៅអីគេអង្គុយពាក់ស្បែកជើងនោះ ឲ្យវ៉ែនតាគាត់មួយ ឲ្យក្រដាសវ៉ាមបួនប្រាំសន្លឹកទៅ ហើយស្ទីលឡូមួយឲ្យគាត់សរសេរ។ ដូច្នេះមិនដែលបាននរណាទៅសួរគាត់ទេ ខ្ញុំមិនសួរ ព្រោះតែកាលណាសួរ ខ្ញុំបង្ហាញចំណុចខ្សោយខ្ញុំណាមួយឲ្យគាត់ឃើញ អ៊ីចឹងឲ្យគាត់សរសេរវិញ។

[១៣:៥៥:០៤]

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរអំពីបញ្ហាមួយទៀត គឺកាលបរិច្ឆេទដែលលោកចាប់ផ្តើមរាយការណ៍

ផ្ទាល់ទៅ នួន ជា។ លោកនិយាយថា កាលបរិច្ឆេទគឺ ១៥ សីហា ៧៧។ ខ្ញុំចង់សួរលោកមួយចំនួនទៅលើចំណុចនេះ។ តើ សុន សេន គាត់នៅទីក្រុងភ្នំពេញដែរឬទេ នៅពេលដែលលោកចាប់ផ្ដើមរាយ-ការណ៍ជូន នួន ជា? ឬមួយក៏ថា ការផ្លាស់ប្ដូរហ្នឹងគឺធ្វើឡើងនៅពេលដែល សុន សេន គាត់បានផ្លាស់ទៅសមរភូមិហើយ?

**ឆ៖** បងខៀវ ផ្លាស់ទៅសមរភូមិ និយាយឲ្យចំថ្ងៃ ខ្ញុំមិនចាំទេ ប៉ុន្តែខ្ញុំចាំថា ថ្ងៃ១៥ ខែសីហា ឆ្នាំ ១៩៧៧ បងនួន ឲ្យគេមកហៅខ្ញុំ ហើយយកទៅជួបគ្នានៅជាន់ទី២ នៃអគារកណ្ដាលរបស់ពុទ្ធិកៈវិទ្យា-ល័យព្រះសុរាម្រិត។ គាត់ប្រាប់ខ្ញុំថា មិត្តខៀវ ទៅសមរភូមិហើយ។ មិត្តត្រូវមកធ្វើការជាមួយនឹងខ្ញុំ។ ហើយខ្ញុំឲ្យ មិត្តប៉ង់ ចុះទៅ។

**ស៖** សំណួរបន្តរបស់ខ្ញុំ គឺជាសំណួរបាទ ឬក៏មិនមែន។ គឺថា នៅពេលដែលលោកឈប់រាយ-ការណ៍ទៅ សុន សេន ហើយចាប់ផ្ដើមរាយការណ៍ផ្ទាល់ទៅ នួន ជា។ តើពេលនោះ គឺវាក្នុងពេលប្រហែលគ្នានៅពេលដែល ចៅ សេង ត្រូវបានគេចាប់ខ្លួនដែរទេ? គឺខ្ញុំចង់និយាយអំពីពេលវេលាដែលលោកចាប់ផ្ដើមរាយការណ៍ទៅ នួន ជា។ តើពេលវេលាហ្នឹងគឺដូចគ្នា ឬប្រហែលគ្នាហ្នឹងពេលដែលគេចាប់ខ្លួន ចៅ សេង ដែរឬទេ?

**ឆ៖** រឿង ចាប់ខ្លួន ចៅ សេង នេះដំបូង សុន សេន ប្រាប់ខ្ញុំ។ បន្ទាប់មក ពូនួន ប្រាប់ខ្ញុំទៀត។ ដូច្នេះវាប្រដំប្រសងគ្នា។ សុន សេន ណែនាំឲ្យខ្ញុំកែឈ្មោះ កុំដាក់ ចៅ សេង ឲ្យដាក់ ចិន សួន។ ហើយអ្នកណាសួរកុំប្រាប់។ ដល់បន្ទាប់មក ពូនួន ហៅខ្ញុំទៅធ្វើការ។ ថា ចៅ សេង ទៅដល់ហើយ? បាទ។ ខាងក្រសួងការបរទេសគេសួរ កុំប្រាប់ណា៎ ទុកឲ្យគេមកសួរខ្ញុំ។ ដូច្នេះ វាជាន់គ្នាអ៊ីចឹង។

[១៣:៥៨:២៧]

**ស៖** ដូច្នេះ ហេតុផលដែលខ្ញុំសួរលោកបែបនេះ ព្រោះថា ខ្ញុំនឹងសួរដេញដោលលោកអំពីភស្តុតាងមួយចំនួនដើម្បីបញ្ជាក់ថាតើឯកសារហ្នឹងអាចជួយឲ្យលោកនឹកឃើញដែរឬទេ ទាក់ទងទៅនឹងការរាយការណ៍ផ្ទាល់ទៅ នួន ជា។ ទី១ គឺបញ្ជីរបស់ ក.ស.ច.ស ស្ដីពីអ្នកទោស ស-២១ ដែលនិយាយអំពីការចាប់ខ្លួន ចៅ សេង ដែលថា ចៅ សេង គាត់មានឈ្មោះ ហៅក្រៅច្រើន ដូចជា ចិន សួន ជាដើម ហើយវាធ្វើឡើងនៅក្នុងខែវិច្ឆិកា ឆ្នាំ៧៧។ គឺឯកសារដែលមានលេខ <១៤១៦៤> គឺនៅលេខរៀង <១៤១៦៤>នៅក្នុងបញ្ជីអ្នកទោសរបស់ ក.ស.ច.ស។ ចំណុចមួយទៀត គឺខ្ញុំចង់ប្រាប់លោកផងដែរ គឺការកត់ត្រាការផ្សាយសំឡេងរបស់វិទ្យុកម្ពុជាប្រជាធិបតេយ្យ បើសិនជាយើងមើលគឺនៅក្នុងខែកញ្ញា

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

តុលា ដែលបង្ហាញថា សុន សេន នៅក្នុងទីក្រុងភ្នំពេញនៅឡើយ នៅក្នុងពេលនោះ ហើយអាចបន្តរហូតទៅដល់ខែវិច្ឆិកាទៀត។ ហើយទី៣ ដែលខ្ញុំចង់សួរលោកផងដែរគឺថា ការនិយាយយោងមួយចំនួនទៅអ្នក -- ទៅសៀវភៅ<>អ្នកសួរចម្លើយ<របស់>លោក គឺកំណត់ត្រារបស់ ម៉ម ណៃ គឺឯកសារ E3/833, ខ្មែរមានលេខ 00077826, អង់គ្លេសមានលេខ 00184592 គឺជាកំណត់ត្រាខែកុម្ភៈ ៧៨ ហើយគាត់បានសរសេរ៖ “យួនវ៉ៃយើងខ្លាំងក្នុងខែវិច្ឆិកា ធ្នូ ឆ្នាំ១៩៧៧ ហើយចូលមកដីយើងប្រហែលជា៣០គីឡូម៉ែត្រ។” ហើយប្រហែលគ្នានេះដែរ នៅក្នុងសៀវភៅដែលយើងរៀបរាប់ថាជាសៀវភៅរបស់ ប៉ុន និង ទុយ គឺ E3/834, ខ្មែរមានលេខ 00077447 ហើយមួយទៀតគឺ 77456, អង់គ្លេសមាន 00184483 និង 48 -- 483 ដល់ 488។ គឺជាចំណារដែលនិយាយអំពីការវាយប្រហាររបស់យួននៅក្នុងខែតុលា វិច្ឆិកា ហើយគេវាយទ្រង់ទ្រាយមធ្យម ហើយបានបញ្ជាក់ថា “ទាហានយើងបានមកដល់ក្នុងខែធ្នូ”។ ហើយពីរបីទំព័រចុះមកក្រោមទៀត គឺបញ្ជាក់ថា “ខែធ្នូ ៧៧ គឺទាហាន<មជ្ឈិម>បានមកដល់”។ ហេតុផលដែលខ្ញុំសួរលោកទៅលើចំណុចទាំងអស់នេះ គឺវាទាក់ទងទៅនឹងពេលវេលា<នៃការផ្ដើយសារភាព>របស់ ចិន សួន <ឬក៏ការ>ចាប់ខ្លួន<គាត់>ក្នុងខែវិច្ឆិកា ៧៧ ហើយកំណត់ត្រាបានបង្ហាញផងដែរថា គឺនៅចុង៧៧ ដែលមជ្ឈិម ដែលកម្លាំងរបស់មជ្ឈិមត្រូវបានបញ្ជូនទៅចូលរួមនៅក្នុងសមរភូមិប្រយុទ្ធជាមួយទាហានវៀតណាម។ នៅពេលដែលយើងពិនិត្យមើលទៅលើចំណុចទាំងអស់នេះ តើវាអាចដែរឬទេ ដែលថាថ្ងៃ១៥ សីហា ៧៧ហ្នឹង គឺប្រហែលជាពន្យារ ឬក៏យឺតពីរបីខែ ឬក៏ចូលទៅដល់វិច្ឆិកា ដែលលោកពេលហ្នឹងទេ ទើបលោកចាប់ផ្ដើមរាយការណ៍ផ្ទាល់ទៅ នួន ជា នោះ?

[១៤:០២:១៧]

**ឆៈ** អរគុណ។ ខ្ញុំសូមបញ្ជាក់ថា មនុស្សសំខាន់ដែលចូលទៅស-២១។ ដំបូង មិត្តធី អត់បានកត់ត្រាទេ។ ព្រោះអី? ព្រោះមនុស្សសំខាន់ គេសម្ងាត់ មិនឲ្យ មិត្តធី ដឹង។ ដូច្នេះ កំណត់ត្រារបស់ មិត្តធី ចំពោះមនុស្សសំខាន់ កាលបរិច្ឆេទ អត់មានទេ។ នេះខ្ញុំបញ្ជាក់មួយ។ ឯមួយទៀត ថ្ងៃដែល បងនួនប្រាប់ខ្ញុំ គឺពិតជាថ្ងៃ១៥ សីហា ១៩៧៧។ ចាប់តាំងពីពេលនោះមក ខ្ញុំអត់ដែលបានឃើញមុខ បងសុន សេន ទេ។ ប៉ុន្តែមានការទាក់ទងគ្នាតាមរលកអាកាសខ្លះ ក្រៅរឿងស-២១។ ឧបមា ដូចជាគាត់មើលផែនទី អាខ្នាត១/៥០.០០០ទៅ គាត់ឃើញ “*អឺរ៉ា*”។ គាត់ឲ្យខ្ញុំបើកមើលវចនានុក្រម តើ “*អឺរ៉ា*” ហ្នឹងស្អី? បានខ្ញុំប្រាប់ថា “តំបន់”។ អានេះ ទាក់ទងគ្នាអ៊ីចឹង តាមរយៈអាកាស ហើយមានអាចុច ប៊ូតុងចុចវ៉ៃបំបែកប្រេកង់ផង បង្វែរប្រេកង់។ ទូរស័ព្ទហ្នឹងអ៊ីចឹង។ គេតេអូហើយ គេចូលទូរស័ព្ទមួយទៀត។

ដូច្នេះ ខ្ញុំមានការទាក់ទងដែរ។

ខ្ញុំសូមជូនភស្តុតាងខាងខ្ញុំវិញ។ ខ្ញុំសរសេរទៅគាត់ សុំយោបល់ពីរឿងក្មេងៗរឹអ្នកទោស។ ខ្ញុំសរសេរទៅ តាំងពីមុនគាត់ចេញទៅសមរភូមិ។ ប៉ុន្តែរហូតដល់ថ្ងៃ៥ ខែ១០ បានឃើញគាត់ឆ្លើយមកវិញ។ ខ្ញុំចេះតែរង់ចាំមើល តើការិយាល័យសហព្រះរាជអាជ្ញាយកអាឯកសារហ្នឹងមកបង្ហាញខ្ញុំទេ។ បើយកអាឯកសារហ្នឹងមកបង្ហាញ វាទៅជាឯកសារដោះបន្ទុកដល់ខ្ញុំ។ ក៏ប៉ុន្តែតាមពិត ដល់ក្រោយមក បងខៀវ អញ្ជើញមកប្រជុំការិយាល័យនយោបាយមជ្ឈិម បាន១គាត់សរសេរមកថ្ងៃ១០ ខែ១០។ ហើយឯកសារស-២១ហ្នឹង មួយចំនួននៅបង ខៀវ ចារ១ៗរហូតដល់ថ្ងៃ១១ ខែ១១ ១៩៧៧។ ហើយចំណែកមានអាឯកសារមួយគត់ដែលខ្ញុំសង្កេតឃើញ គឺគាត់ចារនៅថ្ងៃ២៥ ខែ១១ ៧៧។ ដូច្នេះ វាគ្រាន់តែបង្ហាញថា បងខៀវ អញ្ជើញមកភ្នំពេញប្រជុំអចិន្ត្រៃយ៍ការិយាល័យនយោបាយមជ្ឈិមបក្សនឹងគេ ទៀងទាត់។ រួចពីថ្ងៃនោះមក ពីក្រោយថ្ងៃ១៥មក -- អំ ពីក្រោយថ្ងៃ២៥មក បាន បងខៀវ ឈប់ស៊ីញ៉េលើអាឯកសារហ្នឹង។ ដូច្នេះរឿងហ្នឹងវាទៅអ៊ីចឹង។ បងខៀវ ពិតជាទៅសមរភូមិរវាងថ្ងៃហ្នឹង រួច ចៅ សេង ពិតជាចាប់នៅថ្ងៃ រវាងថ្ងៃ១៥ ខែសីហា ១៩៧៧ មែន។

[១៤:០៥:៣៥]

**ស៖** ខ្ញុំនឹងសួរលោកពីរបីសំណួរទៀត។ លោកបានទទួលស្គាល់ថា លោកមានការនិយាយតាមវិទ្យុទាក់ទងជាមួយ សុន សេន ទោះបីជាគាត់ទៅសមរភូមិមុខក៏ដោយ។ តើមានពេលណាមួយនោះដែលគេឈប់ឲ្យលោកទាក់ទងជាមួយនឹង សុន សេន ដែរទេ? ហើយបើគេឲ្យលោកឈប់ទាក់ទងជាមួយ សុន សេន មែន ថាតើវាមូលហេតុអីដែរនៅក្នុងឆ្នាំ១៩៧៨ ហ្នឹង?

**ឆ៖** អរគុណ។ ខ្ញុំជាអ្នកតូច ជាកូនចៅ ទាល់តែមេហៅមក បានខ្ញុំឆ្លើយ ខ្ញុំមិនដែលមាននឹកនាទៅហៅមេមុនទេ អត់។ ដូច្នេះពីក្រោយថ្ងៃដែលគាត់សួរចុះឡើងៗរឿងហ្នឹងទៅ គាត់មិនហៅធ្វើអីគាត់ អាកូនចៅវានៅតែចាំមើលៗមេទេ ដូច្នេះអត់មានអ្នកណាហៅ អត់មានអ្នកណាហាមឃាត់ទេ។

**ស៖** ខ្ញុំសូមដកស្រង់ចម្លើយរបស់លោកនៅខែឧសភា ១៩៩៩ គឺឯកសារE3/347, ខ្មែរ 00160918, អង់គ្លេស 00185050, បារាំង 00160970 គឺកិច្ចសម្ភាសន៍ជាមួយ គ្រីស្តូហ្វ ប៉េស្ស៊ូ សូមដកស្រង់៖ "ក្រោយពីលោកគ្រូ សុន សេន ទៅវាយជាមួយយួនអស់មួយរយៈពេលយូរមក ជិតដល់ពេលរំដោះទៅហើយ គឺជិតពេលដែលយួនចូលមានមនុស្សម្នាក់ដែលឆ្លើយដាក់ សុន សេន ខ្ញុំបានទៅសុំយោបល់ពី នួន ជា ថាខ្មាំងបានឆ្លើយពាក់ព័ន្ធនឹង បងខៀវ ហើយ នួន ជា បានគិតពីរបីនាទី ហើយគាត់

ឆ្លើយថា អឺ! សរសេរវាទៅហើយចាំខ្ញុំអ្នកពិនិត្យមើល។ លោកគ្រូ សុន សេន ត្រូវបានគេឆ្លើយដាក់ក្រោយមកខ្ញុំឃើញថា ស-២១ ឈប់ក្លាយទៅជាឧបករណ៍ស្វែងរកខ្មាំងហើយ គឺថាជាៗឧបករណ៍សម្រាប់សម្លាប់ខ្លួនឯងតែម្តង។ ខ្ញុំបាន<ធ្វើខុស។ ខ្ញុំបានធ្វើវា។ ខ្ញុំបានធ្វើខុស ខ្ញុំបាន>រំលោភ<>បំពានការពិតហើយ។" តើលោកចាំទេថានៅពេលមួយនៅក្នុងឆ្នាំ១៩៧៨ គឺ សុន សេន ត្រូវបានគេឆ្លើយដាក់<តើ>នៅពេលនោះ<ឬ>ដែលលោកឈប់ធ្វើការទាក់ទងជាមួយនឹង សុន សេន តទៅទៀតហើយ?

[១៤:០៨:៣២]

**ឆ៖** អរគុណ។ រឿងនេះជារឿងពីរដាច់ដោយឡែកពីគ្នា។ រឿងខ្ញុំខានជួបបង សុន សេន ទាំងជាក់ស្តែងទាំងតាមរលកអាកាស វាជារឿងមួយដែលបង សុន សេន គាត់មិនហៅមក។ ឯរឿងមួយទៀតគឺរឿងដែលអ្នកទោសឆ្លើយដាក់បង សុន សេន ខ្ញុំទៅសុំយោបល់ ពូនួន។ "ពិតតើគួរឲ្យវាឆ្លើយទេ?" គាត់ថា "អើ! ឲ្យមកស្តាប់ -- យើងស្តាប់លោ" គាត់និយាយអ៊ីចឹង។ ដូច្នេះរឿងនេះដាច់ដោយឡែកពីគ្នា អត់ទាក់ទងអីគ្នាទេ។

**ស៖** ដោយសារខ្ញុំអស់ពេលវេលាទៅហើយ អ៊ីចឹងខ្ញុំសូមសួរតែមួយសំណួរ ពីរសំណួរទៀតទេលោកប្រធាន។ សុន សេន ត្រូវបានគេឆ្លើយដាក់ យើងនិយាយថា វន វ៉េត នេះ សមាជិកគណៈអចិន្ត្រៃយ៍ត្រូវបានគេចាប់ខ្លួន ហើយថ្នាក់ដឹកនាំស្ទើរគ្រប់ភូមិភាគជាពិសេស ឧត្តរ កុយ ធួន, ភូមិភាគពាយ័ព្យ រស់ញឹម, ភូមិភាគបស្ចិម ជូ ជេត, ឧត្តរថ្មី កង ចាប។ មេភូមិភាគទាំងអស់នេះ ត្រូវបានចាប់ខ្លួន <> មេកងពលស្ទើរតែទាំងអស់<ត្រូវបានចាប់ខ្លួន> ដូចជា ចាន់ ចក្រី មេកងពល ១៧០, តាល់ មេកងពល ២៩០, មេកងពល<៣១០> អឿន, មេកងពល សឿង <៤៥០>, មេកងពល<៩២០>ឈ្មោះ ឈិន។ មេកងពលទាំងអស់នេះត្រូវបាននាំខ្លួនមកស-២១ ចោទថាជាពួកក្បត់ ហើយនិងត្រូវបានសម្លាប់ចោល។ តើមានពេលណាមួយ លោកធ្លាប់បានពិភាក្សាជាមួយ សុន សេន ឬក៏ នួន ជា ដែរទេ? ហើយតើដែលអ្នកណាម្នាក់សួរ<>ថា វាអាចទៅរួចទេ ដែលឲ្យបក្សកុម្មុយនីស្តកម្ពុជា <ធ្វើសង្គ្រាមបានជោគជ័យទៅលើ>របប លន់ នល់ <បើពាក់កណ្តាលនៃសមាជិកអចិន្ត្រៃយ៍ ពាក់កណ្តាលនៃមេដឹកនាំបក្ស និងកងទ័ពជាជនក្បត់នោះ? តើមាននរណាលើកសំណួរនេះឡើងទេ?> តើមានអ្នកណាម្នាក់ដែលលើកអំពីបញ្ហានេះមកនិយាយជាមួយលោកទេ?

**ឆ៖** អរគុណ។ អត់មានទេ អត់មាននរណាលើកបញ្ហានេះ យកមកនិយាយជាមួយខ្ញុំទេ។

[១៤:១១:៤៩]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន ដែលបានបន្ថែមពេលវេលាឲ្យយើងខ្ញុំ។

សូមអរគុណលោកសាក្សី ដែលបានឆ្លើយទៅនឹងសំណួរខ្ញុំទាំងអស់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយខ្ញុំក៏មានសំណួរមួយចំនួនដែរដើម្បីសួរទៅលោកសាក្សី ហើយជាសំណួរទូទៅ។

[១៤:១២:១២]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** យើងបានស្ដាប់លោកបាននិយាយច្រើនលើកច្រើនសាហើយថា មានការផ្លាស់ប្ដូរនៅក្នុងការទទួលខុសត្រូវនៅមន្ទីរសន្តិសុខស-២១ ពីសុន សេន ទៅ នួន ជា ហើយលោកបានកំណត់កាលបរិច្ឆេទច្បាស់លាស់ថានៅថ្ងៃទី ១៥ ខែសីហា ឆ្នាំ១៩៧៧។ តើមានហេតុផលអ្វី ឬក៏មានព្រឹត្តិការណ៍អ្វីដែលលោកបានចងចាំ នូវកាលបរិច្ឆេទនេះយ៉ាងច្បាស់លាស់ ទាំងថ្ងៃ ទាំងខែ ទាំងឆ្នាំ? តើលោកអាចចងចាំ ហើយបញ្ជាក់នូវចំណុចនេះបានដែរទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណលោកប្រធាន។ រឿងដែលខ្ញុំចងចាំនេះ ច្បាស់លាស់ គឺវាព្រឹត្តិការណ៍នេះ វាសំខាន់ពេកសម្រាប់ជីវិតខ្ញុំ។ ជួបបងទី២ ធ្វើការក្រោមបង្គាប់បងទី២ បងទី២ទម្លាក់ខ្លួនមកដឹកនាំខ្ញុំផ្ទាល់ វាជាបញ្ហានេះ។ ដូច្នេះ ខ្ញុំបានកត់ត្រាទុក ឬក៏គិតគូរជាប់ពីបញ្ហានេះ។ ហើយនៅសម័យដេញដោល ឬក៏នៅក្នុងសម័យ -- ហ្អេ! សម័យដេញដោល គេថា ដែលបងសុន សេន មកឧទ្ទេសនាម ការកកើតមន្ទីរសន្តិបាលក៏ថ្ងៃ ១៥ ខែសីហា ប៉ុន្តែឆ្នាំ១៩៥០ សុំទោស ៧៥។ មែន សម្រាប់ជីវិតខ្ញុំអាពីរពេលហ្នឹងវាជាន់គ្នាថ្ងៃខែដូចគ្នា ឆ្នាំខុសគ្នា។ ក៏ប៉ុន្តែនៅមួយទៀត ដែលខ្ញុំអត់បានរាយការណ៍ គឺថ្ងៃដែលខ្ញុំចេញពីភ្នំពេញទៅជនបទ ១៥ សីហា ១៩៧០។ ដូច្នេះក្នុងជីវិតខ្ញុំវាៗមានរឿងចម្លែកបីហ្នឹង ហើយ ១៥ សីហា ទាំងអស់។ នេះសូមបញ្ជាក់ជូនលោកប្រធានប៉ុណ្ណេះ។

[១៤:១៤:២២]

**ស៖** អរគុណ។ ហើយសាច់រឿងនោះ យើងចង់សួរបញ្ជាក់ចំណុចប៉ុណ្ណឹងទេ ហើយបញ្ជាក់

មួយចំនួនទៀត ជាសំណួរទូទៅដែរ ដោយសារពេលវេលាដែលគាត់ -- ដែលលោកបានផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ កន្លងមក ក៏ដូចជាការដែលលោកបានផ្ដល់សក្ខីកម្មនៅប៉ុន្មានថ្ងៃកន្លងមកនេះដែរថា លោកបាននិយាយថា កុយ ធួន ត្រូវបានចាប់ខ្លួន ហើយត្រូវបានឃុំខ្លួននៅក្នុងផ្ទះតាមបញ្ជារបស់ ប៉ុល ពត។ ប្រតិចារឹក កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ហើយឯកសារហ្នឹង E1/52.1, ERN ជាភាសាខ្មែរ 00792500 ហើយនិង ERN ជាភាសាអង់គ្លេស 00793703។ ហើយបញ្ហាដែលសួរនេះ គឺថាតើអ្នកណាជាអ្នកបញ្ជាច្បាស់លាស់ថាឲ្យចាប់ ប៉ុល ពត *(ស៊ីក)* ហ្នឹងនាំទៅឃុំខ្លួននៅក្នុងផ្ទះ? អ្នកណាសម្រេចថា ឲ្យចាប់ខ្លួន ចាប់ ប៉ុល ពត *(ស៊ីក)*? ម៉េចបានលោកដឹងថា ប៉ុល ពត ហ្នឹងបញ្ជាឲ្យចាប់ខ្លួន កុយ ធួន ហើយនាំយកទៅឃុំខ្លួននៅក្នុងផ្ទះ? តើលោកដឹងដោយផ្ទាល់ ឬក៏លោកដឹងតាមរយៈបុគ្គលណានិយាយប្រាប់លោក?

**ឆ៖** អរគុណលោកប្រធាន។ តាមពិតអ្នកដែលនិយាយ គឺ បង សុន សេន។ រឿងចាប់បង កុយ ធួន នេះ យើងខ្ញុំទាំងពីរនាក់យល់បញ្ហានេះយូរហើយ គឺខ្ញុំនិងបងៗ សុន សេន។ ដល់ថ្ងៃនោះ បង សុន សេន ប្រាប់ថា "ឌុចអ្ហា! បងប៉ុល សម្រេចហើយ ឲ្យចាប់ កុយ ធួន ទៅ"។ រួចគាត់ណែនាំថា "ប្រយ័ត្នណា មិត្តឯងធ្លាប់នៅក្រោមការគ្រប់គ្រងរបស់គេ អ៊ីចឹងធ្វើឲ្យស្រួល កុំឲ្យគេវាយសតិអារម្មណ៍មិត្តបាន"។ ដូច្នេះអ្នកដែលនាំពាក្យហ្នឹងមក ថា បងប៉ុល សម្រេចហើយ គឺបង សុន សេន។ ហើយគេនាំយកមកចាប់នៅផ្ទះខ្ញុំ អាផ្ទះមាត់ផ្លូវមុនីវង្ស។ គេនាំយកមកឲ្យខ្ញុំចាប់។

**ស៖** ហើយកន្លែងដែលផ្ទះដែលផ្ទះដែលឃុំខ្លួនដំបូង ដែល កុយ ធួន ហ្នឹងមុននឹងនាំទៅយក ទៅដល់មន្ទីរសន្តិសុខស-២១ហ្នឹង គឺឃុំខ្លួននៅផ្ទះហ្នឹង គឺនៅៗកន្លែងណា នៅទីតាំងកន្លែងណាដែរ លោកឌុច?

**ឆ៖** អរគុណ។ រឿងបង កុយ ធួន ដែលគេដកសិទ្ធិបក្ស ហើយដកតួនាទីចេញពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អង្គការមជ្ឈិមឃុំខ្លួននៅក្នុងមន្ទីរមជ្ឈិមឯនោះទេ។ បើតាមខ្ញុំដឹង ដូចជាថ្ងៃ០៨ -- បើតាមខ្ញុំចាំ ដូចជាថ្ងៃ០៨ ខែ៤ ៧៦។ ដល់ក្រោយមក បានៗគេបញ្ជូនដោយឯកសារហ្នឹងវាឆ្លើយមានចម្លើយអ្នកផ្សេងទៀតដាក់ទៅ បានគេសម្រេច បងប៉ុល គាត់សម្រេចឲ្យបញ្ជូនបង កុយ ធួន មកឲ្យខ្ញុំ។ ដូច្នេះបើតាមខ្ញុំចាំ ថ្ងៃ២៥ ខែ០១ ១៩៧៧ គេនាំបង កុយ ធួន មកដល់ហើយ។ ខ្ញុំក៏ចាប់ផ្ដើមសួរ។ ថ្ងៃ២៩ បង កុយ ធួន ចាប់ផ្ដើមឆ្លើយ ហើយថ្ងៃ០១ ខែកុម្ភៈ គេៗចាប់ពួកឧត្ដរមកទាំងសិប ទាំងរយ។

[១៤:១៨:២៣]

01311939



**ស៖** អ៊ីចឹងការដែលខាងថ្នាក់លើសម្រេចថា ចាប់ខ្លួន កុយ ធួន យកមកឃុំខ្លួននៅក្នុងផ្ទះដំបូងនៅមន្ទីរមជ្ឈិមបក្សឯនោះ បានន័យថា លោកអត់ដឹងរឿងនុ៎ងទេ មែនទេ? លោកអត់រឿងថា ការឃុំខ្លួននៅក្នុងផ្ទះនុ៎ងពីពេលណា ហើយទីកន្លែងណាពិតប្រាកដទេ មែនទេ?

**ធ៖** អរគុណ។ ការឃុំខ្លួននៅក្នុងផ្ទះហ្នឹង ខ្ញុំអត់ដឹងកន្លែងណាពិតប្រាកដទេ។ មន្ទីរមជ្ឈិមហ្នឹងមិនដឹងត្រង់ណាទេ។ ប៉ុន្តែថ្ងៃ បើតាមខ្ញុំចាំ ដូចជាថ្ងៃ០៨ ខែ៤ ប៉ុនមិនដឹងខ្ញុំចាំកាលបរិច្ឆេទហ្នឹងពីៗណាមកទេ មិនផ្លូវការទេ មិនមែន បងខៀវ – បងៗ សុន សេន ប្រាប់ទេ។ ខ្ញុំមិនដឹងជាចាំកាលបរិច្ឆេទហ្នឹងពីកាលណាមក ឬក៏ខ្ញុំចាំដោយសួរបង កុយ ធួន ក៏មិនដឹង។ កាលបរិច្ឆេទនេះ វានៅក្នុងឋានៈហ្នឹង កាលបរិច្ឆេទដែលគេដកបង កុយ ធួន ចេញពីបក្ស ហើយដកសិទ្ធិពីសមាជិកមជ្ឈិមបក្ស ហើយនិងដកសិទ្ធិតួនាទីពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ ខ្ញុំអត់ចាំ កាលបរិច្ឆេទហ្នឹងមិនច្បាស់ថា ខ្ញុំដឹងពីណាទេ។

**ស៖** តើលោកដឹងហេតុផលអ្វីខ្លះដែរទេ ពាក់ព័ន្ធនឹងការដែលចាប់ខ្លួនឈ្មោះ កុយ ធួន ដំបូងហ្នឹង គឺឃុំខ្លួននៅនឹងផ្ទះហ្នឹង តើមានហេតុផលអ្វី បានជាមានលក្ខណៈចម្លែកធៀបជាមួយនឹងបុគ្គលដទៃទៀត ហើយចាប់ខ្លួន គឺបញ្ជូនមកមន្ទីរសន្តិសុខស-២១ ដោយឡែក កុយ ធួន គឺចាប់ឃុំខ្លួននៅផ្ទះមួយរយៈ ហើយក្រោយមកទើបបញ្ជូនមកមន្ទីរសន្តិសុខ ស-២១?

**ធ៖** អរគុណលោកប្រធាន។ រឿងដំបូង រឿង បង កុយ ធួន ដែលរ៉ាំរ៉ៃហូរហែមកហើយ គឺរឿងគាត់ស្រីញី។ នៅឧត្តរក៏គាត់ស្រីញី ចូលមកដល់ភ្នំពេញក៏គាត់ស្រីញី។ អាចុងក្រោយនេះទៅខូចជាមួយប្រពន្ធគេ ដល់ប្ដីគេឡូឡា គាត់ចាត់ចែងកម្ទេចប្ដីគេ។ រួចតាមដំណឹងដែល បងខៀវ ប្រាប់ហ្នឹងពេលដែលកម្ទេចប្ដីគេហ្នឹង បងកុយ ធួន ទៅរួមចំណែកដែរ ដូចចាក់ជើង មិត្តឡុង នោះទៅទៀត។ ដោយសាររឿងកម្ទេចប្ដីគេ ហើយគាត់ឃើញប្រពន្ធគេ គាត់ទៅកម្ទេចប្ដីគេហ្នឹងហើយបានបក្សដកសិទ្ធិយកទៅឃុំឃាំងទុកនៅក្នុងមន្ទីរមជ្ឈិម។

[១៤:២១:២៧]

**ស៖** បាទ ហើយលោកដឹងទេថា អ្នកណាជាអ្នកសម្រេចចាប់បញ្ជូន កុយ ធួន ពីកន្លែងទៅឃុំខ្លួននៅនឹងផ្ទះ និងមកកាន់មន្ទីរសន្តិសុខស-២១ ដែលលោកថា បានចាប់ឃាត់ខ្លួនគាត់នៅនឹងផ្ទះរបស់លោក មកប្រគល់ឲ្យលោកនៅនឹងផ្ទះ?

**ធ៖** អរគុណ។ អ្នកសម្រេច គឺការិយាល័យ៨៧០ អ្នកសម្រេច ហើយអ្នកបញ្ជូនមក ខ្ញុំមិនចាំទេ ភ្លេចហើយ។

**ស៖** បាទ អរគុណ។ ហើយបញ្ហានេះយើងសួរតែប៉ុណ្ណេះ ហើយយើងសូមសួរសំណួរបន្ថែមទៀត ដោយបញ្ហាដែលលោកបានបញ្ជាក់ ឆ្លើយបានច្រើនលើកច្រើនសាហើយប៉ុន្មានថ្ងៃនេះពាក់ព័ន្ធជាមួយនឹងលោកទន្តបណ្ឌិត ឌី ផុន ហៅ ធុក។ ហើយយើងចង់ដឹងបញ្ជាក់ ចង់សុំឲ្យលោកបញ្ជាក់ច្បាស់លាស់មើលអំពីជោគវាសនារបស់គាត់ហ្នឹង តើចុងក្រោយគាត់យ៉ាងម៉េចដែរ ដែលថាជាមនុស្សតែមួយគត់ដែលត្រូវបានថ្នាក់លើសម្រេចឲ្យដោះលែង? ហើយក្នុងការប្រើលទ្ធភាពមួយទៀតថា ទុកឲ្យគាត់ទុកធ្វើធ្មេញ។ ប៉ុន្តែការដែលលោកដឹងតាម -- លោកដឹងច្បាស់លាស់ថា តើលោកទន្តបណ្ឌិត ឌី ផុន ហ្នឹង ជោគវាសនារបស់គាត់យ៉ាងម៉េចដែរ? ពីព្រោះមានបញ្ហាបន្តិចទៀតយើងនឹងសួរហើយ ថាតើលោកសុំបញ្ជាក់នេះឲ្យបានច្បាស់លាស់សិនមើល៍។

**ឆ៖** អរគុណ។ បង ឌី ផុន នេះ បងប៉ុល ណែនាំឲ្យទុក ឲ្យរស់ជីវិត ថែទាំនិងប្រើប្រាស់នៅក្នុង ស-២១ ហ្នឹងអត់លែងទៅក្រៅទេ ហើយមិនប្រគល់សិទ្ធិជាបក្ខជនឲ្យវិញដែរ។ ធម្មតាទេ ខ្ញុំតែងតែយកពេទ្យដែលគេចាត់តាំងហ្នឹងយកមកប្រើ។ ដូច្នេះ បងនួន ហ្នឹងប្រញាប់ថា ឲ្យមិត្តឯងយក ឌី ផុន ហ្នឹងយកទៅប្រើទៅ ធ្វើធ្មេញ។ ឯចំណែករឿងពិតមួយទៀត បងធុក ហ្នឹងគាត់នៅធ្វើការជាមួយនឹងគេនឹងឯងហ្នឹង ជាពេទ្យធម្មតាទេ ពេទ្យជំងឺទូទៅ។ ដល់ថ្ងៃរត់យួននេះ បងឌី ផុន គាត់រត់ទៅជាមួយនឹងគេ ក៏ប៉ុន្តែវាបែកគ្នាជាពីរផ្នែក មួយផ្នែករបស់ខ្ញុំនេះ ភាគច្រើនវាទៅឆ្លងផ្លូវលេខ៤ មួយផ្នែកទៀត មិត្តវ៉ាន់ឈ្មោះដើម ញ៉េប ហូ នេះនាំបែកទៅខាងត្បូងផ្លូវលេខ៤។ សរុបមក រហូតដល់ថ្ងៃ០៧ មករា វេលាម៉ោងបី ដែលយើងខ្ញុំចេញពីស-២១ បង ឌី ផុន នៅរស់ ហើយរត់យួនជាមួយនឹងពួកយើងខ្ញុំ ដល់យប់នោះប្រហែលជាម៉ោងប្រាំពីរ ឆ្លងផ្លូវលេខ៤ យើងបែកគ្នា។ ដូច្នេះជីវិតរបស់បង ឌី ផុន ខ្ញុំលែងដឹងត្រឹមហ្នឹង។ ខ្ញុំតាមដានដែរ តើសភាពការណ៍វាទៅយ៉ាងម៉េច អត់លេច។

[១៤:២៥:០៦]

**ស៖** បាទ អរគុណ។ ហើយប៉ុន្តែនៅក្នុងប្រតិចារឹកកាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោង ១៤:២៥នាទី និង០២វិនាទី លោកបានឆ្លើយថា លោកហ្នឹងគឺរង់ចាំស្ត្រីពីរនាក់មកពីស្រុកបារាំង គឺម៉ាដាម ចៅ សេង នេះមួយ ហើយនិងម៉ាដាម ឌី ផុន។ ម៉ាដាម ឌីផុន នេះគឺ ប៉ាន់ ប៉ូលីន ត្រូវជាប្រពន្ធបង ឌី ផុន ហើយគឺក្នុងគោលបំណង គឺលោកសុំអភ័យទោស បានន័យថា សុំថ្វាយបង្គំទោសគាត់ដោយសារលោកការពារមិនជាប់មនុស្ស “ដែលខ្ញុំគោរព នេះសូមជម្រាបប៉ុណ្ណឹង”។ យើងចង់ដឹងថាអំមិញនេះ គឺលោកបានបញ្ជាក់បន្ថែមហើយថា ជោគវាសនា ឌី ផុន ហ្នឹងគឺក្រោយ៧៩ គឺគាត់បានរួច

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជីវិតហើយ ក្រោយ ០៧មករា ៧៩ គឺរត់ជាមួយខាងបុគ្គលិកសន្តិសុខចេញទៅក្រៅ ប៉ុន្តែនៅក្នុងខ្លឹមសារមួយដែលលោកបាននិយាយនេះ គឺសំដែងនូវការថាលោកមិនអាចការពារពួកគេបាន មានរួមទាំង ថៅ សេង និង ឌី ផុន ផង។ យ៉ាងម៉េចដែរ បានជាលោកឆ្លើយដូច្នេះលើបញ្ហានេះ?

**ឆ៖** អរគុណលោកប្រធាន។ ថៅ សេង គាត់មានគុណលើជាតិ ហើយក៏ដូចជាលើរូបខ្ញុំផ្ទាល់ ដោយសារគាត់បានកែប្រែកម្មវិធីសិក្សា នេះទី១។ ទី២ គាត់បានបង្កើតវិទ្យាស្ថានជាតិគរុកោសល្យនេះឡើងដើម្បីឲ្យពួកក្មេងៗដែលជាប់បាក់ឌុប ឬក៏អ្នកគ្រូជើងចាស់ គេហៅថា គ្រូដីក្រេកុំប្លេម៉ង់តែល នោះមានលទ្ធភាពប្រលងទៅជាសាស្ត្រាចារ្យបាន។ នេះដែលយើងខ្ញុំគិតថា បងថៅ សេង មានគុណលើជាតិប្រជាជនយ៉ាងនេះឯង។ ដូច្នេះ ខ្ញុំមានកាតព្វកិច្ចការពារគាត់។ សំខាន់គឺដឹងថា បងថៅ សេង ជាជនចម្រើន បានន័យថាអ្នកស្រលាញ់បដិវត្តន៍ អ្នកចូលរួមបដិវត្តន៍ ឧបត្ថម្ភបដិវត្តន៍បែបណាមួយមិនដឹងទេ។ ឯចំណែក បងឌី ផុន – បង ឌី ផុន ម្យ៉ាងខ្លួនគាត់ធ្លាប់ជាប់ចលនានៅស្រុកបារាំង។ ដល់ក្រោយមកក៏មានរឿង គេចោទប្រកាន់ម្តងដែរ។ ឯសំខាន់ គឺអ្នកគ្រូ តាន់ ប៉ូលីន ទេដែលពូជគាត់សុទ្ធតែជាអ្នកចម្រើន ជនស្រលាញ់បដិវត្តន៍ ដូចព្រឹកមិញខ្ញុំនិយាយ បងតាន់ ម៉ុក –បងអ្នកគ្រូ តាន់ ប៉ូលីន– នេះជាជនដែលកសាងកម្លាំងនៅក្នុងអគ្គិសនីកម្ពុជា។ ដូច្នេះ អ្នកទាំងអស់នេះ ខ្ញុំទុកដូចជាអ្នកមានគុណ។ ដោយឡែក បងថៅ សេង ច្បាស់ហើយ។ គាត់ស្លាប់ទៅហើយ។ ឯចំណែក បងឌី ផុន ខ្ញុំការពារមិនជាប់ មិនឲ្យគេចាប់មក ការពារមិនជាប់ទេ មានចម្លើយឆ្លើយដាក់។ បានៗជា បងប៉ុល សម្រេចឲ្យចាប់។ ក៏ប៉ុន្តែចុងក្រោយ ០៧ មករា នេះ ដែលបែកខ្ញែកគ្នានេះ ខ្ញុំអត់ទាន់ទទួលព័ត៌មានណាថា បងឌី ផុន នៅរស់ ឬស្លាប់ទេ។ ប៉ុន្តែអ្នកគ្រូ ប៉ូលីន ឈប់ដាក់ឈ្មោះ ម៉ាដាម ឌី ផុន ហើយគាត់ដាក់ឈ្មោះ ម៉ាដាម ឌីផុន ប៉ូលីន។ ដូច្នេះ ខ្ញុំអត់ទាន់ដឹងថា បងឌីផុន ស្លាប់ ឬរស់ទេ រហូតមកដល់ថ្ងៃនេះ គ្រាន់តែដឹងថាបែកគ្នា។

[១៤:២៩:០០]

**ស៖** បាទ អរគុណ។ ហើយសំណួរមួយទៀត ពាក់ព័ន្ធជាមួយនឹងពុទ្ធកៈវិទ្យាល័យសុរាម្រិតហើយលោកអាចបញ្ជាក់បានដែរទេ ព្រោះបានលោកបានឆ្លើយច្រើនដងហើយ អំពីទំនាក់ទំនងរវាងលោក ជាមួយនឹងលោក នួន ជា នៅក្នុងអំឡុងពេលបន្ទាប់ពីការទំនាក់ទំនងការងាររវាងថ្នាក់ដឹកនាំជាមួយនឹងមនុស្សជាន់ខ្ពស់ ជាមួយនឹងមន្ទីរសន្តិសុខស-២១ គឺមានលោកជាប្រធាន គឺបានផ្ទេរការឃុំគ្រងពីការទទួលបន្ទុកពី សុន សេន មក នួន ជា ហើយលោកបានទៅច្រើនលើកច្រើនសា។ សូមលោកបញ្ជាក់មើលថាតើ ពុទ្ធកៈវិទ្យាល័យសុរាម្រិតហ្នឹង នៅទីតាំងនៅកន្លែងណាដែរ ពិតប្រាកដ? ហើយ

លោកទៅជួបគាត់ គាត់ហៅទៅជួបហ្នឹងដើម្បីរាយការណ៍ ឬក៏សុំទទួលបញ្ជាដែលរយៈពេលថា ម្តង ប្រហែលជា១០នាទីហ្នឹង ធ្វើនៅទីកន្លែងណាដែលពិតប្រាកដ? ហើយមានអ្នកណាចូលរួមខ្លះ ក្រៅពីលោក ហើយនិងជាមួយនឹង នួន ជា?

**ឆ៖** អរគុណ។ ពុទ្ធិកៈវិទ្យាល័យព្រះសុរាម្រិតនេះ ផ្លូវបើតាមខ្ញុំចាំ ដូចជាផ្លូវឱកទ័រហាន់ ប៉ុន មិនច្បាស់ទេ។ សូមនិយាយមួយម៉ាត់ ផ្លូវពីកើតត្រង់មកលិចនេះ ប្របក្បែរវាំង មុខសភា ហើយនិងមុខពុទ្ធិកៈ សូមទោស សាសនបណ្ឌិត បណ្ណាគារពុទ្ធសាសនបណ្ឌិតហ្នឹង។ ពុទ្ធិកៈវិទ្យាល័យព្រះសុរាម្រិត នៅចំចន្លោះកណ្តាលអគារពីរនេះ។ កណ្តាលសភា ហើយនិងកណ្តាលពុទ្ធសាសនបណ្ឌិត មុខវាំង នៅមុខវាំង។ មុខវាំងនេះ អគារនោះ ជាអគារវែងបណ្តោយថ្ងៃ ខាងក្រោមអត់មានបន្ទប់ទេ មានតែជណ្តើរមួយឡើង ហើយគេកសាងទៅជាអ៊ីចឹងនេះ។ ជណ្តើរឡើង។ រួចគាត់ហៅខ្ញុំឲ្យឡើងទៅលើ ទៅជួបឯលើ អានេះថ្ងៃដំបូង ថ្ងៃ១៥ ខែសីហា ១៩៧៧ ហ្នឹង ក៏ហៅឡើងទៅលើ។ ដល់ក្រោយៗមក ខ្ញុំអត់បានទៅលើទេ ខ្ញុំជួបគាត់នៅខាងក្រោម។ គាត់ជួបខ្ញុំ គាត់បែរមុខទៅទិសខាងត្បូង ដាក់តុមួយអ៊ីចឹងទៅ បែរមុខទៅទិសខាងត្បូង ហើយខ្ញុំអង្គុយទល់មុខគាត់ហ្នឹង។ តែពីរនាក់ទេ។ ធម្មតាទេ ខាងដឹកនាំមជ្ឈិម គេមិនដែលអត់កងការពារទេ ប៉ុន្តែមិនដឹងកងការពារគេនៅឯណាខ្លះទេ ដើម្បីការពារគាត់។ មាន ប៉ុន្តែតែពីរនាក់គាត់ ហើយនិងខ្ញុំទេ។

[១៤:៣១:៥៩]

**សៈ** បាទ អរគុណ ហើយតាមលោកចាំ លោកបានទៅដល់ទីនោះ ដែលខាង នួន ជា ហៅលោកទៅធ្វើការទទួលបញ្ជា ឬក៏រាយការណ៍ដោយផ្ទាល់ហ្នឹង លោកបានទៅដល់កន្លែងនោះប៉ុន្មានដងដែរ ទៅដល់កន្លែងដែលជួបប្រជុំជាមួយ នួន ជា នោះ ក្នុងអំឡុងពេលដែលចាប់ពី នួន ជា ទទួលបន្ទុកនៅការងារស-២១ ដែលលោកបានឆ្លើយបំភ្លឺដល់អង្គសវនាការកន្លងមកនេះ?

**ឆ៖** អរគុណលោកប្រធាន។ បង នួន ជា ហៅឲ្យខ្ញុំទៅធ្វើការនៅនឹងនោះ អ្ហ៎! ច្រើនដងណាស់ បីបួនថ្ងៃម្តង ជាប់មិនដែលខាន។ ដោយឡែក នៅបុរីកីឡាវាមានបន្ទប់មួយតូចៗនៅ -- វាបន្ទប់តូចៗនៅក្បែរនុ៎ង។ ខ្ញុំទៅនោះ បានពីរ ឬបីដងទេ បងនួន ហៅខ្ញុំទៅធ្វើការនុ៎ង។ ឯចំណែកធ្វើការនៅពុទ្ធិកៈវិទ្យាល័យព្រះសុរាម្រិត ច្រើនដងណាស់។ បីបួនថ្ងៃម្តង មិនដែលខាន។ រួចម្ល៉ោះហើយ ទៅ ខ្ញុំទៅ ហើយនិងមិត្តទៀង និង មិត្តលីន នេះ សន្មតគ្នា។ បើធ្វើការមាត់ទន្លេ គឺពុទ្ធិកៈមហាវិទ្យាល័យ -- ពុទ្ធិកៈវិទ្យាល័យព្រះសុរាម្រិត។ ធ្វើនៅលើទួល គឺបុរីកីឡា។ នេះ គឺបានសន្មតគ្នាអ៊ីចឹង តាមទូរស័ព្ទ។ ពួកនោះ គេហៅខ្ញុំ

តាមទូរស័ព្ទទេ ប៉ុន្តែ បងនួន អត់ប្រើទូរស័ព្ទសោះ។

**ស៖** បាទ អរគុណ ហើយមានសំណួរមួយចំនួនទៀត។ សំណួរមួយពាក់ព័ន្ធនឹងការអនុវត្តទូទៅនៅមន្ទីរស-២១ហ្នឹង មុននឹងឈានដល់ការចាប់ខ្លួនបុគ្គលម្នាក់ តើគឺគ្រាន់តែផ្អែកទៅលើចម្លើយសារភាពរបស់បុគ្គលមុនៗដែលបានឆ្លើយដាក់ តាមរយៈវិធីសាស្ត្រផ្សេងៗនៃការសួរចម្លើយដែលបានប្រើប្រាស់នៅក្នុងមន្ទីរសន្តិសុខស-២១ ឬក៏នៅក្នុងករណីនេះ ករណីណាដែលមានករណីដែលអាចប្រើប្រាស់នូវវិធីផ្សេងទៀត ដូចជាមានការស៊ើបអង្កេតបន្ថែមអីជាដើម បន្ទាប់ពីការស្តាប់ ការដែលទទួលបាននូវចម្លើយដាក់ពីមន្ទីរសន្តិសុខនៅស-២១ តើមានករណីបែបនេះដែរឬទេ?

[១៤:៣៤:៥០]

**ឆ៖** អរគុណ។ តាមឯកសារដែលនៅសល់ ហើយនិងគោលការណ៍បក្សដែលប្រើប្រាស់ បានចម្លើយពីស-២១ ទៅ គេប្រជុំគ្នា កាលណាឃើញការគូរ ដូចជាឈ្មោះ ឡុង ម៉ុយ ហៅ ជួន អ៊ីចឹង បងខៀវ រុញទៅឲ្យ បងប៉ុល សម្រេច អានហើយសម្រេច។ អាហ្នឹងវាមួយបែបទៅ។ មួយបែបទៀតកាលណាបានឯកសារហើយ គេបំបែកទៅតាមភូមិភាគ ឲ្យភូមិភាគរួមចំណែកជាមួយនឹងគេ “សូមមិត្តពិនិត្យមើលតាមជាក់ស្តែង” នេះជារឿងរ៉ាវដែលខ្ញុំបានរាយការណ៍ជូនថ្មី ប៉ុន្តែភូមិភាគក៏ដោយច្រើនតែខាងលើប្រគល់រុញទៅហើយ ខ្លាំងឆ្លើយដាក់ប៉ុន្មានដែលខាងលើគិតថា អាណាមានលទ្ធភាពធំជាងគេចាប់ហើយ។ ដូច សុន សេន គាត់ទទួលខុសត្រូវក្នុងការចាប់ចងខាងក្នុងកងទ័ព ឯកសារដែលនៅសល់នេះមានសរសេរ “ជូនមិត្តពីន ពិនិត្យ”។ ដូច្នេះ មិត្តពីន ហ្នឹង កាលហ្នឹងឃើញឯកសារហ្នឹងទៅច្រើនតែគោរពថ្នាក់ដឹកនាំ ចាប់បញ្ជូនមកទាំងអស់។ នេះជាកិច្ចការដែលខ្ញុំធ្លាប់ដឹង រួចនេះហើយបានជាខ្ញុំនិយាយជាមួយនឹង បងនួន។ បងនួនគាត់ថា “មិត្តអើយ គេចេះធ្វើការដែរ”។

**ស៖** បាទ អរគុណ។ ហើយមានសំណួរមួយទៀតមុននឹងសម្រាក។ អង្គជំនុំជម្រះមាន -- បានស្តាប់ភស្តុតាងមួយចំនួនពាក់ព័ន្ធនឹងកិច្ចប្រជុំមួយនៅ ដែលរៀបចំឡើងនៅទីក្រុងភ្នំពេញនៅក្នុងអំឡុងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ ដែលមានអ្នកចូលរួមមកពីគ្រប់ទិសទី។ តើលោកធ្លាប់បានចូលរួម ឬក៏ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំណាមួយ ឬក៏កិច្ចប្រជុំដែលៗប្រព្រឹត្តឡើងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំពីពាន់ -- អ៊ំ! ឆ្នាំ១៩៧៥ ដែរឬទេនៅពហុកីឡដ្ឋានជាតិ?

**ឆ៖** អរគុណលោកប្រធាន។ នៅពេលនោះ ខ្ញុំនៅអមលាំងនៅឡើយទេ រយៈកាលនោះយូរម្លោះហើយខ្ញុំគិតថា អ្ហែ! យូរពេកគិតសុំរៀបការឲ្យហើយ ហ្នឹងហើយវាមានរឿងហ្នឹង។ ដូច្នេះខ្ញុំនៅឯ

អមលាំងនៅឡើយទេ ខ្ញុំអត់ដឹងរឿងរ៉ាវអីនឹងគេទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកសាក្សីដែលបានឆ្លើយបញ្ជាក់។ ហើយឥឡូវនេះដល់ពេលសម្រាកហើយ ហើយប្រកាសសម្រាកចាប់ពីពេលតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនាវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៨ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកសាក្សី យើងមានសំណួរមួយចំនួនទៀតចង់សួរបញ្ជាក់ពីលោក ហើយសំណួរដែលចង់សួរបញ្ជាក់ហ្នឹងគឺពាក់ព័ន្ធជាមួយនឹង សឿ វ៉ាស៊ី ហៅ ឌឿន ដែលកាលពីម្សិលមិញលោកបានបញ្ជាក់បន្ថែមហើយថា ជាប្រធានមន្ទីរ៨៧០។ ហើយតាមដែលលោកចងចាំតើ សឿ វ៉ាស៊ី ហៅ ឌឿន ហ្នឹងត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ ពីពេលណាដែរ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ សឿ វ៉ាស៊ី ហៅ ឌឿន នេះ ថ្ងៃខែច្បាស់លាស់ខ្ញុំអត់ចាំទេ ប៉ុន្តែចាំថា គាត់ត្រូវបានចាប់ខ្លួនក្រោយបង កុយ ធួន – ក្រោយបង កុយ ធួន ទេ។

**ស៖** បាទ អរគុណ។ ហើយ ទំនងជានៅក្នុងឆ្នាំណា ប្រហាក់ប្រហែលនៅឆ្នាំណា? លោកចាំទេ?

**ឆ៖** អរគុណ។ គឺនៅឆ្នាំ១៩៧៧។

**ស៖** ហើយលោកដឹងទេ ថាអ្នកណាជាអ្នកសម្រេចឲ្យចាប់ខ្លួនលោក ឌឿន?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បញ្ហាអស់នេះ ចម្លើយរបស់ខ្ញុំនៅតែដដែលទេ គឺខាងលើជាអ្នកសម្រេចឲ្យចាប់ និយាយឲ្យចំមួយម៉ាត់ គឺពួក គឺ៨៧០ ជាអ្នកសម្រេច។

**ស៖** ពាក់ព័ន្ធនឹង ឌឿន នេះ យើងមានឯកសារចំណុចមួយចំនួនពាក់ព័ន្ធនឹង ឌឿន ដើម្បីសួរបញ្ជាក់លោក។

ហើយមន្ត្រីរដ្ឋបាលតុលាការយកឯកសារនេះ យកទៅឲ្យលោក ឲ្យសាក្សីពិនិត្យ គឺឯកសារ E3/1625 ដែលមានលេខ ERN ជាភាសាខ្មែរ គឺ 00011608 និងជាភាសាអង់គ្លេស គឺ 00768020 ហើយនៅលើទំព័រនេះ សូមលោកមើលចំណាររលើរឹមទំព័រដែលមាន *ហាយឡាយ* ពណ៌បៃតង នៅត្រង់នេះមានកត់សម្គាល់មួយផ្ញើទៅ ឌឿន កំណត់សម្គាល់មានចុះកាលបរិច្ឆេទថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧។ លោករកឃើញចំណុចនោះដែរទេ ខ្ញុំមានដាក់ *ហ្វូតណូត* ដើម្បីមើល លោកអាចមើលបាន។

លោកឃើញនៅលោក ឌុច ឃើញអាចំណុចដែលយើងមានបំណងសួរដែរឬទេ គឺនៅក្នុងទំព័រលេខ 00011608 ហើយចំណុចហ្នឹងគឺយើងមានដាក់លេខ មានដាក់ *ហាយឡាយ* នៅលើហ្នឹងហើយ ហើយមាន *ហ្វូតណូត*។ *ហ្វូតណូត* ទី១ ឌុច។

[១៥:០៥:០២]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ ខ្ញុំរកឃើញហើយ។ ខ្ញុំសូមអានជូនដូចតទៅ៖ "លោក ឌឿន អត្ថបទនេះ តាមការយល់ដឹងដ៏ស្លូចស្តើងរបស់ខ្ញុំ ខ្ញុំយល់ឃើញថា លោកជាឆ្មាលាក់ក្រចក ឬម្យ៉ាងទៀតថា ឆ្មាកប់អាចម៍។ តាមពិត ខ្ញុំថានេះមិនមែន មិនដឹងជាខុស ឬត្រូវទេ សូមលោក[អត់ទោស] បើលោកអនុគ្រោះ ក៏សូមឆ្លើយ ក៏សូមឆ្លៀតពេលវេលាខ្លះ ក្រៅពីយល់សប្តិ ពិនិត្យអត្ថបទនេះសាឡើងវិញ។ ហើយសរសេររាយការណ៍ឲ្យពិតតាមខ្ញុំ តាមពិត -- ឲ្យពិតតាមសារជាតិនៃបញ្ហានៅពេលនេះ។ ឌុច ថ្ងៃ៣០ ខែ០៤ ១៩៧៧។" នេះ ជាចំណាររបស់ខ្ញុំមែន។

**ស៖** បាទ អរគុណ។ ហើយលោកអាចបញ្ជាក់បំភ្លឺបានទេ អត្ថន័យនូវចំណារនេះ មានន័យយ៉ាងម៉េចដែរ លោកបញ្ជាក់បានទេ ព្រោះលោកជាម្ចាស់ចំណារ?

**ឆ៖** អរគុណ។ នេះជាយុទ្ធវិធីសួរចម្លើយរបស់ខ្ញុំ ហើយនិង ប៉ុន រៀបចំជាមួយគ្នា។ រួចខ្ញុំសរ-សេរនេះ ដោយផ្ទាល់ដៃខ្លួនឯង ទៅប្រាប់ ឌឿន ឲ្យឈប់ភរទៅ។ បានន័យថា អ្នកឯងភរ មានល្បិច ឆ្មាលាក់ក្រចក ឬក៏ឆ្មាកាយអាចម៍កប់។ ដូច្នេះ សូមៗសរសេរឲ្យត្រង់តាមរឿងពិតទៅ កុំភរ។ រួចសូម

បញ្ជាក់នៅចុងនេះ ខ្ញុំហើយនិង ឌឿន ស្គាល់គ្នាយូរដែរ។ ស្គាល់ពីខែ១០ ១៩៧៧ ពេលនោះ ខ្ញុំទៅនៅជាមួយ កុយ ធួន ហើយ ឌឿន ទៅធ្វើការជាមួយ កុយ ធួន។ ដូច្នេះអាងលើបញ្ហាហ្នឹងផង ដើម្បីនឹងសរសេរទៅគេ។

[១៥:០៧:៣៥]

**ស៖** បាទ អរគុណ ហើយលោកមើលចំណុចមួយទៀតនៅក្នុងឯកសារដដែល គឺលើ*ហ្វូតណូត* ទី២ ដែលមានលេខ ERN ជាភាសាខ្មែរ 00011629, និងជាភាសាអង់គ្លេស 00768021 ដែលជាលិខិតមួយសរសេរទៅ ម្សៀ ឌឿន។ មើល លោកមើល មាន*ហាយឡាយ*ពណ៌បៃតង ហើយចុះកាលបរិច្ឆេទថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៧។ លោកៗស្គាល់ឯកសារនេះដែរទេ លោក ឌុច?

**ឆ៖** អរគុណ។ អក្សរនេះ គឺអក្សរ មិត្តប៉ុន អ្នកដែលសួរចម្លើយ ឌឿន ផ្ទាល់។ ខ្ញុំសូមអានជូនអង្គប្រជុំដូចតទៅ៖

"លោកម្សៀរ ឌឿន ខ្ញុំសូមជម្រាបជូនលោកថា៖ អត្ថបទដែលលោកសរសេរ និងកំពុងតែសរ-សេរនេះ និយាយរួមមក គឺសុទ្ធតែជារឿងគេ គឺសុទ្ធតែជារឿងគេ ចំណែករឿងខ្លួនលោកដែលលោកប្រឡូកផ្ទាល់ក្នុងចលនាក្បត់នោះ លោកពុំបានធ្វើសេចក្តីរាយការណ៍ផងទេ។ បើលោករក្សាជំហរបែបនេះទៀត តាមសេចក្តីសម្រេចចិត្តរបស់ក្រសួងសន្តិបាល បានសម្រេចហើយថា នឹងចោះសសៃកែងរបស់លោក។ សូមលោកជឿចុះថា ខ្ញុំប៉ានធ្វើការឲ្យការព្រមាននេះ ទៅជាការពិតជាក់ស្តែងនឹងភ្នែកលោកភ្លាមៗ បើលោកនៅតែចចេស។ ត្រង់ចំណុចថា បងភឹម គាត់ស្រវឹងស្រា ហើយបញ្ចេញសំបុត្រ "ផ្តែសន្ទួចបី" ដែល កែម ឃើញដែរ។ ត្រង់ចំណុចដែលលោកនិយាយនេះ តើជារឿងពិតមែន ឬដូចម្តេច? តើលោកប៉ានធានាប្តូរនឹងប្រស្រីភ្នែកលោកទេ? បើប្រសិនជារឿងនេះសួរ កែម ទៅ កែម ឆ្លើយថា អត់ទេ។ លោក ឌឿន សរសៃកែង និងប្រស្រីភ្នែកមិនមែនជារឿងធម្មតាទេ។ វាទៅជាពិតបាន ក្នុងករណីដែលលោកមាន មានៈនឹងក្រឡិចក្រឡុច ហ្វាស៊ីស...។ សូមលោកសរសេរបញ្ជាក់ថា ជាអត្ថបទមួយសន្លឹក ពីរ ឲ្យច្បាស់លាស់មើល។ ថ្ងៃ១១ ឧសភា ១៩៧៧ ប៉ុន"។

[១៥:១០:៤៨]

**ស៖** បាទ ច្បាស់លាស់ហើយៗ បំណងយើងសួរគឺទី១ ថាហេតុអីបានលិខិតហ្នឹងគេប្រើពាក្យ "ម្សៀរ"ៗ ម្សៀរ ឌឿន ប្រើ ពាក្យ "ម្សៀរ" ហ្នឹងយ៉ាងម៉េចដែរ? វាមានលិខិតចម្លែកមួយដែលប្រើពាក្យនេះនៅក្នុងសម័យ នៅសម័យកម្ពុជាប្រជាធិបតេយ្យ គឺមន្ទីរស-២១?

**ធ៖** "ម្សៀរ" នេះជាពាក្យខ្មែរ គេប្រើសម្រាប់មើលងាយ គេប្រើសម្រាប់មើលងាយ។ ណេះម្សៀរឯងទៅណោះ។ អាហ្នឹងគេមើលងាយ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។

**សៈ** បាទ អរគុណ។ ហើយតាមខ្លឹមសារនៃពាក្យ ព្រមាននេះ ព្រមានដែលមានដូចលោកអានលិខិតអម្បាញ់មិញនេះ តើតាមខ្លឹមសារនេះ តើមានបានអនុវត្តជាក់ស្តែងនៅចំពោះ ឌឿន ដែរឬទេ នៅក្នុងអំឡុងពេលដែលជាប់ឃុំនៅមន្ទីរសន្តិសុខស-២១? ឬក៏បានប្រព្រឹត្តទៅលើគោលដៅណាផ្សេងទៀតក្រៅពី ឌឿន ដែរឬទេ តាមលោកដឹង?

**ធ៖** ការព្រមាននេះ បើតាមខ្ញុំដឹងអត់មានទេ អត់មានប្រព្រឹត្តទៅអ្នកណាទេ។

**សៈ** បាទ អរគុណ។ ហើយសំណួរមួយទៀតពាក់ព័ន្ធនឹងបញ្ហានេះ យើងក៏ចង់ដឹងដែរ លោកតាមពិតលោកឆ្លើយច្រើនលើកច្រើនសាហើយ ប៉ុន្តែដើម្បីឲ្យបានច្បាស់លាស់ថា តើ ប៉ុន ដែលលោកនិយាយ ហើយដែលមានចុះហត្ថលេខា បានន័យថាអ្នកធ្វើឯកសារនេះនៅក្នុងសម័យនោះ។ តើ ប៉ុន ហ្នឹងមានតួនាទីអ្វី? ហើយទទួលខុសត្រូវលើអ្វីខ្លះនៅក្នុងមន្ទីរសន្តិសុខស-២១?

**ធ៖** អរគុណ។ ប៉ុន ជាយុវជនម្នាក់ដែលខ្ញុំរួចពីគុកទៅ ខ្ញុំមកនៅស្នាក់កុដិលេខ៣ ហើយមិត្ត ប៉ុន ហ្នឹងក៏ជាកូនសិស្សកុដិលេខ៣ ដូចខ្ញុំដែរ ជាគ្រូ។ ដឹក្រេកុំប្លេម៉ងតែរ បង្ហាត់នៅកំពង់សិលា។ ដល់ហើយវត់មកជួបខ្ញុំសូមភ្ជាប់ខ្សែជាមួយនឹងខ្ញុំ ខ្ញុំយល់ស្រប ព្រោះជាកូនសិស្សកុដិលេខ៣ ដូចគ្នា។ ហើយខ្ញុំដឹកនាំបង្រៀនការសួរចម្លើយ ការអីហ្នឹង ទាំងពីរនាក់នេះ ខ្ញុំឧស្សាហ៍ ប៉ុន ជាងគេ ហើយនិង មិត្តមាស។ ប៉ុន្តែ មិត្តមាស ហ្នឹងជាក្មេង ប៉ុន្តែគ្នាស្លាប់ទៅហើយ អត់បានជួយការងារអីនៅ ស-២១ ទេ ជួយការងារច្រើនដែរនៅមន្ទីរ១៣។ ដូច្នេះ អ្នកទោសពិសេស ខ្ញុំរុញទៅឲ្យ ប៉ុន ព្រោះខ្ញុំ ទាំងពីរនាក់នេះរួមគ្នាសួររហូតចាប់តាំងពីកកើតម-១៣ មក រហូតដល់ ២១ គេបែកពីខ្ញុំ ខ្ញុំឲ្យបែក ប៉ុន្តែដឹកនាំសួរចម្លើយអ្នកសំខាន់ មនុស្សសំខាន់។ គេអត់ដែលរើមនុស្សសំខាន់ណាឲ្យដាច់ចម្លើយ ស្លាប់ដាច់ចម្លើយទេ។ ហើយទុរន់ទុរាសួរលែងកើតដែរ នេះបើតាមខ្ញុំសង្កេតហើយ ច្រើនសួរបានការ។ ភាគច្រើនគេសួរបានការ។

[១៥:១៤:៤៤]

**សៈ** បាទ ហើយពាក់ព័ន្ធនឹង ឌឿន នេះដែរ យើងសួរចំណុចចុងក្រោយ សូមលោកមើលត្រង់ហ្នូតណូត -- អ៊ំ! យើងដាក់ក្រដាសសម្គាល់លេខទី៣ ចំណុចទី៣ គឺឯកសារ E3/1625 ដែលមានលេខ ERNជាភាសាខ្មែរ 00011671 និងERN ជាភាសាអង់គ្លេស 00768023។ បាទ នេះគឺជាលិខិតមួយប្រហែលជាសរសេរឡើងពីរបីថ្ងៃមុនលិខិតដែលបាន -- យើងបានទើបយកមកពិភាក្សាអម្បាញ់នេះ។

ហើយនេះ គឺជាលិខិតរបស់ ឌឿន សរសេរទៅឲ្យលោក។ តើលោកបានមើលលិខិតនេះ ហើយនៅ?

កុំអាលទាន់ៗ លោក ឌុច។

**ឆ៖** អរគុណលោកប្រធាន។ ខ្ញុំសូមអានលិខិតនេះ ដូចតទៅ “បងឌុច ជាទីស្នេហា! រូបខ្ញុំដែលជាប់ឃុំឃាំងមកដល់ថ្ងៃនេះ រកនិយាយពុំចេញទាល់តែសោះ ព្រោះជាការដាក់ទោស ការធ្វើទារុណកម្មគ្រប់យ៉ាង។ តើធ្វើលើរូបខ្ញុំ ត្រូវ ឬមិនត្រូវ? រូបខ្ញុំពុំបានក្បត់បក្សសោះ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ ឌុច កុំអាលទាន់

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអរគុណ។ ខ្ញុំសូមអន្តរាគមន៍ឥឡូវហ្នឹងពីព្រោះខ្ញុំយល់ឃើញថា យើងសុំឲ្យសាក្សីអានលិខិតសរសេរដោយ ឌឿន ហើយដែលគាត់ពន្យល់ ពេលដែលគេសួរចម្លើយគាត់។ អ៊ីចឹង គឺខ្ញុំគិតថា<យើងកំពុងតែនិយាយពីឯកសារដែលទទួលបានក្រោមការធ្វើទារុណកម្មហើយ។ ដូច្នេះ ខ្ញុំចង់ធ្វើការកត់សម្គាល់នៅពេលនេះ មុនពេលសាក្សីបន្តអាន>អត្ថបទនេះ<>។

**លោក ឌេល លីសាក់៖**

ខ្ញុំយល់គោលបំណងនេះ គឺចង់បង្ហាញថា ការធ្វើទារុណកម្មគឺត្រូវបានប្រើប្រាស់ហើយ។ ដោយបានរៀបរាប់ថា អ្នកដែលជាប់ឃុំឃាំងនេះគឺថា ប្រឈមមុខទៅនឹងការធ្វើទារុណកម្ម។ ខ្ញុំមិនយល់ថាតើអនុសញ្ញាស្តីហាមឃាត់មិនឲ្យ<ប្រើភស្តុតាង> និយាយអំពីការប្រើប្រាស់ ការធ្វើទារុណកម្ម ដោយរបៀបណានោះទេ។ ករណីបែបនេះ មិនអាចធ្វើទៅបានទេ។ កតិកាសញ្ញានេះ មិនហាមឃាត់មិនឲ្យយកចម្លើយបែបនេះ<មកប្រើនោះ>ទេ។ ករណីកតិកាសញ្ញានេះ គឺប្រើសម្រាប់គោលបំណងរកភស្តុតាងដែលអ្នកជាប់ឃុំឃាំងនិយាយថា ខ្លួនហ្នឹងអាចត្រូវបានធ្វើទារុណកម្ម។ <ដូច្នេះខ្ញុំគិតថា ភស្តុតាងណាក៏ដោយ ដែលអ្នកជាប់ឃុំនិយាយអំពីការធ្វើទារុណកម្ម គឺអាចទទួលយកបាន។>

[១៥:១៨:០១]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអនុញ្ញាតធ្វើអត្ថាធិប្បាយខ្លីមួយ។ <បើ>គ្រាន់តែចង់ដឹងថា <តើមាន>ការធ្វើទារុណកម្មនោះ ទៅ<លើ> ឌឿន ឬក៏អត់នោះ គឺថាយើងមានភស្តុតាងគ្រប់គ្រាន់ហើយដើម្បីបង្ហាញថា គាត់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទទួលរងទារុណកម្ម ព្រោះថា ក្នុងចម្លើយ<សាក្សី>ហ្នឹង <គឺបង្ហាញគ្រប់គ្រាន់រួចទៅ>ហើយ។ <ហើយក្នុងករណីណាក៏ដោយ ការឃុំឃាំង ដូចដែលយើងបានឃើញនៅក្នុង>ចំណារ <>ដែលអង្គជំនុំជម្រះអនុញ្ញាតឱ្យអាននោះ គឺថា ក៏បង្ហាញអ៊ីចឹងដែរ។ <ហើយនៅពេលនេះនិយាយថា យើងអាចប្រើប្រាស់>ខ្លឹមសារចម្លើយសារភាពរបស់បុគ្គលម្នាក់ ដែលទទួល<បានពីការសួរចម្លើយពាក់ព័ន្ធនឹងការប្រព្រឹត្តលើ ដែលស្ថិតនៅក្រោមវិសាលភាពនៃ>អនុសញ្ញា<ប្រឆាំងនឹងការធ្វើទារុណកម្ម>។ <នេះជាចំណុចទីពីរ។ ទាំងអស់នេះមិនមែនជាចម្លើយ ដែលបញ្ជាក់អំពីការធ្វើទារុណកម្មទេ ប៉ុន្តែក៏បាននិយាយអំពីមូលហេតុដែលបុគ្គលម្នាក់នេះត្រូវបានគេឃុំឃាំងដែរ។ ដូច្នេះហើយ យើងកំពុងតែប្រើប្រាស់>ឯកសារ ដែល<ទទួលបានដោយការ>ទារុណកម្មនោះហើយ <ហើយវាត្រូវគ្នាម៉ាច់តែម្ដងទៅនឹងអ្វីដែលអនុសញ្ញាស្ដីពីការធ្វើទារុណកម្មហាមឃាត់>។ អ៊ីចឹងហើយបាន ខ្ញុំនៅតែរក្សាការកត់សម្គាល់ខ្ញុំដដែល ដូចដែលខ្ញុំបានធ្វើកាលពីម្សិលមិញ។

**សួរដោយប្រធានអង្គជំនុំ៖**

បាទ មិនអីទេ អ៊ីចឹងយើងដាក់ឯកសារនេះឡើងគឺបំណងតែមួយទេ ដោយសារយើងរកឯកសារភស្តុតាងដទៃទៀតមិនឃើញ ហើយយើងឃើញឯកសារនេះ ហើយយើងសួរសំណួរទូទៅវិញ។

**ស៖** ឌុច ដោយសារបញ្ហាក្នុងការកត់សម្គាល់ហ្នឹងគឺថា មានពាក្យអង្វរកសុំការអធ្យាស្រ័យ និងអភ័យទោសឱ្យលើកលែងទោសជីវិត បានន័យថា លើកលែងទោសសម្លាប់ដល់គាត់ហើយឱ្យគាត់ ក្នុងន័យថា ឱ្យគាត់ធ្វើអី ក៏ធ្វើដែរ ហើយសូម្បីតែរំសាយចេញពីបក្ស ឬក៏ឱ្យទៅជាមហាជន ទៅធ្វើដាំ បង្កបង្កើនផលក៏បានដែរ។ សំណួរសួរថា តើលោកបានដឹងរឿងរ៉ាវពាក់ព័ន្ធជាមួយនឹងរឿងថាគាត់សុំអភ័យទោស សុំការលើកលែងទោសពីគាត់ហ្នឹង មកលោក ឬក៏ទៅថ្នាក់ដឹកនាំដែរឬទេ? តើមានកើតរឿងហ្នឹងដែរឬទេ កន្លងមកនៅក្នុងមន្ទីរសន្តិសុខស-២១?

[១៥:២០:៤៣]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណលោកប្រធាន។ រឿង ឌឿន នេះ ខ្ញុំអត់ចាំទេ។ សំបុត្រនេះ ខ្ញុំវង្វេងហើយ មិនដឹងជាខ្ញុំបានឃើញ ឬមិនបានឃើញ។ ក៏ប៉ុន្តែអ្នកដែលសុំបែបនេះ មាន អ្នកផ្សេងទៀត គឺបង កង ចាប ហៅ សែ សរសេរសំបុត្រ ហើយអង្វរកខ្ញុំ។ សូមបក្សទុកឱ្យរស់ចុះ គាត់ចេះវិញខ្សែគោ។ សុំរស់នៅដើម្បីវិញខ្សែគោ។ ខ្ញុំបានរាយការណ៍ជូន ពូនួន គាត់សើច គាត់អត់ឱ្យទេ បន្តការការងារសន្តិបាល ទៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លើ បងចាប តទៅទៀត។ ដូច្នេះ ដោយឡែក ករណី ឡឿន នេះ ខ្ញុំវង្វេងហើយ ដឹងខ្ញុំជាខ្ញុំបានអាន ឬក៏មិនអាន ទោះបានអាន ឬមិនបានអាន ឡឿន អត់បានចេញទេ តែគេចាប់ហើយ ចាប់ហើយ។ ខ្ញុំនៅចាំបានថា ថ្ងៃមួយនោះ ប៊ុន សុំអនុញ្ញាតខ្ញុំយក កុយ ធួន ទៅផ្ទាល់ ដល់យក កុយ ធួន ទៅផ្ទាល់ ប៊ុន គាត់ដេរ ចង្កួលមុខដេរ កុយ ធួន អីចឹង។ កុយ ធួន ធ្វើស្មើក ដើរចេញមកវិញ ប៊ុន ក៏ឲ្យគេនាំ កុយ ធួន ចេញមកវិញមក។ នេះរឿងសួរចម្លើយ ឡឿន តឹងតែងបន្តិច។ ហើយចម្លើយសារភាពរបស់គាត់ មិនដឹងយ៉ាងម៉េចទេ ខ្ញុំអត់ដឹង ខ្ញុំភ្លេចអស់ទៅហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសាក្សី ដែលបានបំភ្លឺនូវសំណួររបស់ខ្ញុំ។ ឥឡូវ ខ្ញុំអស់សំណួរហើយ ហើយអស់លោក លោកស្រីចៅក្រម មានសំណួរដែរទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនធំ ដើម្បីសួរទៅកាន់លោក ហើយជាដំបូងគឺជាសំណួរសួរពីអ្វីដែលបានសួរពីមុន។ ឥឡូវ ខ្ញុំត្រឡប់មកនិយាយអំពីឈ្មោះ ណាត។ លោកដឹងទេអ្នកណាជាអ្នកសម្រេចផ្ទេរ ណាត ពីគុកស-២១ ទៅកាន់សេនាធិការ? -- សូមទោស ពីការកាន់កាប់ស-២១ ទៅសេនាធិការ អ្នកណាជាអ្នកសម្រេច សុន សេន ឬក៏ជាអ្នកណាដែលសម្រេចផ្ទេរ <ណាត> ពីអ្នកគ្រប់គ្រងស-២១ ទៅសេនាធិការនោះ?

[១៥:២៣:១៧]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណលោកចៅក្រម។ អ្នកដែលនាំពាក្យសម្ដីៗ មកនិយាយប្រាប់ខ្ញុំ និងណាត គឺបង សុន សេន។ កាលនោះ គាត់ហៅខ្ញុំទៅធ្វើការទាំងពីរនាក់។ ដល់ទៅ គាត់ថា "ឥឡូវនេះ ស-២១ ប្រគល់ឲ្យមិត្តឌុច ឯចំណែក មិត្តណាត នៅបង្រើយការងារចាស់ហ្នឹងបីខែ ពីរបីខែតទៅទៀត។ អើ! ឲ្យមិត្តឌុចសួរទៅ យឺតបន្តិចក៏យឺតចុះ មិនអីទេ។ ការងារយឺតបន្តិច ក៏យឺតចុះ។" ហ្នឹងគាត់ណែនាំប៉ុណ្ណឹង។ ដូច្នេះ បើយោងតាមសម្ដីបង សុន សេន ជាហូរហែ គាត់ចុះមកជួបស-២១ មិនមែនក្នុងនាមសេនាធិការទេ

គឺក្នុងនាមអង្គការ។ បានន័យថា ក្នុងនាម៨៧០ ឬក៏ក្នុងនាមអចិន្ត្រៃយ៍ ការិយាល័យនយោបាយមជ្ឈិមបក្ស។

**ស៖** ដូច្នេះ បើតាមចម្លើយរបស់លោក គឺ សុន សេន ហ្នឹង គាត់និយាយតាំងនាមឲ្យការិយាល័យ៨៧០ មែនទេ?

**ឆ៖** អរគុណ។ គឺសុន សេន មកជួបស-២១ ក្នុងនាម៨៧០ មិនដែលមកជួបក្នុងនាមសេនាធិការទេ។

**ស៖** សម្រាប់ជាប្រតិចារឹក <ព្រោះថា នេះជាឯកសារដែលលោកមិនបានដឹងពីមុនមកនោះទេ ប៉ុន្តែ>ខ្ញុំសូមបញ្ជាក់ថា <នៅក្នុងសំណុំរឿង>មានកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ៧៦ គឺឯកសារ E3/235, ERN ជាភាសាអង់គ្លេស 00183419, ERN ជាភាសាបារាំង 00322971, និងជាភាសាខ្មែរ 00019146។ ខ្ញុំសូមដកស្រង់៖ "ឯសមមិត្ត មាន និង សមមិត្តណាត គ្រាន់តែជាកម្មាភិបាលសេនាធិការចល័តជួយក្នុងការសេនាធិការ។ ខាងប្រតិបត្តិការប្រយុទ្ធ អត់ក្តាប់កម្លាំងផ្ទាល់ទេ។" អ្វីដែលខ្ញុំចង់ដឹងនោះគឺថា នៅពេលដែល ណាត ទៅធ្វើការនៅសេនាធិការនោះ តើលោកធ្លាប់ជួបគាត់ទៀតទេ? ហើយលោកធ្លាប់ចូលរួមប្រជុំណាដែល ណាត ចូលរួមដែរទេ? ហើយតើគាត់ក្នុងឋានៈជាសេនាធិការហ្នឹង គាត់មានតួនាទីភារកិច្ចអ្វីគ្រប់គ្រងលើស-២១ ទេ?

[១៥:២៦:៤៩]

**ឆ៖** អរគុណលោកចៅក្រម ឯកសារដែលលោកចៅក្រម លើកយកមកសូត្រនេះ ខ្ញុំឃើញក្រោយហើយទេ ឃើញនៅក្នុងសម័យ ដូចជាសម័យដេញដោលសំណុំរឿងលេខ០០១ អំពីរឿងករណីមាន ហើយនិង ណាត, ប៉ុល ពត មិនឲ្យជាប់នឹងកម្លាំងទេ។ តែតាមពិត ថ្ងៃដែលដកខ្ញុំហ្នឹង ណាត ពីដើមការងារច្រើនណាស់ គាត់ជាជំនួយការមជ្ឈិមផង ជាប្រធានគណៈកម្មាធិការពេទ្យផង ជាប្រធានគណៈកម្មាធិការទូរគមនាគមន៍យោធាផង បានមកជាប្រធានស-២១ ផង។ ដល់ក្រោយមក ថ្នាក់ខាងលើចេះតែដក ៗៗនៅសល់តែជាជំនួយការសេនាធិការ។ នេះដែលរឿងខ្ញុំដឹងពេលនុ៎ង។ ហើយការដែលផ្ទេរឲ្យខ្ញុំឡើងធ្វើប្រធាន ហើយដក ណាត ចេញនេះ សុន សេន និយាយតែប៉ុននុ៎ង។ ឯចំណែកឯកសារដែលលោកចៅក្រមសូត្រអំមិញហ្នឹង ខ្ញុំឃើញក្រោយមកទេ គឺបក្សមិនទុកចិត្ត តាមដាន ណាត យូរហើយ។

**ស៖** ខ្ញុំមិនមែនសួរអ៊ីចឹងទេ លោក ឌុច។ ខ្ញុំចង់សួរលោកថា ក្រោយមកទៀតនោះ ពេលដែល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ណាត ទៅធ្វើការនៅសេនាធិការហើយនោះ តើគាត់នៅតែបន្តគ្រប់គ្រងសកម្មភាពការងារនៅស-២១ ដដែល ឬក៏គាត់ចូលរួមនៅក្នុងដំណើរការរបស់ ស-២១ ដដែលឬក៏យ៉ាងម៉េច? ឬក៏មានតែ សុន សេន ទេ ដែលគ្រប់គ្រងលើ ស-២១ នោះ ឬក៏មានអ្នកណាផ្សេងទៀត?

**ឆ៖** អរគុណលោកចៅក្រម។ ណាត មានមកលោបញ្ជាខ្ញុំ មានមកលោបញ្ជាខ្ញុំ ក្រោយពេលដែលគាត់ដកចេញទៅហើយ ហើយក្នុងរយៈកាលដែលគាត់ត្រូវបង្ហើយការងារចាស់។ ខ្ញុំរាយការណ៍ជូន សុន សេន។ គាត់ថា មិត្ត ថ្ងៃក្រោយស្តីឱ្យទៅ ថា នែ!ឆាឆៅ រាយការណ៍ជូនអង្គការ បើមិនដាក់កន្ទុយទេ ឱ្យធាក់។ ដូច្នេះថ្ងៃក្រោយ ណាត មកឆាឆៅ ខ្ញុំថា៖ "នែ! បងឯងហ្នឹង ខ្ញុំរាយការណ៍ជូនអង្គការណា!" ដូច្នេះ ណាត មានមកលោ លោដឹកនាំបញ្ជាស-២១ ពីលើខ្ញុំ។

**ស៖** ដូច្នេះដើម្បីឱ្យច្បាស់ទាំងអស់គ្នា បើតាមលោកចាំ តើពេលណាដែល ណាត លែងមានសកម្មភាពអ្វីទាំងស្រុងពាក់ព័ន្ធនឹងការដឹកនាំ ស-២១?

**ឆ៖** ប្រហែលជានៅក្នុងខែ៦ ប្រហែលជាក្នុងខែមិថុនា។

**ស៖** <ដើម្បីកំណត់ត្រា គឺ>ខែមិថុនា ឆ្នាំ១៩៧៦។ ដូច្នេះ តើលោកដឹងទេ ថាតើ ណាត មានធ្លាប់ត្រូវបានផ្ទេរឱ្យទៅធ្វើការនៅក្រសួងការបរទេសទេ?

[១៥:៣០:២០]

**ឆ៖** អរគុណ។ យូរក្រោយមក ទើបបាន ណាត ត្រូវដកចេញពីសេនាធិការបញ្ចូលទៅខាងក្រសួងការបរទេស គឺមុនខ្ញុំទៅរៀនជាមួយនឹង ប៉ុល ពត ប៉ុន្មានខែប៉ុណ្ណឹង។ សុំទោស ខ្ញុំសុំកែតម្រូវអ្នកបកប្រែបន្តិច។ មុនៗ ខ្ញុំរៀន មុនខ្ញុំរៀន មិនមែនក្រោយទេ មុនខ្ញុំទៅរៀន។ ខ្ញុំទៅរៀនជាមួយ ណាត ជាមួយគ្នានៅនុ៎ង។

**ស៖** លោកសំដៅទៅវគ្គរៀនសូត្រជាមួយ ប៉ុល ពត ឬវគ្គរៀនសូត្រជាមួយ ណាត។ លោកចង់សំដៅថា មានវគ្គរៀនសូត្រដែលបង្រៀនដោយ ប៉ុល ពត ហ្នឹង ហើយក្នុងហ្នឹង ណាត ចូលរួមដែរ។ អ៊ីចឹងមែនទេ?

**ឆ៖** អរគុណលោកចៅក្រម។ សូមបញ្ជាក់ វគ្គសិក្សានេះ ប៉ុល ពត ដឹកនាំ ខ្ញុំក៏ជាកូនសិស្ស មិត្តហ៊ី ក៏ជាកូនសិស្ស, មិត្តហ៊ុយ ក៏ជាកូនសិស្ស, ណាត ក៏ជាកូនសិស្ស, បងហុក ក៏ជាកូនសិស្ស។

**ស៖** តើវគ្គរៀនសូត្រហ្នឹង គឺនៅខែតុលា ឆ្នាំ១៩៧៨ មែនទេ?

**ឆ៖** អរគុណ។ ថ្ងៃខែ ខ្ញុំអត់ចាំទេ ជម្រាបប្រសាសន៍លោកចៅក្រមឱ្យច្បាស់។

**ស៖** លោកបានឆ្លើយថា លោកចាំថា ណាត ត្រូវបានផ្ទេរទៅឲ្យធ្វើការនៅក្រសួងការបរទេស ដូច្នេះ តើការផ្ទេរហ្នឹង ជាវិធានការសន្តោសប្រណី ឬក៏ជាការទម្លាក់បុណ្យស័ក្តិ? ហើយហេតុអីបានជាគេផ្ទេរទៅឲ្យក្រសួងការបរទេស?

**ឆ៖** អរគុណលោកចៅក្រម។ ការដកកម្មាភិបាលពីក្នុងតំណែង ហើយបញ្ជូនទៅក្រសួងការបរទេសជាវិធានការមួយដំបូងហើយ ដែលគេៗចាប់អារម្មណ៍លើបុគ្គលនោះ មិនឲ្យជាប់នឹងកម្លាំង។ បងហុក ក៏គេបញ្ជូនទៅ, ណាត ក៏គេបញ្ជូនទៅ, កែ គឹមហួត ក៏គេបញ្ជូនទៅក្រសួងការបរទេសមុននឹងគេចាប់។

[១៥:៣៣:៤១]

**ស៖** តើលោកចាំទេ តើគេចាប់ខ្លួន ណាត នៅពេលណា?

**ឆ៖** នៅចុងឆ្នាំ១៩៧៨។

**ស៖** នៅក្នុងសំណុំរឿងយើងមានចម្លើយសារភាពរបស់ ណាត – អ៊ិន លន ហៅ ណាត គឺ ឯកសារ E3/1710 គឺចម្លើយសារភាពហ្នឹងធ្វើនៅចុងខែធ្នូ ឆ្នាំ១៩៧៨។ តើលោកចាំទេ លោករាយ-ការណ៍អំពីចម្លើយសារភាពរបស់ ណាត ហ្នឹង ទៅកាន់អ្នកណាដែរ?

**ឆ៖** អរគុណ។ សេចក្តីសារភាពរបស់ ណាត ខ្ញុំជូនទៅ ពូនួន។ អង្កាល់នោះដែលចាប់ទៅជាមួយគ្នានោះ មានណាត មានបងហុក។

**ស៖** តើ ណាត ត្រូវបានឃុំខ្លួននៅកន្លែងណា? ព្រោះថា ណាត គាត់ស្គាល់អ្នកធ្វើការនៅ ស-២១ហើយ អ៊ីចឹង គឺថាគាត់គេឃុំគាត់នៅកន្លែងណាដែរ?

**ឆ៖** អរគុណ។ កាលនោះ កន្លែងសួរចម្លើយដាក់នៅក្នុងវិទ្យាល័យពញាយ៉ាត។ អ្នកដែលស្គាល់ ណាត មាន មិត្តហ៊ី មិត្តអី ជាពិសេសៗ មិត្តហ៊ី ក៏ប៉ុន្តែអត់មាននរណាប៊ានអន្តរាគមន៍ទេ ដោះលែងទេ។

**ស៖** លោកឆ្លើយថា លោកបានរាយការណ៍ទៅ នួន ជា។ ដូច្នេះ ណាត ត្រូវបានឃុំខ្លួនក្នុងរយៈពេលខ្លី ហើយក្រោយមកវៀតណាមវាយចូល។ ដូច្នេះតើមានបញ្ជាឲ្យកម្ទេច ណាត ទេ? ហើយបើមានតើបញ្ជាឲ្យកម្ទេចនេះ ចេញមកពីខាងណា?

**ឆ៖** រឿងកម្ទេច ណាត ដូចមិនមានអីពិសេស។ កម្ទេចតាមធម្មតា មិនពន្យារទុកឲ្យយូរដើម្បីចម្លើយអីទេ អត់ទេ។ អត់មានបញ្ជាឲ្យទុក ឲ្យយូរ ដើម្បីចម្លើយឲ្យគ្រប់គ្រាន់ទេ អត់ទេ។ ចប់ យកចេញ។ កាលនុ៎ង បើតាមខ្ញុំចាំ យកចេញទៅបីនាក់ មាន ណាត, មាន បងហុក, មាន បងវន។ ទៅទាំង

បីនាក់។ ហើយមានយកទៅដល់ជើងឯកទេ ប្រហែលជានៅក្នុងព្រៃគុម្ពោត ក្បែរផ្លូវ១៦៣ ហើយនិងផ្លូវម៉ៅសេទុង។

[១៥:៣៧:៣១]

**ស៖** ខ្ញុំគិតថា លោកបាននិយាយអំពីកន្លែងហ្នឹងរួចហើយ លោកថា នៅកន្លែងហ្នឹងមានៗត្រពាំងមួយ ជាកន្លែងដែលគេសម្លាប់អ្នកទោសសំខាន់ៗ។ តើអ៊ីចឹងមែនទេ?

**ឆ៖** កន្លែងហ្នឹងឯង គឺកន្លែងដែលមានព្រៃគុម្ពោតតូចៗ ហើយមានត្រពាំងមួយនៅខាងជើងផ្លូវ១៦៣ ហើយនិងខាង -- ហើយក្បែរផ្លូវម៉ៅសេទុង។

**ស៖** អ៊ីចឹងពេល<>ដែលលោកធ្វើជាប្រធានស-២១<>លោកមានតួនាទីច្រើននៅស-២១។ លោកជាប្រធានស-២១ផង ជាប្រធានគណៈស-២១ផង តើអ៊ីចឹងមែនទេ?

**ឆ៖** អរគុណលោកចៅក្រម។ ខ្ញុំត្រូវបានតែងតាំងពាក់កណ្ដាលខែ៣ ១៩៧៦។ ដល់កាលណាតែងតាំងអ៊ីចឹងហើយ ដក ណាត ចេញ ខ្ញុំទៅជាលេខាបក្ស លេខាគណៈកម្មាធិការបក្សមន្ទីរស-២១។

**ស៖** បើលោកជាលេខាគណៈកម្មាធិការ<>ស-២១ អ៊ីចឹងលោកប្រាកដជាមានអនុលេខា ដែលជា ហ៊ី។ លោកក៏មានសមាជិកឈ្មោះ ហ៊ុយ ឬក៏ ហ៊ុយស្រែ។ ហ៊ី និង ហ៊ុយ ហ្នឹង គឺគាត់ជាសមាជិកកងពល៧០៣មែនទេ?

**ឆ៖** អរគុណ។ គឺពិតជាដូច្នោះមែន។ ខ្ញុំជាលេខាតែម្នាក់ឯងទៅ ហើយ ហ៊ុយ និង ហ៊ី សុទ្ធតែមកពីកងពល៧០៣ ជាអនុលេខា ហើយនិងជាសមាជិក។

**ស៖** យើងដឹងហើយថា ហ៊ុយ ជាប្រធានព្រៃស។ តើនៅពេលណាមួយគាត់ធ្លាប់កាន់ជាប្រធានគុកនៅតាខ្មៅទេ?

**ឆ៖** អរគុណ។ គុកព្រៃសនៅក្នុងដីរបស់ស-២១ ធ្វើស្រែ។ យើងខ្ញុំមិនដែលបានប្រើគុកព្រៃសនេះទេ។ យើងខ្ញុំនៅចាំច្បាស់ថា កាលពីសម័យដេញដោលរបស់យើងខ្ញុំ លោកចៅក្រមមានប្រសាសន៍ថា "យើងខ្ញុំមិនយកគុកព្រៃសប្រើ មកពីបក្សមិនចង់ឲ្យឃើញថា បក្សកុម្មុយនីស្តកម្ពុជាមានគុកច្រវាក់" នេះជាប្រសាសន៍របស់លោកចៅក្រមផ្ទាល់។ នេះខ្ញុំសូម*(ឮមិនច្បាស់)* ដូច្នេះគឺគុកព្រៃស យើងខ្ញុំអត់ប្រើទេ ទុកចោល។

**ស៖** សូមលោកស្ដាប់សំណួរខ្ញុំឲ្យច្បាស់ ខ្ញុំមិននិយាយអំពីគុកព្រៃសទេ ខ្ញុំសួរលោកថា តើ ហ៊ុយ នេះធ្លាប់ធ្វើជាប្រធានគុកនៅតាខ្មៅទេ? ខ្ញុំនិយាយអំពីតាខ្មៅ ខ្ញុំអត់និយាយពីព្រៃសទេ គឺទីតាំងសម្លាប់

មនុស្សតាខ្មៅ។ ខ្ញុំដឹងហើយថា គាត់ប្រធានព្រៃសហ្នឹង គឺកន្លែងហ្នឹងជាមន្ទីរអប់រំកែប្រែ ប៉ុន្តែខ្ញុំសួរលោកហ្នឹង គឺពាក់ព័ន្ធនឹងគុកតាខ្មៅ។

**ឆ៖** អរគុណលោកចៅក្រម។ ចំពោះករណីយកិច្ចរបស់ ហ៊ុយ ហើយនិង ហ៊ា មុនខែ៣ ខ្ញុំក្តាប់គេមិនជាប់ទេ ប៉ុន្តែនៅពេលដែលមកដល់ដៃខ្ញុំ មិត្តហ៊ុយ គឺកាន់កាប់ការធ្វើស្រែ ការអប់រំសាជាថ្មី នៅព្រៃស នៅកន្លែងព្រៃស។ ឯចំណែក ហ៊ា ភ្នំពេញផង ហើយនិងជើងឯកផង។

[១៥:៤២:៥៨]

**ស៖** ហ៊ុយ ត្រូវបានចាប់ខ្លួន ហើយសម្លាប់ចោល ក៏ប៉ុន្តែ ហ៊ា ហ្នឹងមិនត្រូវបានចាប់ខ្លួន ឬក៏សម្លាប់ទេ។ អ៊ីចឹងហេតុអីបានជា ហ៊ា ដែលជាសមាជិកកងពល៧០៣ ហ្នឹងមិនត្រូវបានបោសសម្អាត? តើអ្នកណាជាអ្នកសម្រេចថា សមាជិក ឬក៏កម្មាភិបាលកងពល៧០៣ ជាច្រើននាក់ត្រូវបោសសម្អាតចោលនោះ?

**ឆ៖** នៅ ស-២១ ហ៊ុយ ត្រូវបានកម្ទេច, តែ ហ៊ា អត់ត្រូវបានកម្ទេចទេ។ យើងខ្ញុំមិនមែនចេះតែកម្ទេចឲ្យតែឃើញមនុស្សមកពី៧០៣ ទេ។ ហ៊ា គេទទួលខុសត្រូវច្បាស់លាស់លើការងារគេចំពោះមុខបក្ស។

**ស៖** ដូច្នេះគឺមានអ្នកណាម្នាក់ជាអ្នកសម្រេចថា អ្នកណាខ្លះជាសមាសភាពមិនល្អ ឬសមាសភាពល្អនៅក្នុងកងពល៧០៣ មែនទេ? អ៊ីចឹងខ្ញុំចង់សួរលោកថា អ្នកណាជាអ្នកសម្រេចថា អ្នកណាម្នាក់ជាសមាសភាពល្អ ឬសមាសភាពមិនល្អនោះ? យើងដឹងហើយថា បុគ្គលិកស-២១ ជាច្រើនមកពីកងពល៧០៣។

**ឆ៖** អរគុណ។ យកឲ្យអ្នកណាសម្រេចថា អ្នកណាល្អ អ្នកណាអាក្រក់ គឺចលនាអ្នកសម្រេច។ ហ៊ា គេទទួលខុសត្រូវការងារគេខ្ជាប់ល្អណាស់។ ឯចំណែក ហ៊ុយ អត់ទេ គាត់ឡេះឡុះបន្តិច មានធ្វើកំហុស មានធ្វើកំហុសច្រើន។ កំហុសដែលខ្លាំងបំផុត ហើយចុងក្រោយបំផុត គឺបណ្តោយឲ្យអ្នកកាន់តេអូរបស់គាត់រត់ចេញពីអង្គភាពមិនដឹងជាទៅណា។ យើងខ្ញុំរកអត់ឃើញទេ។

**ស៖** ឥឡូវនេះ ខ្ញុំចង់ចោទសំណួរមួយចំនួនពាក់ព័ន្ធនឹងឈ្មោះ ប៉ង់។ តើលោកជួប ប៉ង់ ជាលើកដំបូងបំផុតនៅពេលណា? លោកស្គាល់ ប៉ង់ ជាដំបូងនៅពេលណា?

[១៥:៤៥:៥៨]

**ឆ៖** អរគុណលោកចៅក្រម។ ខ្ញុំស្គាល់ ប៉ង់ តាំងពីពេលមួយដែល ប៉ង់ -- ដែល ណាត នាំ ប៉ង់

ទៅបង្ហាញកន្លែងស-២១។ កាលនោះ យើងខ្ញុំនៅអគ្គនាយកដ្ឋាននគរបាលជាតិ។ ពេលនោះ ប៉ង់ ចូលទៅ, ណាត នាំទៅ។ ដល់ក្រោយមក សុន សេន គាត់និយាយថា អាភឹម។ ពេលនោះ អាភឹម ពួកកម្មាភិបាលមកពីហាណូយវាឆ្លើយសារភាព ពួកណាត ហ្នឹងគេសរសេរឈ្មោះអ្នកឆ្លើយដាក់នោះ។ ដល់ទៅបងសុន សេន ដំណើររឿងហ្នឹងយកមកនិយាយ។ ខ្ញុំភ័យ។ បានដល់ថា សុន សេន គាត់ថា អត់អីទេមិត្តប៉ង់ មនុស្សល្អ។ ដូច្នេះ ខ្ញុំស្គាល់ ប៉ង់ តាំងពីពេលនោះមក។

**ស៖** ខ្ញុំមិនសូវយល់ចម្លើយរបស់លោក។ លោកថា លោកខ្លាចដោយសារតែ សុន សេន ប្រាប់លោកថា គេនឹងចាប់កម្មាភិបាលមកពីហាណូយឬក៏យ៉ាងម៉េច? ម៉េចក៏ពាក់ព័ន្ធនឹងកម្មាភិបាលហាណូយ ខ្ញុំអត់យល់ ចម្លើយរបស់លោក?

**ឆ៖** អរគុណ។ នេះជារបៀបរបបធ្វើការងារពីរដែលមិនដូចគ្នា។ ណាត គាត់ឲ្យកម្មាភិបាលហាណូយដែលយើងចាប់ ហើយសារភាពនោះ សរសេរដាក់នៅលើក្ដារខៀនជាចំហ។ អាកម្មាភិបាលហាណូយ ឈ្មោះភឹម កាលនោះឆ្លើយដាក់ បងញឹម ពាយ័ព្យ។ ដល់អ៊ីចឹង បងសុន សេន យកមកនិយាយថា "នែ! អាភឹម វាមានឆ្លើយដាក់ មិត្តញឹម"។ ខ្ញុំភ័យ។ ដែលខ្ញុំភ័យនេះ ព្រោះសេចក្ដីសារភាពរបស់ខ្មាំងមិនត្រូវឲ្យអ្នកផ្សេងទៀតឃើញ។ អ្នកផ្សេងទៀត កាលនោះ ខ្ញុំសំដៅ ប៉ង់។ ហើយគាត់--

**ស៖** ខ្ញុំយល់តាមរយៈចម្លើយរបស់លោកថា ប៉ង់ ហ្នឹងមានតួនាទីសំខាន់ពីព្រោះគាត់អាចពិនិត្យមើលចម្លើយសារភាពបាន។ អ៊ីចឹងពេលដែលលោកដឹងអំពីតួនាទីខ្ពស់របស់ ប៉ង់ ហ្នឹង លោកដឹងថា ប៉ង់ ហ្នឹងធ្វើការខាងផ្នែកសន្តិបាលទេ?

**ឆ៖** អរគុណ។ ក្រោយមកបានខ្ញុំដឹងថា ប៉ង់ ហ្នឹង មិនមែនមនុស្សធម្មតាទេ ជាសមាជិកជំនួយការមជ្ឈិមបុគ្គលទី១។ ដូច្នេះខ្ញុំក៏ចាប់ផ្ដើមគោរពគេ ព្រោះគេជាអ្នកនាំសម្ដីរបស់ ប៉ុល ពត ចូលមកស-២១។

**ស៖** ប៉ង់ ជាអ្នកធ្វើការពាក់ព័ន្ធជាមួយនឹងស-២១ ប៉ុល ពត ឬក៏មជ្ឈិម។ តើអ៊ីចឹងមែនទេ? អ៊ីចឹង លោកធ្លាប់ឮមន្ទីរមួយដែលគេហៅថា មន្ទីរស-៧១ទេ? ហើយបើលោកធ្លាប់ឮ តើលោកដឹងអ្វីខ្លះអំពីស-៧១?

[១៥:៥០:៥៣]

**ឆ៖** អរគុណលោកចៅក្រម។ ខ្ញុំពីដើម ខ្ញុំស្គាល់ថា ប៉ង់ គឺជាអ្នកនាំពាក្យរបស់ ប៉ុល ពត, ជាប្រធានកងការពារមន្ទីរប៉ុល ពត។ ដល់ក្នុងសវនាការនេះ បានខ្ញុំឃើញបញ្ជីមួយរបស់ស-២១។ គេដាក់

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

"ប៉ង់ ប្រធានក្រសួង ស-៧១"។

**ស៖** ខ្ញុំចង់ឲ្យលោកបែងចែកឲ្យបានច្បាស់ អ្វីដែលលោកដឹងនៅសម័យនោះ អានេះហើយដែលខ្ញុំចង់បាន ហើយនិងអ្វីដែលលោកដឹងនៅពេលក្រោយ។ អ៊ីចឹង នៅសម័យនោះ ខ្ញុំចង់សួរលោក ថា តើលោកដឹងថាគាត់ហ្នឹង ជាប្រធានស-៧១ ឬក៏អត់ ខ្ញុំមិនសួរការដឹងឮរបស់លោកក្រោយរបបខ្មែរក្រហមទេ?

**ឆ៖** អរគុណ។ នៅពេលនោះ ខ្ញុំដឹងថា ប៉ង់ អ្នកនាំពាក្យរបស់ ប៉ុល ពត ជាប្រធានកងការពាររបស់ ប៉ុល ពត។

**ស៖** តើលោកធ្លាប់ឃើញ ប៉ង់ ចាប់ខ្លួនមនុស្ស ឬក៏នាំខ្លួនមនុស្សដែលគេចាប់ខ្លួនបាន មកស-២១ ទេ?

**ឆ៖** អរគុណលោកប្រធាន។ ប៉ង់ នាំមនុស្សមកឲ្យខ្ញុំចាប់ មាន។ មនុស្សដែលខ្ញុំនៅចាំបំផុត គឺ បង ម៉ែន សាន ហៅ យ៉ា នេះ នាំមកឲ្យខ្ញុំចាប់នៅផ្ទះរបស់ខ្ញុំ ដែលនៅតាមផ្លូវលេខ -- មុនីវង្ស។

**ស៖** តើ ប៉ង់ ធ្លាប់នាំបុគ្គលិកក្រសួងការបរទេសមក ស-២១ទេ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ។

**ស៖** ខ្ញុំសូមបញ្ជាក់ថា នៅក្នុងសវនាការយើងនេះ យើងបានស្ដាប់ចម្លើយរបស់ សាឡុត បាន គឺ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ នៅម៉ោង១០:០៤នាទី គឺឯកសារ E1/67.1 គាត់បានពន្យល់ថា <> មនុស្សដែលមកយកបុគ្គលិកក្រសួងការបរទេសទៅនោះ គឺមានឈ្មោះ ប៉ង់។ តើលោកដឹងថា ប៉ង់ មានតួនាទីអ្វីផ្សេងទៀតទេ ឧទាហរណ៍ដូចជា គាត់មានទំនាក់ទំនងអ្វីជាមួយបឹងត្របែកទេ ឬក៏គាត់មានទំនាក់ទំនងជាមួយច្រាំងចំរេះ ឬក៏មន្ទីរជុំវិញមជ្ឈិមណាផ្សេងទៀតទេ?

[១៥:៥៤:៤៣]

**ឆ៖** សូមទោសលោកចៅក្រម ខ្ញុំស្ដាប់ឃ្លានេះមិនបានទេ។ លោកចៅក្រម ចង់សួរថា តើប៉ង់ មានការទាក់ទងជាមួយអ្នកណា?

**ស៖** អ្វីដែលខ្ញុំចង់ដឹងនោះ ខ្ញុំសួរលោកថា តើលោកដឹងទេថា ប៉ង់ មានធ្វើការអ្វីផ្សេង ឧទាហរណ៍ដូចជា ពាក់ព័ន្ធនឹងមន្ទីរបឹងត្របែក មន្ទីរច្រាំងចំរេះ ឬក៏មន្ទីរណាមួយផ្សេងទៀត ជុំវិញមជ្ឈិមនោះ?

**ឆ៖** អរគុណ។ ប៉ង់ និយាយប្រាប់ខ្ញុំ ដែលកាលដែលគាត់ចុះឡើងមកខាងបឹងត្របែកផង ទៅ

ខាងច្រាំងចំរេះផង ទៅខាងឯណាឯណីនោះ មែន គាត់រវល់ការងារជាប់ ចូលជ្រៅៗទៅដល់។

**ស៖** តើ ប៉ង់ មានតួនាទីទទួលអាណិកជនខ្មែរដែលរស់នៅបរទេស ហើយត្រឡប់មកកម្ពុជាវិញទេ? ហើយតើ ប៉ង់ ធ្លាប់នាំអាណិកជនខ្មែរ ទៅស-២១ ដោយផ្ទាល់ដែរឬទេ?

**ឆ៖** អរគុណលោកចៅក្រម។ សកម្មភាពនាំខ្មែរដែលចូលមកពីបរទេសមកដល់ស្រុកខ្មែរ ត្រង់ទៅស-២១ ខ្ញុំចាំមិនច្បាស់ទេ ប៉ុន្តែខ្ញុំជឿជាក់ថាមានច្រើនដង។ ឲ្យខ្ញុំចាំច្បាស់ ខ្ញុំអត់ចាំច្បាស់ទេ។

**ស៖** បាទ សូមអរគុណ។ លោកបានឆ្លើយថា លោកធ្លាប់សន្ទនាគ្នាជាមួយ ប៉ង់។ ដូច្នេះ អ្វីដែលខ្ញុំចង់សួរលោកនោះគឺថា លោកធ្លាប់សន្ទនាជាមួយ ប៉ង់ មុនពេលគេចាប់ខ្លួន ប៉ង់ ហើយនិងឃុំខ្លួននៅស-២១ ឬក៏លោកសន្ទនាជាមួយ ប៉ង់ ហ្នឹងក្រោយពេលគេចាប់ខ្លួន ប៉ង់ ហើយ?

**ឆ៖** ខ្ញុំមានការទាក់ទងសួរដេញដោល ប៉ង់ ញឹកណាស់ ព្រោះគេនាំពាក្យសម្ដីពីខាងលើមកស-២១ នាំអ្នកផ្សេងទៀតមកឲ្យស-២១ ចាប់ ឬក៏នាំអ្នកទោសពីក្រោមកឲ្យស-២១។ ឯចំណែករឿងរ៉ាវដែលខ្ញុំបានសន្ទនាជាមួយ ប៉ង់ គឺមុនពេលដែល ប៉ង់ ត្រូវចាប់ខ្លួន។ ក្រោយពេលចាប់ខ្លួន ប៉ង់ ខ្ញុំអត់បានទៅជិត ប៉ង់ ទេ។ ហ្នឹងជម្រាបឲ្យត្រង់ ខ្ញុំអត់បានទៅជិត ប៉ង់ ទេ។

[១៥:៥៨:៤២]

**ស៖** ក្រោយពី ប៉ង់ ត្រូវបានចាប់ខ្លួន មានម្នាក់ទៀតឈ្មោះ លីន គឺ កាន លីន ហៅ កែន ម្នាក់ហ្នឹងជាមនុស្សតែមួយទេ មែនទេ?

**ឆ៖** អរគុណ។ បន្ទាប់ពី ប៉ង់ មកមាន មិត្តលីន។ មិត្តលីន ហ្នឹងហៅ កិ -- កិន -- កេន។ ខ្ញុំភ្លេចហើយ ប៉ុនថា កិន ឬក៏ កែន ហ្នឹងគឺ មិត្តលីន។ អ្ហាក! អត់ទេៗ លីន អត់មានត្រូវចាប់ ក្រោយ ប៉ង់ទេ បន្ទាប់ពី ប៉ង់ មកទេ អត់ទេ។ អ្នកបកប្រែហ្នឹង ខុសហើយ ខ្ញុំ។ លីន អត់មានត្រូវចាប់ទេ។ ឥឡូវនេះខ្ញុំសូមនិយាយតទៅទៀត ពីរឿងមិត្តលីន។ មិត្តលីន នេះមានកងពលមួយ គឺកងពល១៨០។ អាកងពល១៨០ នេះការពារមន្ទីរមជ្ឈិមទាំងមូល។ ឯចំណែក ប៉ង់ ហ្នឹង វានៅលើ លីន។ លីន ហ្នឹងនៅពីលើខាំមី។ មានមួយទៀត ឈ្មោះខាំមី ឈ្មោះគេបីនាក់ហ្នឹង។

**ស៖** បាទ ដើម្បីឲ្យច្បាស់ទាំងអស់គ្នា។ អ្នកណាមកជំនួស ប៉ង់?

**ឆ៖** អរគុណ។ គឺលីន ហៅ កែន នេះជាអ្នកជំនួស ប៉ង់។

**ស៖** ហើយចុះ លីន ត្រូវបានចាប់ខ្លួននៅពេលណា បើគាត់ជំនួស ប៉ង់ ក្រោយមកគាត់ប្រាកដជាត្រូវបានចាប់ខ្លួនដែរហើយ។ អ៊ីចឹង គាត់ លីន ហ្នឹង ត្រូវបានចាប់ខ្លួននៅពេលណា?

01311959


**ឆ៖** លីន នេះអត់មានចាប់ខ្លួនទេ។ ខ្ញុំជួប លីន នៅឆ្នាំ១៩៨០ប្លាយ ៨៥។

**ស៖** អ៊ីចឹង លោកនិយាយអំពីអ្នកណា ពេលដែលលោកថាគាត់ត្រូវបានចាប់ខ្លួនមុន ប៉ង់ ហ្នឹង គាត់ លោកនិយាយពីអ្នកណា ពីគីម? ពីកែន? អ្នកណាមួយ? អម្បាញ់មិញនេះ លោកថា ម្នាក់ដែលខ្ញុំគិតថា លីន ហ្នឹង ត្រូវបានចាប់ខ្លួនមុន ប៉ង់ អ៊ីចឹងលោកនិយាយសំដៅលើអ្នកណាដែលលោកថា ម្នាក់ហ្នឹងត្រូវបានចាប់ខ្លួនមុន ប៉ង់ ហ្នឹង?

[១៦:០២:៣២]

**ឆ៖** អ្នកដែលកម្មាភិបាលហាណូយ ដែលចាប់មុន ប៉ង់ ហ្នឹង ឈ្មោះ ភីម -- ភីមៗ ដែលឆ្លើយពីរឿង បងញឹម ចូលក្នុងបក្សពួកក្បត់។

**ស៖** តើ ភីម នេះ មានជាប់សាច់ញាតិអី ឬក៏មានទំនាក់ទំនងអីជាមួយ អៀង សារី ទេ?

**ឆ៖** អរគុណ។ ប៉ង់ ទាក់ទងជាមួយនឹង អៀង សារី កម្រិតណា ខ្ញុំអត់ដឹងទេ។ ក៏ប៉ុន្តែតួនាទីរបស់ ប៉ង់ ធំណាស់ គាត់ដើរចូលគ្រប់កន្លែង។

**ប្រធានអង្គជំនុំ៖**

បាទ ប៉ុណ្ណឹងសិនចុះបាទ។ បាទ ហើយសវនាការនៅថ្ងៃនេះដល់ ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី១៥ ខែមិថុនា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។ អង្គជំនុំជម្រះអរគុណលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប និងសាក្សី ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ហើយដោយឡែកលោក កាំង ហ្កេកអ៊ាវ បង្គាប់ឲ្យនាំខ្លួនគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងប្រាំបួនគត់។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*